ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងការទទួលខុសត្រូវក្នុងការការពារ

◆ ភាពខុសគ្នារវាងការថែទាំសុខភាពរបស់មេដឹកនាំខ្មែរក្រហម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៥៧ ខែឧសភា ឆ្នាំ២០២១

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៥៧ ខែឧសភា ឆ្នាំ២០២១

## មាតិកា

### សំបុត្រ


◆ ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងការទទួលខុសត្រូវក្នុងការការពារ .................. ១


### ផ្នែកឯកសារ


◆ កែន ឆាំ បញ្ជាការកងអនុសេនាធំ៤៧ថ្មី ..... ៣


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ ខាំ នឿន ៖ ពិការជើងដោយសារជាន់មីន..... ៦
◆ ខ្ញុំឈឺគ្រុនចាញ់ .............................. ៨
◆ ឈាង ជួ ៖ វរសេនាតូច១២០ កងពលទី១ ..... ១០
◆ ជីវិតថ្ងៃ...................................... ១២
◆ នួន ហុងលីម៖ ការចងចាំអំពីជីវិតក្នុងរបប ..... ១៤
◆ ភាពឈឺចាប់ក្រោយរបប ប៉ុល ពត ដួលរលំ. ១៧
◆ ម៉ក សំអឿន៖ អតីតពេទ្យសហករណ៍ ....... ២០
◆ វ៉ាន់ មឿន អតីតយោធាផ្នែកកាំភ្លើងធំ ......២៣
◆ សុំ សឿម៖ អតីតមេបញ្ជាការវរសេនាតូច-៥១ .. ២៦
◆ សោម ហេង៖ ខ្ញុំជាទាហានរបស់ សោ ភឹម ...២៨
◆ ក្រោយរដ្ឋប្រហារភូមិរបស់ខ្ញុំទទួលរងការ ..... ៣២
◆ ខ្ញុំមិនចង់រំឭករឿងពីអតីតកាល.............. ៣៥
◆ នៅតែរឭកដល់ឪពុក និងបង...............៣៨
◆ សៀក ហេង៖ ចូលកងសែងយោធា .........៤០
◆ អនុស្សាវរីយ៍ក្នុងរបបខ្មែរក្រហម ........... ៤៣


### ផ្នែកច្បាប់


◆ សាលក្រមសំណុំរឿង០០២/០២ ............ ៤៦


### ផ្នែកវេទិកាសាធារណៈ


◆ ភាពខុសគ្នារវាងការថែទាំសុខភាពរបស់មេដឹកនាំខ្មែរក្រហម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ............................ ៥៦


### ផ្នែកស្រាវជ្រាវរកគ្រួសារ


◆ នៅតែទន្ទឹងរង់ចាំដំណឹងពីសមាជិកក្រុមគ្រួសារដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហម ........... ៥៧




ស្តូបតំកល់អដ្ឋិធាតុជនគ្រោះពីរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥-១៩៧៩) នៅខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្មេរលេខនេះ៖** ឆាំង យុ, មេក វិន, ពីង ឧស្សាហ៍, ឡុង អូន, សួត វិចិត្រ, ស៊ាង ចិន្តា, ហ៊ាន ពិសី, គាត ស្រីឡែន, ផាត ចាន់សុនិតា, មីន សាណាស់, ភា រស្មី, សុខ វណ្ណៈ, ព្រំ ផល្លា, ទូច វណ្ណេត, រី លក្ខិណា និង កែម សុភី

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដារ៉ារដ្ឋ មេត្តា **អ្នកបកប្រែ៖** អ៊ុន សុដាវី **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** អ៊ុន សុដាវី **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងការទទួលខុសត្រូវក្នុងការការពារ

ឆាំង យុ

*២០ ឧសភា ២០២១*

*បុព្វកថានៃអនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានចែងថា “**អំពើប្រល័យពូជសាសន៍ គឺជាឧក្រិដ្ឋកម្មមួយដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ**” ប៉ុន្តែចាប់តាំងពី អនុសញ្ញាប្រល័យពូជសាសន៍ត្រូវបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៤៩មក តើមានអំពើប្រល័យពូជសាសន៍ប៉ុន្មានហើយ ដែលបានកើតឡើង? តើអំពើប្រល័យពូជសាសន៍ ចំនួនប៉ុន្មានករណីត្រូវបានកាត់ទោសតាមច្បាប់ជាតិឬអន្តរជាតិ? ចាប់តាំងពីឆ្នាំ១៩៤៩មានអំពើប្រល័យពូជសាសន៍ចំនួន ៣ តែប៉ុណ្ណោះ (ប្រទេសកម្ពុជា បូស្នៀ និងរវ៉ាន់ដា) ដែលត្រូវបានយកទៅជំនុំជម្រះនៅក្នុងតុលាការអន្តរជាតិ។*

*ប្រទេសកម្ពុជាបានបាត់បង់ប្រជាជនប្រមាណ ២លាននាក់ក្នុងរយៈពេលតិចជាង៤ឆ្នាំ។ អស់រយៈពេល ៤០ឆ្នាំបានកន្លងផុតទៅហើយ ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហម និងសព្វថ្ងៃមានអ្នករស់រានមានជីវិតចំនួន ៥លាននាក់។ អ្នករស់រានមានជីវិតភាគច្រើន នៅតែបន្តតស៊ូជាមួយភាពភ័យរន្ធត់ដែលខ្លួនបានជួបប្រទះ ឬបានរងទុក្ខ ហើយផលប៉ះពាល់នៃរយៈពេលនោះ បានជះឥទ្ធិពលដល់ជីវិតរបស់អ្នករស់រានមានជីវិតមិនត្រឹមតែ នៅក្នុងទម្រង់នៃការប៉ះទង្គិចផ្លូវចិត្តតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្ថានភាពសុខភាពផ្លូវកាយ និងការរងរបួសនៅលើរាងកាយ ដែលនៅតែបន្តទទួលស្គាល់ជាសាធារណៈតិចតួចបំផុតនិងមិនមានការគាំទ្រជាក់លាក់ដើម្បីទទួលបានសេវាកម្មថែទាំសុខភាព។*



*លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតឡើងមិនត្រឹមតែដើរតួនាទីជាកន្លែងតម្កល់ឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យធំបំផុតនៅលើសកលលោកតែប៉ុណ្ណោះទេ ប៉ុន្តែក៏បានចូលរួមវិភាគទានដ៏សំខាន់ដល់ការអប់រំអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) នៅលើប្រធានបទនេះ។ ការងាររបស់យើងនៅតែបន្តដំណើរការទៅមុខជាលំដាប់ ពីព្រោះសមាគម*

អាស៊ានទោះបីមានឈ្មោះជា សហគមន៍មួយ ប៉ុន្តែនៅមិនទាន់មានលក្ខណៈពេញលេញ និងរឹងមាំនៅឡើយទេ។

មជ្ឈមណ្ឌលឯកសារកម្ពុជា មើលឃើញថាការចងក្រងឯកសារនិងការអប់រំអំពីអំពើប្រល័យពូជសាសន៍ គឺជាកត្តាដ៏សំខាន់ ដើម្បីបន្ការនិងដោះស្រាយផលប៉ះពាល់នៃអំពើប្រល័យពូជសាសន៍ ប៉ុន្តែនេះគ្រាន់តែជាមួយផ្នែកតូចនៃកិច្ចខិតខំប្រឹងប្រែងរួមរបស់យើង។ នៅក្នុងឆ្នាំ២០២១ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងពង្រីកការងារដើម្បីរួមបញ្ចូលការគាំទ្រដល់ការថែទាំសុខភាព និងសុខុមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងអនុវត្តសកម្មភាពដែលមានគោលបំណងជាក់លាក់ដើម្បីលើកកម្ពស់ការថែទាំសុខភាព និងសុខុមាលភាព ក៏ដូចជាធ្វើការចុះស្រាវជ្រាវនិងសកម្មភាពផ្សព្វផ្សាយ ដែលលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការតស៊ូរបស់អ្នករស់រានមានជីវិត។

គម្រោងដែលនឹងអនុវត្តទូទាំងប្រទេសមួយនេះ តំណាងឲ្យការបោះជំហានទៅមុខ ដែលមិនត្រឹមតែយកចិត្តទុកដាក់និងដោះស្រាយនូវគម្លាតដ៏ធំនៅក្នុងការផ្តល់សេវាកម្មថែទាំសុខភាព និងសុខុមាលភាពរបស់អ្នករស់រានមានជីវិតអំពីអំពើប្រល័យពូជសាសន៍តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្លាស់ប្តូរគំនិតនៃយុត្តិធម៌អន្តរកាល ទៅជាការស្តារយុត្តិធម៌ឡើងវិញ។

ការស្តារយុត្តិធម៌ឡើងវិញ គឺពឹងផ្អែកទៅលើការប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវវិធីសាស្ត្រដែលចម្បង និងមានស្រាប់ក៏ដូចជាការបង្កើតវិធីសាស្ត្រថ្មីៗដោយផ្អែកទៅលើសង្គមបច្ចុប្បន្ន ដែលកំពុងបន្តវិវឌ្ឍន៍ទៅមុខ។ មានសំណួរមួយអំពីវិធីសាស្ត្រចម្បង សម្រាប់ការលើកកម្ពស់ការទប់ស្កាត់ការកាប់សម្លាប់រង្គាល ចម្លើយរបស់ខ្ញុំគឺប្រជាជនគ្រប់រូប រួមទាំងអ្នកពាក់ព័ន្ធថ្នាក់ជាតិ និងស្ថាប័នផ្សេងៗ ដើរតួនាទីសំខាន់ដូចគ្នាក្នុងការសម្រេចបាននូវការផ្លាស់ប្តូរដែលមានឥទ្ធិពលមួយ។ សំណួរមួយទៀតបានសួរដើម្បីកំណត់អត្តសញ្ញាណឧបករណ៍អប់រំដែលមានប្រយោជន៍បំផុតសម្រាប់ការអប់រំទាក់ទង នឹងការទប់ស្កាត់ការកាប់សម្លាប់រង្គាល ហើយខ្ញុំសូមបញ្ជាក់ម្តងទៀតថាការផ្លាស់ប្តូរដែលមានឥទ្ធិពល គឺពឹងផ្អែកទៅលើការប្រើប្រាស់វិធីសាស្ត្រដែលមានស្រាប់ឲ្យអស់ពីលទ្ធភាព និងត្រូវបានទទួលស្គាល់ក្នុងការយកទៅរៀនសូត្រ ក៏ដូចជាការបង្កើតវិធីសាស្ត្រថ្មីៗ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តការរួមបញ្ចូលទម្រង់នៃការរៀនសូត្រ និងការអប់រំបែបប្រពៃណី និងទាន់សម័យដើម្បីទទួលបាននូវការរួមបញ្ចូលគ្នារវាងទម្រង់ចាស់ និងថ្មី ។ តាមរបៀបនេះ ការអប់រំអាចបញ្ជាក់អំពីចំណេះដឹង និងបទពិសោធន៍របស់មនុស្សម្នាក់ ក៏ដូចជា ធ្វើឲ្យមានការផ្លាស់ប្តូរអំពីអ្វីដែលបុគ្គលម្នាក់បានដឹង និងគិតអំពីពិភពលោក។ យុត្តិធម៌អន្តរកាលអាចហៅថាជាយុត្តិធម៌បានលុះត្រាណាតែត្រូវបង្កើតឡើងដោយការខិតខំប្រឹងប្រែង មានទំនុកចិត្ត និងមានប្រសិទ្ធភាពក្នុងគោលបំណងស្តារឡើងវិញ ក៏ដូចជា ការផ្លាស់ប្តូរសង្គម និងបុគ្គលម្នាក់ៗ។



ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ប្រជាជនកម្ពុជាគ្រប់គ្រួសារបានបាត់បង់សមាជិកគ្រួសារ និងសាច់ញាតិ ដោយសារការធ្វើការងារហួសកម្លាំង ការបង្អត់អាហារ ជំងឺ និងការយកទៅសម្លាប់។ រូបថតនេះនៅស្ពានថ្ម ខាងមុខព្រះរាជដំណាក់ក្នុងក្រុងសៀមរាប។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# កែន ឆាំ បញ្ជាការ កងអនុសេនាធំ៤៧ថ្មី កងពល៧០៣

ជាវ៉ារដ្ឋ មេត្តា



*កងកាំភ្លើងធំរបស់កងទ័ពបដិវត្តន៍ខ្មែរវាយប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅសមរភូមិខេត្តស្វាយរៀង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ កែន ឆាំ និងមានឈ្មោះ បដិវត្តន៍ កែន សិត គឺជាជនជាតិខ្មែរដែលមាននាទីជាបញ្ជាការ កងអនុសេនាធំ អង្គភាព ៤៧ ថ្មី ប្រចាំកងពល ៧០៣ ។ ខ្ញុំមានអាយុ ២៨ឆ្នាំ នៅក្នុងឆ្នាំ ១៩៧៧ ។ ខ្ញុំមិនទាន់មានគ្រួសារទេ ។ ទីកន្លែងកំណើតរបស់ខ្ញុំនៅភូមិព្រៃទំនប់ ឃុំកំពង់ស្វាយ ស្រុក១៦ តំបន់ ២៥ ។ ឪពុកខ្ញុំឈ្មោះ កែន សុំ អាយុ ៥៧ឆ្នាំ និង ម្តាយ ឈ្មោះ វ៉ែន យ៉ាន់ អាយុ៥២ឆ្នាំ។ ឪពុកខ្ញុំ គឺជាជាងកាត់សក់ និងពេលខ្លះគាត់ឆ្មៀតរកត្រីសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ខ្ញុំមានបងប្អូនបង្កើតទាំងអស់ចំនួន ១០នាក់ ក្នុងនោះស្រីចំនួន ៦នាក់ ។ បងប្អូនរបស់ខ្ញុំបានចូលធ្វើបដិវត្តន៍ចំនួន ៣នាក់ និងចូលសហករណ៍ចំនួន ៧នាក់។ បងប្អូនខ្ញុំចំនួន ៣នាក់មានគ្រួសាររួចហើយ។

ខ្ញុំបានសម្រេចចិត្តចូលបដិវត្តន៍នៅថ្ងៃទី ១៤ ខែតុលា ឆ្នាំ១៩៧០ នៅភូមិព្រៃទំនប់ដោយមានឈ្មោះ សារឿន គឺជាអ្នកនាំចូល។ សារឿន គឺជាអ្នកឃោសនាអប់រំប្រជាជន យុវជន នៅក្នុងតំបន់ខ្ញុំរាំង។ ខ្ញុំចូលបដិវត្តន៍ដោយបានទទួលនាទីជាបន្តបន្ទាប់ គឺជាមេពួក អនុក្រុមសមាជិកកងអនុសេនាតូច បញ្ជាការកងអនុសេនាតូច

នយោបាយអនុសេនាតូច សមាជិកកងអនុសេនាតូច បញ្ជូរការងអនុសេនាធំ។

នៅខែមេសា ឆ្នាំ១៩៧៥ ក្រោយរំដោះបានទីក្រុងភ្នំពេញដែលជាតំបន់សេដ្ឋកិច្ច កងរបស់ខ្ញុំបានទៅរៀបចំសណ្តាប់ធ្នាប់ ដោយខ្ញុំពិនិត្យមើលយុទ្ធជនរៀបចំផ្ទះ និងជម្រះស្មៅ។ នៅប្រមាណម៉ោង ៨ព្រឹក ឈ្មោះ សុន បានដើរមករកខ្ញុំ។ សុន បានសួរខ្ញុំអំពីការងារ។ ក្រោយមក សុន បានឲ្យខ្ញុំនាំគាត់ដើរមើលអគ្គភាពនៅជិតៗនោះ និងត្រួតពិនិត្យមើលឃ្លាំង។ មួយថ្ងៃក្រោយមក ខ្ញុំបានទៅកន្លែង សុន ធ្វើការនៅម្តុំក្បាលថ្នល់ដើម្បីសួរគាត់អំពីរបៀបនៃការរៀបចំផ្ទះ។ នៅពេលជួបគ្នា សុន មិនឲ្យខ្ញុំប្រញាប់ប្រញាល់ត្រឡប់ទៅអគ្គភាពវិញទេ គឺឲ្យខ្ញុំនៅអង្គុយនិយាយលេងនៅកន្លែងធ្វើការរបស់គាត់សិន។ យើងបាននិយាយគ្នាអំពីការងារ និងការរៀបចំផ្ទះ ហើយថែមទាំងប្រាប់ខ្ញុំកុំឲ្យខិតខំធ្វើការ គឺគ្រាន់តែដើរមើលយុទ្ធជនធ្វើការងារទៅបានហើយ។ និយាយបណ្តើរ សុន សើចបណ្តើរ និងមានបង្អែមទទួលខ្ញុំផង។ ក្រោយមកខ្ញុំបានត្រឡប់មកមើលអគ្គភាពនៅកំពង់រាប។ សុន គឺជាកម្មាភិបាលដែលយកចិត្តទុកដាក់ជាងកម្មាភិបាលឯទៀតដែលខ្ញុំធ្លាប់រស់នៅជាមួយ។

រយៈពេលប្រហែល ៦ទៅ ៧ថ្ងៃបន្ទាប់មក ខ្ញុំបានទៅជួប សុន ម្តងទៀតនៅក្បាលថ្នល់ ។ ពេលខ្ញុំទៅជួបគាត់ គាត់ក៏បានជួបមនុស្ស ២នាក់ទៀតដែរ គឺឈ្មោះ យ៉ន និង សូត្រ នៅទីនោះ។ សុន បានលើកឡើងថា ថ្ងៃទី ៣០ ខែមេសា មុននេះ នៅប្រទេសវៀតណាមខាងត្បូង គឺត្រូវបានរំដោះទាំងស្រុងហើយ។ ការទាក់ទងរវាងប្រទេសយើងទាំងពីរស្អិតដូចដីរញ្ញៅ បេះមិនដាច់ ចាប់តាំងពីសម័យសង្គ្រាមរហូតមិនដែលបែកបាក់គ្នាម្តងណាឡើយ។ សុន និង ឈឹន បានអប់រំខ្ញុំអំពីការធ្វើបដិវត្តន៍មានការលំបាក មិនងាយឡើងតួនាទី។ ចំណែកបងប្អូនសាច់ញាតិដែលចូលធ្វើបដិវត្តន៍ នៅអគ្គភាពខុសគ្នាក៏មិនអនុញ្ញាតឲ្យជួបមុខគ្នាដែរ គឺតឹងតែងរឹតត្បិតសេរីភាព។ ដូច្នេះមានតែផ្លូវម្យ៉ាង គឺយើងនាំគ្នាក្រោកឈរធ្វើការតស៊ូប្រឆាំងនឹងរបបបដិវត្តន៍សព្វថ្ងៃនេះ។ ក្រោយពីខ្ញុំទទួលបានការអប់រំពី សុន និង ឈឹន ខ្ញុំបានយល់ច្បាស់អំពីខ្លឹមសារបដិវត្តន៍។ ខ្ញុំបានចូលបក្សពលករ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៥ ដោយឈ្មោះ សុទ្ធ គឺជាអ្នកខាងទ្រុសនាម។ ទីតាំងដែលខ្ញុំចូលនៅបន្ទាយប៉េអឹម ក្បាលថ្នល់។ សុន បានលើកឡើងអំពីការផ្តាំផ្ញើ និងទិសដៅរបស់បក្សពលករថា ស្មើមិត្តទាំងអស់ឲ្យរក្សាឥទ្ធិពល និងកិត្តិយសរបស់បក្សថ្មីឲ្យបានល្អ និងរក្សាការសម្ងាត់ឲ្យបានជាដាច់ខាត។

ចំណែកផែនការ និងខ្លឹមសាររបស់យើងម្នាក់ៗ ត្រូវកសាងកម្លាំងបក្សពលករឲ្យបានចំនួន ៣នាក់ ក្នុងមួយខែ, ត្រូវដឹកនាំកម្លាំងឲ្យធ្វើបដិវត្តន៍ចុះខ្សោយទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន, បំផុសទំនាស់ និងបំផ្លាញសម្ភាររបស់អង្គការ។ នៅក្នុងរយៈពេល ៣ ទៅ ៤ថ្ងៃ ត្រូវទាក់ទងគ្នា ពិភាក្សាអំពីផែនការ និងសកម្មភាពម្នាក់ៗដែលសម្រេចបាន ត្រូវក្តាប់មហាជនឲ្យបានជារៀងរាល់ថ្ងៃ ដើម្បីងាយស្រួលអូសទាញកម្លាំង។

អ្នកចូលបក្សពលករជាមួយខ្ញុំកាលនោះមាន សូត្រ គឺជាលេខាអនុសេនាធំ វរសេនាធំ វរសេនាតូច១២៧ វរសេនាធំ ២៦៨ កងពល១២ចាស់ ហើយបច្ចុប្បន្នអគ្គភាព «ស-២១», យ៉ន យោធាអនុសេនាធំ វរសេនាតូច ១២៧ វរសេនាធំ ២៦៨ កងពល ១២ ចាស់ បច្ចុប្បន្នអគ្គភាព «ស-២១» , ហ៊ុន យោធាវរសេនាតូច ១២៧ វរសេនាធំ ២៦៨ កងពល ១២ចាស់ បច្ចុប្បន្នអគ្គភាព«ស-២១», រុន សមាជិក អនុសេនាតូច អនុសេនាធំ៧១ និងខ្ញុំ។ ខ្សែបក្សពលករដែល សុន បានប្រាប់ខ្ញុំមានចំនួន ៤នាក់ រួមមាន វ៉ែន សមាជិកអនុសេនាធំ វរសេនាធំ ២៦៨ កងពល ១២ ចាស់ នៅអគ្គភាព «ស-២១» ។ វ៉ែន មានមាឌតូច មុខស្រួច សក់ស្កូត ដំណើរញាប់ ខ្នងកំពឹស និយាយមួយៗ សំឡេងធំ, ប៉េង គឺជាស្នងការអនុសេនាធំ វរសេនាតូច ១២៧ វរសេនាធំ ២៦៨ កងពល ១២ ចាស់ អគ្គភាព «ស-២១» ។ ប៉េង មានសម្បុរខ្មៅ មាឌធំ មុខវែង ដំណើរញាប់ និយាយពុៗ ហើយសំឡេងធំ, ថៃ គឺជាយោធាអនុសេនាធំ វរសេនាតូច ១២៧ វរសេនាធំ ២៦៨ កងពល ១២ចាស់ នៅខាងយន្តហោះ។ ថៃ មានសម្បុរខ្មៅ មាឌធំល្មម មុខមូលតូច សក់ស្កូត ភ្នែកតូចល្មម ដំណើរមួយៗ និយាយតិចៗ សំឡេងតូច និង ហ៊ិ គឺជាស្នងការអនុសេនាតូច អនុសេនាធំ ៧១ វរសេនាតូច ១២៧ វរសេនាធំ ២៦៨ កងពល ១២ចាស់។ ហ៊ិ មានសម្បុរស មាឌស្តើង ដំណើរមួយៗ និយាយតិចៗ សំឡេងតូចៗ ខ្ញុំបានទាក់ទងអ្នកទាំងនោះជាប់រហូតព្រោះខ្ញុំធ្លាប់រស់នៅ និងស្និទ្ធស្នាលជាមួយគ្នា។

បន្ទាប់មក សុន បានណែនាំប្រាប់ឈ្មោះឲ្យខ្ញុំស្គាល់បន្តទៀត រួមមានឈ្មោះ គ្រុយ នាទី អនុសេនាធំ វរសេនាតូច ១២៧ វរសេនាធំ ៣៦៨ កងពល១២ចាស់ អង្គភាព «ស-២១», សារ៉េត ប្រធានមន្ទីរវរសេនាតូច១២៧ វរសេនាធំ ២៦៨ កងពល ១២ ចាស់ អង្គភាព«ស-២១», កើត ស្នងការកងហា អនុសេនាធំ ៧២ វរសេនាតូច ១២៧ វរសេនាធំ៦៨ កងពល ១២ចាស់ អង្គភាព ៤៧ថ្មី របស់កងពល៧០៣, អ៊ុច ពេញ គឺជាស្នងការកងហាអនុសេនាធំ ៧១ វរសេនាតូច ១២៧ វរសេនាធំ ៦៨ កងពល ១២ ចាស់ ក្រោយមកអង្គការបានដក អ៊ុច ពេញ មកអង្គភាព ៤៧ថ្មី របស់កងពល៧០៣, សៅ ស្រស់ សមាជិកអនុសេនាតូច អនុសេនាធំ ៧៣ វរសេនាតូច ១២៧ វរសេនាធំ ៦៨ កងពល ១២ចាស់ អង្គភាពវរសេនាតូច ៣២២ វរសេនាធំ ៣២ កងពល ៧០៣ថ្មី, ហ៊ិន គឺជាស្នងការកងហា អនុសេនាធំ ៧៣ វរសេនាតូច ១២៧ វរសេនាធំ ២៦៨ កងពល ១២ ចាស់ បច្ចុប្បន្ននៅមន្ទីរពិការ។ ហ៊ិន មានសម្បុរពណ៌សណ្តែកបាយ មុខមូលខ្លី សក់ស្កួត ដំណើរញាប់ និយាយព្តុៗ សំឡេងតូច និងពិការដៃឆ្វេង។

នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧៥ ខ្ញុំបានដើរទៅមើលយុទ្ធជននៅអង្គភាពយាមនៅក្បាលថ្នល់ ពេលនោះខ្ញុំបានដើរចូលទៅកន្លែងអង្គភាពរបស់ សុន ក្នុងគោលបំណងសួរសុខទុក្ខគាត់ ប៉ុន្តែ សុន ប្រាប់ថាថ្ងៃស្អែកយើងជួបគ្នានៅសាលាបឹងត្របែក នៅម៉ោង៧ព្រឹក ដើម្បីធ្វើការងាររបស់យើងមួយចំនួន។ លុះថ្ងៃទី២៧ ខែឧសភា ម៉ោង៧ព្រឹកខ្ញុំបានទៅជួប សុន ត្រង់សាលាវ៉ែងកណ្តាល។ សុន បានលើកអំពីបញ្ហាចំនួនពីរនិយាយជាមួយខ្ញុំ គឺទី១) មតិណែនាំរបស់គាត់ និង ទី២) ឧទ្ទេសនាមប្រាប់ពីខ្មែរបក្សពលករនៅក្នុងអង្គភាពវរសេនាតូច១២៧។ ក្រោយពីទទួលការអប់រំ បំពាក់បំប៉នខ្មែរ បានធ្វើឲ្យខ្ញុំកាន់តែមានជំនឿខ្លាំងឡើងលើអនាគតរបស់កម្លាំងពលករ។

នៅចុងខែមិថុនា ឆ្នាំ១៩៧៥ អង្គការបានចាត់តាំងអង្គភាពរបស់ខ្ញុំទៅធ្វើស្រែ និងដាំដំណាំផ្សេងៗ នៅព្រែកហូរ។ បន្ទាប់ពីចេញពីព្រែកហូរ អង្គការបានចាត់តាំងខ្ញុំឲ្យទៅធ្វើស្រែនៅព្រៃស។ នៅដើមខែសីហា ឆ្នាំ១៩៧៥ សុន និង ឈឹនបានទៅអប់រំខ្ញុំនៅទីនេះ។ ខ្លឹមសារនៅក្នុងពេលនោះ ពង្រឹងគោលជំហរម្នាក់ៗ ត្រូវយកចិត្តទុកដាក់ក្តាប់យុវជន មហាជនសេរីឲ្យបានច្រើន ដែលធ្វើឲ្យងាយស្រួលក្នុងការពង្រីកកម្លាំង។ សមមិត្ត ត្រូវចុះឲ្យជាប់លើការងារ ឬបញ្ហាទាំងអស់គឺធ្វើឲ្យងាយស្រួលក្នុងការបំផុសឬចាត់តាំង និងត្រូវឯករាជ្យម្ចាស់ការលើខ្លួនឯង។ អ្នកដែលបានចូលរួមមានខ្ញុំ, វ៉ែន, ប៉េង, សូត្រ និង យ៉ន។ ក្រោយមកខ្ញុំបានយកខ្លឹមសារនេះទៅអប់រំនៅកន្លែងធ្វើការ ដូចជា ពេលស្ទូងស្រូវ ភ្ជួរដី និងពេលធ្វើការនៅកន្លែងមួយចំនួនទៀត។ ក្រោយមកមិនបានប៉ុន្មាន ថៃ និង សុន ត្រូវអង្គការដកទៅអង្គភាពវរសេនាធំ ៣៣ ។ ចំណែកខ្មែរបក្សពលករដែលជាកងអនុសេនាធំ ត្រូវអង្គការដកចេញ និងបំបែកពីអង្គភាពទាំងអស់។ ទោះបីត្រូវអង្គការប្តូរ និងដកនៅសល់តែខ្ញុំតែម្នាក់ក្នុងអង្គភាព ក៏ខ្ញុំនៅតែធ្វើសកម្មភាពប្រឆាំងដាច់ខាតជាមួយអង្គការ ដូចជា បំផ្លាញសម្ភារ ខោអាវ មុងភួយ ប្រហែលជា ៤ទៅ៥បាវ ដោយយកទៅចោលហាលភ្លៀង, យកប្រេងពីរធុងទៅចាក់ចោល, បំផ្លាញម៉ាស៊ីនធ្វើទុយោអស់មួយគ្រឿង, បំផ្លាញសម្ភារ, ចាន, កែវ និងឆ្នាំងអស់មួយចំនួន។

ក្រោយមក នៅក្នុងខែកក្កដា ឆ្នាំ១៩៧៦ អង្គការបានចាត់តាំងខ្ញុំឲ្យមកបំពេញភារកិច្ចនៅក្នុងអង្គភាពវរសេនាតូច ៣២៣ វិញ ។ ក្រោយពីបានធ្វើសកម្មភាពយ៉ាងសកម្មនៅក្នុងអង្គភាពវរសេនាតូច ៣២១ នេះមកខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅនៅក្នុងអង្គភាព៤៧ ថ្មីរបស់កងពល ៧០៣ ។ ក្រោយពីខ្ញុំផ្លាស់មកនៅក្នុងអង្គភាព៤៧ថ្មី ខ្ញុំមិនបានធ្វើសកម្មភាពអ្វីទេគឺចង់ឲ្យអង្គការទុកចិត្តមកលើរូបខ្ញុំមួយរយៈ។ ក្រោយមកអង្គការបានចាប់ខ្ញុំ និងសួរចម្លើយខ្ញុំនៅខែ សីហា ឆ្នាំ១៩៧៧។

**កំណត់ចំណាំ៖ អត្ថបទចម្លើយសារភាពខាងលើសង្ខេបចេញពីឯកសារJ00771។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយរបស់ កែន ឆាំ ហៅ សិត ពិតឬយ៉ាងណានោះទេ។**

# ខាំ នឿន ៖ ពិការជើងដោយសារជាន់មីន

**មេក វិន**



ខាំ នឿន ភេទប្រុស អាយុ៦៣ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (មេក វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខាំ នឿនភេទប្រុស អាយុ៦៣ឆ្នាំមានស្រុកកំណើតនៅភូមិទ័ពស្វាយ ឃុំជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប។ នឿនបច្ចុប្បន្នរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ នឿន បាននិយាយរៀបរាប់ពីដំណើរនៃការតស៊ូ និងទុក្ខលំបាករបស់ខ្លួនក្នុងសម័យខ្មែរក្រហម ដូចខាងក្រោម៖

កាលពីកុមារភាព ខ្ញុំរស់នៅក្នុងគ្រួសារមួយដែលមានជីវភាពមធ្យម។ ខ្ញុំគឺជាក្មេងប្រុសម្នាក់ដែលរៀនបានតិចតួចជាងគេ ក្នុងចំណោមក្មេងៗនៅក្នុងភូមិ។ ដោយសារតែឪពុកម្តាយ របស់ខ្ញុំមានវ័យចំណាស់ ថែមទាំងមានកូនប្រុសតែ ២នាក់ទៀត ទើបខ្ញុំសម្រេចចិត្តឈប់រៀនដើម្បីជួយធ្វើការសម្រាលបន្ទុកគ្រួសារ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ បានកើតមានឡើង។ ក្រោយមកក៏មានការទម្លាក់គ្រាប់បែក និងធុងសាំង ក្នុងស្រុកអង្គរធំ ខេត្តសៀមរាប ដែលបានធ្វើឲ្យឆាបឆេះផ្ទះប្រជាជនអស់ជាច្រើនខ្នង។ ចំណែកខ្មែរក្រហមបានជម្លៀសប្រជាជនមួយចំនួនតូចឲ្យទៅនៅខាងស្រុកវ៉ារិន។ ចំណែកឯគ្រួសាររបស់ខ្ញុំ និងប្រជាជនដែលនៅសេសសល់ដទៃទៀត មិនត្រូវបានជម្លៀសចេញពីភូមិកំណើតទេ។

នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានសម្លាប់បងប្រុសរបស់ខ្ញុំ ដោយចោទប្រកាន់ថា គឺជាជនក្បត់ដែលបម្រុងរត់ចូលទៅខាង លន់ នល់។ ខ្ញុំត្រូវបានខ្មែរក្រហមចាប់បង្ខំឲ្យចូលធ្វើជាកងទ័ពដើម្បីវាយប្រយុទ្ធជាមួយទាហាន លន់ នល់។ កាលណោះ ខ្ញុំទើបមានអាយុ ១៣ ឬ ១៤ ឆ្នាំតែប៉ុណ្ណោះ។

រហូតដល់ឆ្នាំ១៩៧៤ ខ្ញុំបានសម្រេចចិត្តរត់ចេញពីជួរកងទ័ព ហើយគេចខ្លួនទៅនៅស្រុកកំណើតវិញ។ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅលើកទំនប់ម្កាក់ ដែលស្ថិតនៅក្នុងខេត្តសៀមរាប។ របបអាហារមានភាពប្រសើរជាងពេលនៅជាកងទ័ព។ ខ្ញុំរួមទាំងប្រជាជនជាច្រើននាក់ទៀត បានរស់នៅទីនោះរហូតលើកទំនប់ម្កាក់ហើយរួចរាល់។

នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហម ទទួលបានជ័យជម្នះទាំងស្រុង។ នៅពេលបានដឹងពីព័ត៌មាននេះ ខ្ញុំនិងប្រជាជនដទៃទៀតពិតជាមានចិត្តសប្បាយរីករាយយ៉ាងខ្លាំង មិនតែប៉ុណ្ណោះ ថែមទាំងនាំគ្នាស្រែកហ៊ោថា «ប្រទេសជាតិយើងទទួលបានឯករាជ្យ» ទៀតផង។ ខ្ញុំបានត្រឡប់មកនៅភូមិកំណើតវិញ ហើយត្រូវបានខ្មែរក្រហមជ្រើសរើសខ្ញុំចូលធ្វើជាយោធានៅខាងស្រុកវ៉ារិនរហូតដល់ឆ្នាំ១៩៧៦។

នៅក្នុងឆ្នាំដដែល មេកងពលរបស់ខ្ញុំត្រូវបានខ្មែរក្រហមចោទថាជាជនក្បត់ និងត្រូវបានសម្លាប់ចោល។ កងពលរបស់ខ្ញុំក៏ត្រូវបានរំសាយ។ ខ្ញុំរួមទាំងកងកម្លាំងជាច្រើននាក់ផ្សេងទៀតដែលបានជាប់និន្នាការក្បត់ ត្រូវបានបញ្ជូនទៅក្នុងកងចល័តពិសេស។ ខ្ញុំត្រូវវែកដី នឹងលើកទំនប់នៅខាងគោកស្រុក ក្នុងស្រុកវ៉ារិន ខេត្តសៀមរាប។ អង្គការនឹងយកខ្ញុំទៅសម្លាប់ចោល ប្រសិនបើក្រុមរបស់ខ្ញុំដែលមានសមាជិក៣នាក់ មិនអាចលើកដីដែលមានទំហំ៣ម៉ែត្របួនជ្រុងកម្ពស់១ម៉ែត្រ ក្នុងរយៈពេល ១ថ្ងៃ ឲ្យហើយរួចរាល់។ ខ្ញុំទទួលបានរបបអាហារអង្ករមួយកំប៉ុងសម្រាប់មនុស្សបីនាក់ក្នុងមួយថ្ងៃៗ។

ពេលរដូវវស្សាចូលមកដល់ ខ្មែរក្រហមបានបញ្ជូនខ្ញុំឲ្យទៅដកស្ទូងស្រូវវិញ។ ប្រធានកងចល័តបានហៅកម្លាំង

ប្រជាជនទាំងអស់ឲ្យមកជួបជុំគ្នា និងប្រាប់ឲ្យឈរជា ៤ជួរ។ នៅពេលដែលយើងឮសំឡេងស្រែករាប់ ១, ២, ៣ យើងត្រូវរត់ចុះទៅក្នុងស្រែដែលមានសំណាប។ ឈ្លបបានជិះសេះ និងម៉ូតូ ដើម្បីដេញវាយអ្នកណាដែលរត់មិនទាន់គេ ឬអ្នកណាដែលធ្វើការយឺតយ៉ាវ។ លើសពីនេះទៅទៀតប្រសិនបើមានអ្នកណារត់គេច ឬដើរចេញពីជួរ ឈ្លបនឹងតាមចាប់យកមកវិញ។ បន្ទាប់ពីចាប់ខ្លួនបានហើយ ឈ្លបបញ្ជាឲ្យជីករណ្តៅខ្លួនឯង ។ បន្ទាប់មក ឈ្លបសម្លាប់អ្នកនោះ ដោយទម្លាក់ចូលក្នុងរណ្តៅ។ នៅសម័យនោះ ខ្មែរក្រហមមិនអាណិតអាសូរប្រជាជនឡើយ។ ប្រជាជនណាដែលមិនគោរពតាមបញ្ជារបស់ខ្មែរក្រហម គឺ ខ្មែរក្រហមសម្លាប់ចោល សូម្បីតែឪពុកម្តាយ និងបងប្អូនរបស់ខ្លួនក៏ដោយ។ ចំពោះរបបអាហារវិញ មួយថ្ងៃ ប្រជាជនទទួលបានអង្ករមួយកំប៉ុងហូបសម្រាប់មនុស្ស ២៥នាក់។ នៅតាមផ្លូវ នៅពេលយើងឃើញសម្បកដំឡូងមី យើងតែងតែនាំគ្នាលួចរើសយកមកស្ងោរហូបបន្ថែម។ ក្រុមខ្ញុំមានគ្នាចំនួន ១២នាក់ តែងតែបំពេញការងារគ្រប់ចំនួនកំណត់របស់ខ្មែរក្រហមជានិច្ច។

នៅចន្លោះឆ្នាំ១៩៧៨ និងឆ្នាំ១៩៧៩ គឺរយៈពេលដែលខ្ញុំជួបការលំបាក និងវេទនាបំផុត។ បន្ទាប់ពីខ្ញុំលើកទំនប់នៅខាងគោកស្រុក រួចខ្មែរក្រហមបានបញ្ជូនមកឲ្យលើកទំនប់នៅភូមិចាន់រុនវិញ។ ខ្ញុំលើកទំនប់រហូតដល់ចុងឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមកដល់។ ខ្ញុំរួមទាំងប្រជាជនដែលនៅលើកទំនប់ជាច្រើននាក់បានរត់ទៅស្រុកកំណើតវិញ។ នៅពេលធ្វើដំណើរទៅដល់ផ្ទះ សភាពការណ៍នៅក្នុងភូមិរបស់ខ្ញុំកំពុងតែចលាចល ព្រោះមានកងទ័ពវៀតណាមបានចូលមកដល់ដែរ។ ខ្ញុំមិនអាចបែងចែកថាតើនរណាជាប្រជាជន ហើយនរណាជាកងទ័ពវៀតណាមទេ។

នៅឆ្នាំ១៩៨០ កងទ័ពវៀតណាមបានចាប់ប្រជាជនក្នុងភូមិដើម្បីសួរចម្លើយ និងធ្វើទារុណកម្មដោយច្រកថង់។ កងទ័ពវៀតណាមបានវាយធ្វើបាបប្រជាជនខ្មែរដែលរត់ទៅនៅតាមដុបតាមព្រៃជារៀងរាល់ថ្ងៃ។ ចំណែកស្រីៗមួយចំនួនក៏ត្រូវបានកងទ័ពវៀតណាមចាប់រំលោភដែរ។

នៅឆ្នាំ១៩៨២ ឪពុកម្តាយរបស់ខ្ញុំបានស្លាប់ចោលខ្ញុំ ដោយសារតែជំងឺប្រចាំកាយ។ ក្រោយមក ខ្ញុំបានរៀបការ តែត្រូវកងទ័ពវៀតណាមចូលមកហាមឃាត់ ឃើញដូច្នេះ ឪពុកក្មេករបស់ខ្ញុំបានកាប់ជ្រូកមួយ ហើយបានចែកឲ្យកងទ័ពវៀតណាមពាក់កណ្តាល ហើយនៅសេសសល់ទុកសម្រាប់ធ្វើម្ហូបទទួលភ្ញៀវ។ ក្រោយពីរៀបការរួច ខ្ញុំនិងគ្រួសារបន្តរស់នៅក្នុងភូមិទ័ពស្វាយដដែល ។ បន្ទាប់មក ប្រជាជននៅក្នុងភូមិបានបោះឆ្នោតឲ្យខ្ញុំធ្វើជានគរបាលភូមិ។ រយៈពេល៤ខែក្រោយមក ក៏មានការបោះឆ្នោតម្តងទៀត។ ខ្ញុំក៏បានជាប់ទាំងនគរបាលឃុំ និងយោធាឃុំ និងបន្តធ្វើការរហូតដល់ឆ្នាំ១៩៨៨។

នៅក្នុងឆ្នាំ១៩៨២ដដែល ខ្មែរក្រហមក៏បានចូលមកក្នុងស្រុកអង្គរធំ ហើយបានចាប់ខ្ញុំ មេភូមិ មេឃុំ រួមទាំងប្រជាជនដទៃទៀត រួចបញ្ជូនទៅភ្នំដងរែក។ តាម៉ុក បានបញ្ជូនមនុស្សដែលខ្មែរក្រហមចាប់ខ្លួនបានទាំងអស់ឲ្យទៅដឹកជញ្ជូនគ្រាប់ក្នុងទឹកដីថៃ ដោយធ្វើដំណើរតាមច្រកភ្នំស្រួច នឹង ច្រកវ៉ាល ខានពុំបាន។ ការធ្វើដំណើរឡើងតាមច្រកទាំងពីរនេះ ជួបប្រទះការលំបាកយ៉ាងខ្លាំង។ យើងត្រូវតោងវល្លិ៍ ដើមឈើ ឬតោងថ្ម ដើម្បីឡើងទៅខាងលើ។ គ្រាប់ដែលយើងត្រូវដឹកជញ្ជូនពីដីថៃមកដីខ្មែរមានដូចជា គ្រាប់បេ មីនតោន៍ និងគ្រាប់អាការជាដើម។ មនុស្សម្នាក់ត្រូវកាន់គ្រាប់អាការចំនួន៥០០គ្រាប់ មីន១០គ្រាប់ និងគ្រាប់បេចំនួនមួយគ្រាប់។ មិនតែប៉ុណ្ណោះ យើងត្រូវស្ពាយអង្ករ ទឹក និងស្បៀងអាហារសម្រាប់ហូបនៅតាមផ្លូវ។ ក្រោយពីខ្ញុំដឹកជញ្ជូនគ្រាប់រួចហើយ ខ្មែរក្រហមបានអនុញ្ញាតឲ្យខ្ញុំត្រឡប់មកផ្ទះវិញ ហើយខ្ញុំបន្តកាន់មុខតំណែងជានគរបាលឃុំ និងយោធាឃុំដដែល។ ថ្ងៃមួយ ខ្ញុំបានជួបគ្រោះថ្នាក់ចរាចរណ៍ និងឈឺរ៉ាំរ៉ៃ។

នៅក្នុងកំឡុងឆ្នាំ១៩៩៣ ខ្មែរក្រហមបានចូលមកក្នុងភូមិខ្ញុំម្តងទៀត។ កាលណោះខ្ញុំចាំបានថា ខ្ញុំកំពុងតែដេកឈឺនៅក្រោមផ្ទះ។ កងកម្លាំងរបស់ខ្មែរក្រហមបានដើរមកឃើញខ្ញុំកំពុងតែដេកឈឺ គ្រូពេទ្យរបស់ខ្មែរក្រហមក៏បានយកឡានមកដឹកខ្ញុំទៅព្យាបាលនៅអន្លង់វែង។ មួយរយៈក្រោយមក ខ្ញុំមានកម្លាំងមាំមួន និងបានជាសះស្បើយវិញ។ ខ្ញុំបន្តរស់នៅជាមួយខ្មែរក្រហមរហូតដល់ឆ្នាំ១៩៩៧។ ខ្ញុំបានសម្រេចចិត្តទៅយកប្រពន្ធនិងកូនរបស់ខ្ញុំពីស្រុកកំណើតមករស់នៅស្រុកអន្លង់វែងវិញ។

មួយឆ្នាំក្រោយមក ខ្ញុំត្រូវពិការជើងដោយសារមីន ក្នុងពេលដែលខ្ញុំធ្វើដំណើរឡើងលើភ្នំដងរែកដើម្បីទៅទទួលប្រជាជនមកពីជំរំកូណយ ហើយភ្លាមៗនោះគ្រូពេទ្យបានសម្រេចចិត្តកាត់ជើងរបស់ខ្ញុំនៅក្នុងព្រៃតែម្តង។ មួយរយៈក្រោយមក កម្លាំងខ្មែរក្រហមនៅអន្លង់វែងបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល ហើយខ្ញុំនិងប្រពន្ធព្រមទាំងកូនរបស់ខ្ញុំ បានចុះពីលើភ្នំមករស់នៅក្នុងភូមិអូរគគីរក្រោមរហូតដល់បច្ចុប្បន្ន។

# ខ្ញុំឈឺគ្រុនចាញ់

## ពឹង ឧស្សាហ៍



រូបថតនេះ ថតនាចុងឆ្នាំ១៩៧៤ ពេលទៅលេងចម្ការនៅវាលទ្រា ខេត្តបាត់ដំបង។ រូបពីឆ្វេងទៅស្តាំ: ប៉ារបស់ខ្ញុំ វេជ្ជបណ្ឌិត ពឹង គិមស៊ា, បងប្រុស ពឹង កម្លាំង, បងប្រុស ពឹង សាកល, បងប្រុស ពឹង កុសល និងខ្ញុំ ពឹង ឧស្សាហ៍។ នៅក្នុងចំណោមអ្នកនៅក្នុងរូបនេះមានតែ ខ្ញុំនិងបង កុសល ទេដែលបានរួចរស់ពីរបប ប៉ុល ពត។ ឪពុករបស់ខ្ញុំបានស្លាប់ នៅទួលស្លែង នៅខែមេសា ឆ្នាំ១៩៧៧។

នៅដើមខែកុម្ភៈ ឆ្នាំ១៩៧៦ ខ្ញុំឈឺគ្រុនចាញ់ជាលើកទីពីរ តែលើកនេះធ្ងន់ធ្ងរជាងកាលឈឺនៅមោងឫស្សី ពីព្រោះខ្ញុំទើបនឹងបានស្បើយពីជំងឺគ្រុនចាញ់មិនបានបីខែផង ហើយយើងខ្វះម្ហូបត្រីសាច់ថែមទៀត ម្យ៉ាងទៀតយើងមិនមានថ្នាំសង្កូវគ្រប់គ្រាន់។ ខ្ញុំអាយុជាង៨ឆ្នាំ ស្គមស្គាំង ហើយគ្មានកម្លាំងកំហែងសោះ។ ខ្ញុំដើរចង់ពន្ទំជើង ហើយពេលងើបឈរម្តងៗងងឹតមុខឈឺង ទាល់តែតោងជញ្ជាំងមួយស្របក់ទើបអាចដើរបាន។

ខ្ញុំឈឺគ្រុនចាញ់ញាក់គ្មានលោះថ្ងៃឡើយ ហើយពេលគ្រុនម្តងៗ រណ្តំថ្កាមរងាររញាក់ អន្ទ្រូនខ្លួនប្រាណសឹងតែប្រកាច់ៗ ប៉ាឱបខ្ញុំស្រក់ទឹកភ្នែករាល់ដង ចំណែកម្តាយខ្ញុំចិត្តទន់មិនអាចយកភ្នែកមើលបាន តែងតែងើបទៅកូរម្សៅឈូកដែលនៅសល់បន្តិចបន្តួច ដាក់លាយស្ករទុកឲ្យខ្ញុំញ៉ាំពេលខ្ញុំឈប់ញាក់។ មិនដឹងថាប៉ាដែលជាវេជ្ជបណ្ឌិតមួយរូបសោកសង្រេងយ៉ាងណាទេ ពេលឃើញកូនស្រីធ្លាក់នៅក្នុងសភាពបែបនេះ។ ជួនកាលខ្ញុំញាក់ខ្លាំងដល់ភាំងស្មារតីក៏មាន ពេលដឹងខ្លួនឡើងឃើញបងៗនៅរឹតប្រឹបាច់ឲ្យខ្ញុំពេញខ្លួន ហើយជួនកាលទៀតខ្ញុំឮសំឡេងប៉ាលើយៗហៅខ្ញុំឲ្យភ្ញាក់មកវិញ។

បន្ទាប់ពីខ្ញុំរងាររញាក់រួច ដល់ពេលក្តៅខ្លួនម្តងៗ ម្តាយខ្ញុំតែងដងទឹកទុកក្នុងផ្ទះឲ្យត្រជាក់សម្រាប់ជ្រលក់ក្រមាស្អំក្បាលឲ្យខ្ញុំ ព្រោះខ្ញុំឡើងកម្តៅខ្លាំង និងឈឺក្បាលដូចជាគេដំ ហើយថែមល្វីងមាត់វិលមុខទន់ខ្លួននិយាយសឹងតែមិនចេញ។ ម្តាយរបស់ខ្ញុំខំបញ្ចុកទឹកម្សៅឈូក ដែលជាធម្មតាខ្ញុំចូលចិត្តណាស់ តែពេលនោះប្រែជាល្វីងខះ ប៉ុន្តែត្រូវប្រឹងលេបទាំងបង្ខំ។ ពេលសីតុណ្ហភាពចុះ ខ្ញុំក៏បានធូរស្បើយប្រហែលពីរថ្ងៃ ហើយទទួលរងកម្មពីជំងឺដដែលនេះសារជាថ្មី។ ពេលនោះ ប៉ានិងបងៗត្រូវបានខ្មែរក្រហមចាត់តាំងឲ្យចេញទៅធ្វើពលកម្មរាល់ថ្ងៃ ចំណែកខ្ញុំមានជំងឺត្រូវនៅផ្ទះម្នាក់ឯង។

ជំងឺគ្រុនចាញ់នោះធ្វើឲ្យខ្ញុំញាក់ទៀងទាត់ពេលសឹងថាដាក់នាឡិកាផ្ទៀងម៉ោងទុកមុនបាន ហើយធម្មតាខុសតែ១ ឬ២ម៉ោង ប៉ុណ្ណោះ ដូច្នេះឪពុកម្តាយនិងបងៗ របស់ខ្ញុំបណ្តាក់គ្នាមកមើលថែខ្ញុំពេលគ្រុនញាក់ ប៉ុន្តែមានម្តងនោះខ្ញុំញាក់ខុសម៉ោង អត់មានអ្នកណានៅជិតខ្ញុំទេ។ ខ្ញុំរងារខ្លាំងណាស់ ខ្ញុំដណ្តប់ភួយយ៉ាងណាក៏នៅតែរងារ

រណ្ដំផ្កាម សើងរង្គើធ្មេញជ្រុះអស់ ខ្ញុំគិតថា ប្រសិនបើមានភ្នក់ភ្លើងនៅជិត ខ្ញុំចង់លោតចូលអង្គុយក្នុងភ្លើងកម្ដៅខ្លួន។ ថ្ងៃនោះមេឃក្ដៅណាស់ គឺចំពេលថ្ងៃត្រង់បណ្ដើរកូនព្រិចៗ ខ្ញុំវារអូសទាំងភួយ ទៅអង្គុយហាលថ្ងៃម្នាក់ឯងនៅទីទួលកណ្ដាលផ្លូវ ព្រោះមុខផ្ទះនៅមានម្លប់ដើមឈើ ប៉ុន្តែខ្ញុំអង្គុយមិនហ្នឹងនក៏ក្រាបគ្រលំភួយលើដី។ មិនដឹងថា ខ្ញុំក្រាបហាលថ្ងៃយូរប៉ុណ្ណាទេ ប៉ុន្តែខ្ញុំចាំច្បាស់ដូចម្សិលមិញ ឃើញប៉ាជិះកង់មកយ៉ាងលឿន ហើយផ្ដួលកង់ចោលព្រួសរត់មកលើកខ្ញុំ។ ប៉ាខ្ញុំស្គម ព្រោះយើងខ្វះបាយញ៉ាំ ហើយជើងរបស់ប៉ាកើតជំងឺរលាកសន្លាក់មិនទាន់ជាស្រួលបួលផង ប៉ុន្តែប៉ាបីខ្ញុំរត់ចូលក្នុងផ្ទះទាំងទឹកភ្នែក។ តាមពិត ពេលប៉ាមកដល់ខ្ញុំផុតញាក់ហើយ ចូលដល់ដំណាក់កាលទីពីរនៃជំងឺនោះ គឺក្ដៅខ្លួនខ្លាំង ប៉ុន្តែខ្ញុំងើបដើរចូលផ្ទះមិនរួច។ ប៉ាដាក់ខ្ញុំគេងលើក្ដាររួចទាញភួយពីខ្លួន និងដោះអាវខ្ញុំដែលប្រឡាក់សុទ្ធតែដីចេញ ហើយយកកន្សែងជ្រលក់ទឹកជូតមុខ ជូតខ្លួនឲ្យខ្ញុំ ដើម្បីបញ្ចុះសីតុណ្ហភាព ព្រោះខ្ញុំក្ដៅខ្លួនខ្លាំង។ ប៉ាឲ្យថ្នាំ គីនីន កន្លះគ្រាប់មកខ្ញុំផឹក ខ្ញុំស្អប់ថ្នាំនេះណាស់ ព្រោះវាមហាសែនល្វីង ហើយឆាប់រលាយក្នុងមាត់មុនពេលខ្ញុំអាចលេបចូលពោះ។

វេទនាពេក ខ្ញុំយំប្រាប់ប៉ាថា បើរស់ពិបាកយ៉ាងនេះខ្ញុំចង់ស្លាប់វិញល្អជាង។ ប៉ាចាប់ខ្ញុំឱបយ៉ាងណែន ហើយប្រាប់ខ្ញុំទាំងក្ដុកក្ដួលថា ប៉ាស្រឡាញ់កូនជាងជីវិតរបស់ប៉ា ប៉ាសុខចិត្តវះថ្លើមប្រមាត់ប៉ាប្ដូរឲ្យកូនជា។ កូនស្ដាប់ប៉ា ហើយត្រូវចាំឲ្យច្បាស់ថាកូនត្រូវតស៊ូដើម្បីរស់ ព្រោះកូននៅមានអនាគតវែងឆ្ងាយ គង់មានថ្ងៃមួយកូនបានទៅជួបបងនៅអាមេរិក បានរៀនសូត្រ បានសប្បាយ។ កូនសន្យាជាមួយប៉ាថា កូនមិនគិតនិងមិននិយាយពាក្យអស់សង្ឃឹមនេះទៀតទេ។ ខ្ញុំស្លុតចិត្តហើយសន្យាជាមួយប៉ាទាំងទឹកភ្នែក។ ខ្ញុំរក្សាសន្យានេះជូនប៉ាបាន ខ្ញុំតស៊ូក្នុងជីវិតកំព្រាក្រោយពេលប៉ាត្រូវខ្មែរក្រហមសម្លាប់។

ខ្ញុំប្រឈមមុខពុះពារដើម្បីបានរៀនសូត្រ ជឿជាក់លើខ្លួនឯងនូវការសម្រេចចិត្តជ្រើសរើសគូស្រករ សាងគ្រួសារមួយក្នុងសង្គមដ៏ល្អ និងចិញ្ចឹមចិត្តសង្ឃឹមជានិច្ចថា ប៉ាគង់ពេញចិត្តនឹងជីវិតដ៏សាមញ្ញរបស់កូនស្រីកំព្រារបស់លោក។

**ពឹង ឧស្សាហ៍**

រដ្ឋ អូរីហ្គែន សហរដ្ឋអាមេរិក

ខែកញ្ញា ឆ្នាំ២០១៨



រូបថតរបស់នាងខ្ញុំ ពឹង ឧស្សាហ៍។

# ឈាង ជួ ៖ វរសេនាតូច១២០ កងពលទី១

ផាន់ អូន



ឈាង ជួ អាយុ៦៩ឆ្នាំ សព្វថ្ងៃរស់នៅឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (សុខ វណ្ណៈ៖មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឈាង ជួ ភេទប្រុស អាយុ៦៩ឆ្នាំ។ ខ្ញុំរស់នៅឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំមានស្រុកកំណើតនៅឃុំព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែង។ ឪពុកខ្ញុំឈ្មោះ ហេង ឈាង និងម្ដាយឈ្មោះ អ៊ុង ហ៊ាន។ ឪពុកខ្ញុំបានស្លាប់មុនម្ដាយរបស់ខ្ញុំ ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤នាក់ គឺស្រី១នាក់និង ប្រុស៣នាក់។ ខ្ញុំគឺជាកូនច្បងនៅក្នុងគ្រួសារ ។

កាលពីក្មេងខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ នៅសាលាជ្រៃ។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៦២ ខ្ញុំបានឈប់រៀនមកជួយធ្វើស្រែម្ដាយ និងឃ្វាលគោក្របីបន្ទាប់ពីឪពុករបស់ខ្ញុំបានស្លាប់។ ម្យ៉ាងទៀតម្ដាយរបស់ខ្ញុំគ្មានប្រាក់ផ្គត់ផ្គង់ឲ្យខ្ញុំរៀនគ្រប់គ្រាន់។ ក្រោយមកនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បានកើតមានរដ្ឋប្រហារទម្លាក់ សម្ដេចព្រះនរោត្តម សីហនុ ចេញពីតំណែង។ កាលនោះស្រុកទេសមានសភាពជ្រួលច្របល់។ សម្ដេចព្រះ នរោត្តម សីហនុ ព្រះអង្គគង់នៅទីក្រុងប៉េកាំង បានអំពាវនាវឲ្យកូនចៅចូលព្រៃម៉ាគីធ្វើការតស៊ូប្រឆាំងនឹងរបប លន់ នល់ យកអំណាចឲ្យព្រះអង្គវិញ។ កាលនោះ ខ្ញុំ ម្ដាយខ្ញុំ និងបងប្អូនចំនួន ៣នាក់ទៀត មករស់នៅម្ដុំតាំងក្រង់ ឃុំស្វាយទាប ស្រុកចំការលើដោយប្រកបរបរធ្វើស្រែចម្ការ។ ក្រោយមក ខ្ញុំនិងយុវជនក្នុងភូមិប្រមាណជា ១០០នាក់ទៀតបានចូលព្រៃតស៊ូជាមួយវៀតកុង (វៀតណាមខាងជើង)។ កាលនោះ កងទ័ពវៀតកុងជាច្រើននាក់បានចូលមកដីខ្មែរជាពិសេសនៅតាមជនបទ។ កងទ័ពវៀតកុងមួយចំនួនទៀតបានឆ្លងកាត់ទៅដល់ខេត្តកំពង់ឆ្នាំង ហើយខ្ញុំក៏បានទៅតាមកងទ័ពវៀតកុងទាំងនោះដែរ។

បន្ទាប់មកអ្នកតស៊ូខ្មែរក៏បានស្នើសុំកងទ័ពវៀតកុងផ្ទេរអ្នកតស៊ូខ្មែរមកអង្គភាពខ្មែរគ្រប់គ្រងវិញ។ ដូច្នេះខ្ញុំបានផ្លាស់មកអង្គភាពទ័ពខ្មែរ។ ដំបូងអង្គភាពយើងមិនទាន់បានរៀបជាកងពលធំទេ។ នៅរវាងពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ ទើបមានការរៀបចំប្រមូលកងវរសេនាតូច ហើយបង្កើតទៅជាកងពលទី១ ដែលមានកងទ័ពប្រមាណជា៥០០០ ទៅដល់១០០០០នាក់ ដែលមាន ពេទ្យ សឿង ប៉ុ តាសឿង គឺជាប្រធានកងពល និង តាសាន គឺជាអនុកងពល។ ខ្ញុំនៅកងវរសេនាតូចលេខ ១២០ មានគ្នាចំនួនប្រមាណជា៣០០នាក់។ អង្គភាពរបស់ខ្ញុំឈរជើងចាប់ពីគគីរ កំពង់ហ្លួង ឧដុង្គ រហូតដល់ស្ពានសេដ្ឋា កៀកក្រុងភ្នំពេញ និងត្រូវចល័តសារចុះឡើងនៅសមរភូមិ។

ក្រោយជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងពលទី១ ត្រូវបានផ្លាស់មកឈរជើងនៅលង្វែកទាំងអស់ ហើយកងកម្លាំងមួយចំនួនត្រូវបានបំបែក និងបញ្ចូលទៅកងទ័ពអាកាសលេខ ៥០២ ដែលដឹកនាំដោយឈ្មោះ ស៊ូ ម៉េត។ កាលនោះកងពលខ្ញុំមិនបានកាត់ចូលក្នុងទ័ព

អាកាសទេ ព្រោះអង្គការបានកំណត់យកត្រឹមវរសេនាធំប៉ុណ្ណោះ។ ដោយសារកងកម្លាំងខ្លះត្រូវបានដកទៅកងទ័ពអាកាស ដូច្នេះកងកម្លាំងរបស់កងពលទី១ ត្រូវការកងកម្លាំងបន្ថែម ក៏ជ្រើសយកកម្លាំងមកពីស្រុកខ្លះ តំបន់ខ្លះបានចំនួន៣វរសេនាធំគឺ ២ វរសេនាធំបោះទីតាំងនៅលង្វែក និង១វរសេនាធំបោះទីតាំងនៅខេត្តកោះកុង។

ខ្ញុំឈរជើងនៅលង្វែករហូតដល់ឆ្នាំ១៩៧៧ អង្គការបានដកខ្ញុំ និងកម្លាំងនៅក្នុងកងពលឲ្យទៅឈរជើងនៅខេត្តក្រចេះ នៅពេលដែលខ្មែរក្រហមចាប់ផ្តើមមានជម្លោះជាមួយវៀតណាមនៅតាមព្រំដែន។ នៅពេលនោះក៏មានការដកកម្លាំងមួយចំនួនចេញពីកងវរសេនាធំរបស់ភូមិភាគបស្ចិមខ្លះដែលឈរជើងនៅតំបន់៣១ កំពង់ឆ្នាំង, តំបន់៣២ កំពង់ឆ្នាំងខាងត្បូង, តំបន់១១ កោះកុង និង តំបន់៣៧ កំពង់សិលា ហើយបានបង្កើតទៅជាកងពល១១៧ និងបានក្លាយជាកងពលមជ្ឈិមបន្ទាប់មក។ កងពល១១៧ ត្រូវបានបំពាក់អាវុធ ដើម្បីវាយតទល់នឹងកងទ័ពវៀតណាម ដែលមានទំនាស់នៅតាមព្រំដែន ស្នួល មេមត់ និងមណ្ឌលគិរី ។ កងពល១១៧ មានប្រធានកងពលឈ្មោះ រ៉ុំ និងឈ្មោះ លៀង គឺជាអនុប្រធាន។ កងពល១១៧ បានរួមគ្នាជាមួយកម្លាំងនៅតំបន់ក្រចេះ៥០៥ ដែលកាលនោះគ្រប់គ្រងដោយគណៈតំបន់ឈ្មោះ យី គួន បោះទីតាំងនៅស្រុកស្នួល ។

កាលនោះខ្មែរក្រហម និងវៀតណាមមានជម្លោះគ្នាដោយប្រជាជនខ្មែរស្នូងស្រូវ ហើយកងទ័ពវៀតណាមបានចូលមកដកសន្ទូង។ នៅពេលនោះក៏មានការបរចាគ្នា ដោយខាងវៀតណាម ព្រមព្រៀងឈប់មកដកសន្ទូងរបស់ប្រជាជន ប៉ុន្តែកងទ័ពវៀតមិនបានអនុវត្តទេ ហើយជួនកាលបានលបបាញ់ទៀត។ កងវរសេនាតូចខ្ញុំឈរជើងចាប់ពីផ្លូវជាតិលេខ ១៣ រហូតដល់ព្រំប្រទល់ប្រទេសវៀតណាម។ នៅពេលមានសង្គ្រាមកើតឡើងកងកម្លាំងរបស់ខ្ញុំបានចុះខ្សោយ ហើយដោយសារកម្លាំងយោធាខ្មែរក្រហមមិនអាចទប់ទល់បាន ក៏ដកថយវិញ។ ជួនកាលកងយោធាខ្មែរក្រហមបានវាយចូលដល់ក្រទូត ក្នុងទឹកដីវៀតណាម ប៉ុន្តែខ្ញុំមិនបានឃើញប្រជាជន ឬចាប់បានប្រជាជនទេ ព្រោះប្រជាជនវៀតណាម ត្រូវបានជម្លៀសចេញមុនពេលដែលកម្លាំងរបស់ខ្ញុំបានចូលទៅដល់។ ចំណែកកងទ័ពវៀតណាមវាយចូលមកដីខ្មែរ ក៏ចាប់ប្រជាជនខ្មែរមិនបានដែរ ព្រោះខ្មែរក្រហមបានជម្លៀសប្រជាជនចេញដែរ។ នៅពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រវៀតណាម វាយចូលមកដល់ស្ពាយជ្រះស្ថិតនៅក្នុងស្រុកស្នួល នៅដើមឆ្នាំ១៩៧៩ ខ្ញុំ និងយោធាខ្មែរក្រហមនៅទីនោះក៏បានរត់គេចខ្លួនដោយទុកចោលទីស្នាក់ការ។

ខ្ញុំនិងកងទ័ពមួយចំនួន បានចាកចេញពីស្រុកស្នួលដោយឆ្លងទន្លេព្រែកប្រសព្វ មកភូមិតាំងរេន ខេត្តកំពង់ធំ បន្ទាប់មកខ្ញុំធ្វើដំណើរកាត់តាមផ្លូវជាតិលេខ ៦ មកកំពង់ឆ្នាំងវិញ ។ មានប្រជាជនជាច្រើនបានត្រឡប់មកភូមិកំណើតវិញ ហើយដោយសារខ្ញុំគិតថាគ្មានសុវត្ថិភាព ទើបខ្ញុំធ្វើដំណើរសំដៅមកតាមជួរភ្នំដងរែក រហូតមកដល់ប្រាសាទតាមាន់។

ចាប់តាំងពេលនោះមក ខ្ញុំបានដាច់ទំនាក់ទំនងជាមួយប្រពន្ធរបស់ខ្ញុំ។ ប្រពន្ធទី១ របស់ខ្ញុំឈ្មោះ អែម គឺជាពេទ្យប្រចាំការនៅលង្វែក។ យើងបានរៀបការនៅក្នុងឆ្នាំ១៩៧៥។ ក្រោយពីរៀបការបានមួយរយៈ ខ្ញុំបានផ្លាស់ទៅឈរជើងនៅកោះកុង ចំណែកប្រពន្ធខ្ញុំនៅលង្វែកដដែល។ យើងមិនសូវបាននៅជិតគ្នាទេ ព្រោះយើងមានតួនាទីរៀងៗខ្លួន។ នៅដើមឆ្នាំ១៩៧៩ នៅពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងទ័ពស្ម័គ្រចិត្តវៀតណាម វាយចូលមកនិងមានភាពច្របូកច្របល់យើងបានបែកគ្នារហូត។ ខ្ញុំបានដើររកប្រពន្ធខ្ញុំតាមព្រំដែន ប៉ុន្តែរកមិនឃើញ ខ្ញុំក៏សម្រេចចិត្តឈប់ដើររកគាត់ទៀត (ទើបតែនៅអំឡុងឆ្នាំ ២០១០ ខ្ញុំបានទទួលដំណឹងថាប្រពន្ធខ្ញុំមានគ្រួសារថ្មី ហើយគាត់បានស្លាប់)។

នៅក្នុងឆ្នាំ១៩៨១ ខ្ញុំបានជួបនារីម្នាក់ឈ្មោះ អ៊ុច នៀង នៅពេលរត់ទៅព្រំដែន ហើយខ្ញុំបានរៀបការលើកទី ២។ ខ្ញុំមានកូនចំនួន៣នាក់ ស្រី១នាក់ និងប្រុស២នាក់។

នៅអំឡុងឆ្នាំ១៩៨២ ខ្ញុំបានមករស់នៅសំឡូត។ ក្រោយមក ខ្ញុំមករស់នៅជាមួយ តាម៉ែត ម៉ុំអូររថក្រោះ។ នៅក្នុងឆ្នាំ១៩៩៦ ខ្ញុំបានផ្លាស់មកនៅស្រុកវាលវែង ដោយខ្មែរក្រហមបានរៀបចំកងពលថ្មីទៀត។ ក្រោយពេលធ្វើសមាហរណកម្ម ខ្ញុំបានចូលបម្រើការនៅមន្ទីរធម្មការ នៅឆ្នាំ១៩៩៩។

នៅក្នុងឆ្នាំ២០០៦ ខ្ញុំចូលនិវត្តន៍ ចំណែកប្រពន្ធខ្ញុំបានប្រកបមុខរបរធ្វើស្រែ ហើយគាត់បានចូលធ្វើការងារស្ម័គ្រចិត្តជាមួយកាកបាទក្រហមនៅស្រុកវាលវែង។

# ជីវិតថ្លៃ

## សួត វិចិត្រ

នាង ដៃ ភេទស្រី អាយុ៦២ឆ្នាំ មានទីកន្លែងកំណើតនៅភូមិក្រាំងផ្តៅ ឃុំសឹង ស្រុកសំរោង ខេត្តតាកែវ។ បច្ចុប្បន្ននេះ ដៃ គឺជាគ្រូបង្រៀនម្នាក់នៅសាលាមត្តេយ្យសិក្សាសហគមន៍ដែលស្ថិតនៅភូមិទួលសាលា ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ដៃ បានរៀបរាប់ពីបទពិសោធន៍ជីវិតផ្ទាល់ខ្លួន ដូចខាងក្រោមថា ៖

នៅឆ្នាំ១៩៧៣ ភូមិរបស់ខ្ញុំទទួលរងនូវភាពប្រទាញប្រទង់គ្នាយ៉ាងខ្លាំង រវាងកងទ័ពរំដោះរបស់ខ្មែរក្រហម និងទាហាន លន់ នល់។ អំឡុងពេលនោះ ប្រជាជននៅក្នុងភូមិទទួលរងនូវការគំរាមកំហែងយ៉ាងខ្លាំងដោយសារការបាញ់ប្រោះ និងការទម្លាក់គ្រាប់បែកនៅជាយៗភូមិ។ គ្រានោះ គ្រួសាររបស់ខ្ញុំបានបន្តរស់នៅក្នុងភូមិ និងតែងតែចូលទៅលាក់ខ្លួនក្នុងលេណដ្ឋាន ដោយសារការទម្លាក់គ្រាប់បែករបស់ទាហាន លន់ នល់ កាន់តែច្រើនឡើង។

នៅចុងឆ្នាំ១៩៧៤ ឃុំសឹង នៃខេត្តតាកែវ បានប្រែទៅជាតំបន់រំដោះរបស់ខ្មែរក្រហម។ ពេលនោះ ខ្ញុំ និងប្រជាជននៅក្នុងភូមិ ត្រូវបានខ្មែរក្រហមស្នើឲ្យទៅធ្វើការនៅក្នុងរោងសិប្បកម្មតម្បាញ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ វ៉ុធ គឺជាប្រធានកងអង្គភាពនារី។ កិច្ចការប្រចាំថ្ងៃរបស់យើង គឺត្រូវចងធ្មេញឈើសម្រាប់បម្រើដល់ការងារតម្បាញ។ ក្រោយមក រោងសិប្បកម្មតម្បាញត្រូវបានបោះបង់ចោល បន្ទាប់ពីកងកម្លាំងរបស់យើងត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែនៅតំបន់ថ្នល់ទទឹង នៃខេត្តតាកែវ។

នៅក្នុងខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបញ្ជូនខ្ញុំ និងកងកម្លាំងនារីៗបួននាក់ផ្សេងទៀត នៅក្នុងកងអង្គភាពឲ្យធ្វើដំណើរតាមរថភ្លើងពីក្នុងស្រុកបាទី ទៅកាន់ទីក្រុងភ្នំពេញ។ យើងបានធ្វើដំណើរអស់រយៈពេលពេញមួយយប់ទើបទៅដល់គោលដៅ។ ខ្មែរក្រហមបានអនុញ្ញាតឲ្យយើងសម្រាកនៅទីក្រុងភ្នំពេញមួយ



នាង ដៃ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមប្រាប់ដល់ សួត វិចិត្រ អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

យប់ទៀត មុនពេលបញ្ជូនយើងទៅកាន់ខេត្តក្រចេះ។ យើងបានធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញនៅវេលាថ្ងៃរសៀល តាមកប៉ាល់ដឹកអង្កររបស់ខ្មែរក្រហម ដែលបើកបញ្ច្រាសចរន្តទឹកនៃដងទន្លេមេគង្គនារដូវទឹកស្រក។ ទិដ្ឋភាពតាមច្រាំងទន្លេនៅពេលនោះ គឺមានសភាពស្ងប់ស្ងាត់ណាស់។ មនុស្សម្នាក់ៗបានជួបនូវការលំបាកយ៉ាងខ្លាំងដោយសារការអត់ងងុយ និងការភ័យខ្លាច។ ខ្មែរក្រហមបានផ្តល់នំប៉័ងដល់យើងម្នាក់មួយដើម ដើម្បីបរិភោគមុនពេលទៅដល់គោលដៅ។ អស់រយៈពេលប្រមាណជាពីរថ្ងៃ ទើបយើងធ្វើដំណើរទៅដល់ឃុំរការកណ្តាល នៃខេត្តក្រចេះ។ យើងបានរស់នៅទីនោះអស់រយៈពេលបីខែ ជាមួយនឹងប្រជាជនដែលមកពីតំបន់ផ្សេងៗគ្នា ដូចជា ប្រជាជនមកពីខេត្តតាកែវ, កំពង់ស្ពឺ និងសៀមរាប។ ថាន គឺជាប្រធានអង្គភាពនារីដែលគ្រប់គ្រងនៅទីនោះ។ ថាន បានចាត់តាំងខ្ញុំឲ្យកត់ប្រវត្តិរូបប្រជាជនដែលរស់នៅក្នុងអង្គភាពរបស់ខ្លួន ដែលនៅ

ពេលនោះ ខ្ញុំបានផ្តោតសំខាន់តែទៅលើឈ្មោះ និងទីកន្លែងកំណើតរបស់ប្រជាជនទាំងនោះប៉ុណ្ណោះ។

ក្រោយមក ប្រធានអង្គភាពរបស់ខ្ញុំបានដកកម្លាំងមួយចំនួន រួមទាំងខ្ញុំម្នាក់ដែរ ទៅកាន់តំបន់អក ៤ លើ នៃខេត្តមណ្ឌលគិរី។ នៅទីនោះ យើងរស់នៅក្រោមការគ្រប់គ្រងរបស់ប្រធានកងពល ៩២០ ដែលមាន មៀច សាន ហៅ តា០៦ ជាប្រធាន ។ កងកម្លាំងនៅទីនោះ គឺត្រូវបានបែងចែកជាពីរ រួមមាន កម្លាំងប្រជាជនចាស់ និងកម្លាំងប្រជាជនថ្មី។ កងកម្លាំងប្រជាជនចាស់ មានតួនាទីក្តោបក្តាប់កម្លាំងប្រជាជនថ្មី និងចេញទៅប្រយុទ្ធនៅសមរភូមិមុខជាប្រចាំ។ ចំណែកឯកងកម្លាំងប្រជាជនថ្មីវិញ គឺត្រូវធ្វើការនៅសមរភូមិ ក្រោយដោយត្រូវសាងសង់ជម្រកស្នាក់នៅ, ឃ្លាំងដាក់អង្ករ និងលើកភ្លឺស្រែនៅពាក់កណ្តាលអន្រ្លាត្រ។ នៅគ្រានោះ យើងបានជួបការនឿយហត់យ៉ាងខ្លាំង ប៉ុន្តែមិនបានជួបប្រទះនឹងការអត់ឃ្លានទេ។

ក្រោយមក ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅធ្វើការនៅក្រោមការគ្រប់គ្រងរបស់គណៈតំបន់វិញ ដែលមានទីតាំងស្ថិតនៅក្នុងខេត្តមណ្ឌលគិរីដដែល។ ការងារនៅទីនោះ គឺខ្មែរក្រហមបានបញ្ជាឲ្យខ្ញុំលើកទំនប់ជាមួយក្រុមជនជាតិដើមភាគតិច។ យើងបានប្រើប្រាស់ភាសាខ្មែរ ដើម្បីទំនាក់ទំនងគ្នា។ ក្រុមជនជាតិដើមភាគតិចទាំងនោះ តែងតែគោរព និងស្រឡាញ់យើង នៅពេលដែលយើងធ្វើការងាររួមគ្នានៅក្នុងកងអង្គភាពតែមួយ។

រហូតដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមបានរៀបចំឲ្យខ្ញុំមានគូស្រករ នៅក្នុងចំណោមប្រជាជនប្រមាណ១០គូផ្សេងទៀត។ ពេលនោះ អង្គភាពមិនមានការរៀបចំពិធីអ្វីធំដុំនោះទេ ដោយបានឲ្យយើងប្តេជ្ញាចិត្ត និងស្មោះស្ម័គ្រជាមួយអង្គភាព។ បន្ទាប់ពីរៀបការរួចហើយ ខ្ញុំមិនបានរស់នៅជួបជុំជាមួយប្តីរបស់ខ្ញុំយូរទេ ដោយខ្មែរក្រហមត្រូវបញ្ជូនគាត់ទៅវែកដីនៅក្នុងការដ្ឋានមួយកន្លែងស្ថិតក្នុងខេត្តមណ្ឌលគិរី។

នៅក្នុងឆ្នាំ១៩៧៩ កងទ័ពវៀតណាម បានវាយចូលមកក្នុងប្រទេសកម្ពុជា។ ពេលនោះ ខ្ញុំទទួលបានដំណឹងថា ប្តីរបស់ខ្ញុំត្រូវគល់ឈើសង្កត់ ហើយធ្លាក់ខ្លួនពិការ។ ភ្លាមៗនោះ ខ្ញុំមិនបានទៅមើលថែទាំគាត់ទេ ដោយសារប្រធានអង្គភាពរបស់ខ្ញុំតម្រូវឲ្យកម្លាំងនៅក្នុងអង្គភាពខ្ញុំរត់ចូលព្រៃដើម្បីគេចខ្លួនពីការវាយប្រហាររបស់កងទ័ពវៀតណាម។

ក្រោយមក ខ្ញុំបានទទួលដំណឹងម្តងទៀតថា ប្តីខ្ញុំបានស្លាប់បាត់បង់ជីវិតនៅក្នុងអំឡុងពេលសង្រ្គាម។ រយៈពេលរស់នៅក្នុងព្រៃ យើងបានជួបប្រទះនូវការលំបាក ដោយសារពុំមានស្បៀងអាហារហូបចុកគ្រប់គ្រាន់។ នៅពេលយើងធ្វើដំណើរទៅដល់កន្លែងណាមួយ យើងតែងដឹកនាំកម្លាំងរកជីកដំឡូងព្រៃ ប្រមើមក្តួច ដើម្បីធ្វើជាអាហារ។

រហូតដល់ឆ្នាំ១៩៨០ ខ្មែរក្រហមបានបញ្ជូនយើងទៅកាន់តំបន់បេងកោង នៃភូមិភាគបូព៌ា។ ខ្ញុំបានរៀបការជាមួយប្តីទីពីររបស់ខ្ញុំនៅទីនោះ ដែលមានតួនាទីជានីរសាររបស់ថ្នាក់លើ ខ្មែរក្រហម ក្នុងអង្គភាព៩២០។ យើងបានរស់នៅក្នុងភូមិភាគបូព៌ាអស់រយៈពេលមួយឆ្នាំ ក្រោយមកទើបប្រធានអង្គភាពរបស់ខ្ញុំ បានដឹកនាំកម្លាំងទាំងអស់ក្រោមការគ្រប់គ្រងរបស់គាត់ធ្វើដំណើរទៅកាន់ច្រក ១០០១ ដែលស្ថិតក្នុងខេត្តព្រះវិហារ។ យើងបានធ្វើដំណើរយ៉ាងលំបាកអស់រយៈពេលជាច្រើនខែទម្រាំទៅដល់ទីនោះ។

ក្រោយពេលទៅដល់តំបន់១០០១ ខ្មែរក្រហមបានរៀបចំឲ្យកងកម្លាំងនារីៗដែលមានគ្រួសារ ហើយកាប់ឆ្ការព្រៃបង្កបង្កើនផល និងចម្អិនអាហារសម្រាប់កងអង្គភាពខ្មែរក្រហម។ ចំណែកឯបុរសៗ និងនារីៗមួយចំនួនដែលនៅលីវត្រូវធ្វើជាកងដឹកជញ្ជូនទៅសមរភូមិមុខខាងក្នុងប្រទេស។

រហូតដល់ឆ្នាំ១៩៨៤ កងកម្លាំងនៅក្នុងតំបន់១០០១ ត្រូវបានជម្លៀសទៅកាន់ជំរំជងទង់ និងស៊ីងចាន់ នៃប្រទេសថៃ តាមរយៈខ្សានដឹកជញ្ជូនរបស់ខ្មែរក្រហម។

លុះនៅឆ្នាំ១៩៩០ ខ្មែរក្រហមបានបញ្ជូនយើងទៅកាន់តំបន់ ១០០៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ឈិត ជឿន ហៅ តាម៉ុក នៅទីនោះ។ ក្រោយមក យើងក៏បានរត់ភៀសខ្លួនចំនួនពីរទៅបីលើកទៀត នៅពេលមានការប្រយុទ្ធគ្នារវាងកងកម្លាំងខ្មែរក្រហម និងទាហានរាជរដ្ឋាភិបាលកម្ពុជា។ យើងបានចុះមករស់នៅជាអចិន្ត្រៃយ៍នៅតំបន់អន្លង់វែង ក្រោយពេលកងកម្លាំងតស៊ូខ្មែរក្រហមបានទម្លាក់អាវុធ ហើយធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅដើមឆ្នាំ១៩៩៩។

# នួន ហុងលីម៖ ការចងចាំអំពីជីវិតក្នុងរបបខ្មែរក្រហម

ស៊ាង ចិន្តា

លោកតា នួន ហុងលីម មានជំនាញធ្វើនំប៉័ង និងជាអ្នករស់រានមានជីវិតមួយរូបពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ លោកតា បានចែករំលែកអំពីសាវតាររបស់ខ្លួន ក៏ដូចជារំឭកអំពីដំណើរជីវិតរបស់ខ្លួន មុនពេល និងក្នុងរបបនេះ ជាពិសេស នូវព្រឹត្តការណ៍ដែលលោកតាចាំមិនភ្លេច ដូចជាការជម្លៀស ចេញពីភូមិស្រុក និងការរៀបការក្នុងសម័យខ្មែរក្រហមជាដើម។

លោកតា លីម កើតនៅឆ្នាំ១៩៥៥ ក្នុងគ្រួសារកសិករនៅភូមិកោះថ្មី ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ លោកតា មានបងប្អូនប្រុសស្រីចំនួន ១១រូប ប៉ុន្តែបានបាត់បង់ជីវិតមួយចំនួន។ លោកតា បានរៀនដល់ថ្នាក់ទី ៧ ចាស់ នៅសាលាបឋមសិក្សាភ្នំតាងិល ដែលស្ថិតនៅឆ្ងាយពីភូមិកំណើតរបស់ខ្លួន។ ដោយសារតែជីវភាពក្រីក្រ លោកតា បានបោះបង់ការសិក្សាត្រឹមថ្នាក់ទី៧ នៅអាយុ១៨ឆ្នាំ និងបានរៀនធ្វើនំប៉័ងលក់។ លោកតា បានដុតនំប៉័ង និងតែងតែដឹកយកមកលក់នៅទីរួមខេត្តកំពង់ចាម។ នាថ្ងៃមួយក្នុងឆ្នាំ១៩៦៩ លោកតា បានយកនំប៉័ងមកលក់ និងបានឃើញការធ្វើ ឃាតកម្មនៅទន្លេអុំ។ លោកតា ពិតជាភ័យតក់ស្លុតចំពោះព្រឹត្តិការណ៍ដែលបានឃើញនេះ។ បន្ទាប់ពីមានរដ្ឋប្រហាររបស់ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងវិបត្តិសង្គ្រាម ស៊ីវិលរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម។

ទោះបីជាស្ថិតក្នុងគ្រាផ្ទុះឡើងសង្គ្រាមស៊ីវិលយ៉ាងណាក៏ដោយ លោកតា លីម នៅតែបន្តធ្វើនំប៉័ង និងលក់ដាច់ដូចធម្មតា ជាពិសេស មានឈ្មួញកណ្ដាល ដែលបានទទួលទិញនំប៉័ងលក់បន្តនៅតាមចំណតឡានឈ្នួល។ រហូតដល់ឆ្នាំ១៩៧២ កងទ័ពខ្មែរក្រហមបានចូល មកដល់



លោកតា នួន ហុងលីម សព្វថ្ងៃរស់នៅភូមិកោះថ្មី ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ភូមិរបស់លោកតា។ លោកតា និង គ្រួសារ ត្រូវបានខ្មែរក្រហមជម្លៀសចេញពីផ្ទះ ទៅកាន់ភូមិដីហែ ដែលស្ថិតនៅក្នុងតំបន់រំដោះរបស់ខ្មែរក្រហម។ លោកតា ត្រូវបានខ្មែរក្រហមដាក់ឲ្យនៅធ្វើការក្នុងកងចល័តយុវជន ដែលត្រូវធ្វើការភ្ជួររាស់ និងដាំដំណាំ រួមមាន ដំឡូង និងបន្លែ។

សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម បានផ្ទុះកាន់តែខ្លាំងឡើង ទាំងតាមផ្លូវគោក និងតាមបណ្ដោយទន្លេមេគង្គ។ លោកតា បានឲ្យដឹងបន្ថែមថា «នាវាទាហានម៉ារីន លន់ នល់ តែងតែធ្វើដំណើរតាមបណ្ដោយទន្លេមេគង្គ ដើម្បីដឹកស្បៀង និងសម្ភារសឹកផ្សេងៗពីភ្នំពេញ ទៅកាន់ទីរួមខេត្តកំពង់ចាម ហើយកងទ័ពខ្មែរក្រហម បានលបវាយឆ្មក់ជាញឹកញាប់» ។

នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកតា លីម ត្រូវបានចល័តមកកាន់ភូមិកោះថ្មីវិញ។ នៅចុងឆ្នាំ១៩៧៥ លោកតា ត្រូវបានអង្គការឲ្យរៀបការជាមួយមិត្តនារី យ៉ាង ស៊ីម៉ាន់។ លោកតា បានរំឭកថា «ខ្ញុំមិនដែលបានជួបមុខប្រពន្ធខ្ញុំពីមុនមកទេ ពីព្រោះអង្គការបានរៀបចំឲ្យការ។ ក្នុងថ្ងៃរៀបការនោះ គឺមានទាំងអស់ចំនួន ១០គូ ។ ខ្ញុំមិនហ៊ាននិយាយអ្វីនោះទេ ក្រៅតែពីពាក្យប្ដេជ្ញាចំពោះអង្គការ និងហូបអីបន្តិច រួចហើយត្រឡប់ទៅផ្ទះវិញ»។

នៅចុងឆ្នាំ១៩៧៦ លោកតា លីម និងភរិយា ទទួលបានកូនប្រុសមួយ។ លោកតា ត្រូវបានបញ្ជូនចេញទៅឆ្ងាយពីគ្រួសារ ទៅកងចល័តសហករណ៍ដែលមានសមាជិកប្រហែល១០០នាក់ ដើម្បីធ្វើការនៅតាមការដ្ឋានផ្សេងៗ។ លោកតា លីម បានលើកឡើងថា «ខ្ញុំក្រោកធ្វើការពីម៉ោង៥ទៀបភ្លឺ ទៅភ្ជួររាស់ ស្ទូងស្រូវ ដាំដំឡូង និងដឹកកាយដីប្រឡាយជាដើម។ ខ្ញុំមិនសូវបានជួបមុខប្រពន្ធកូនទេ ពីព្រោះខ្ញុំត្រូវបានបញ្ជូនទៅចល័តធ្វើការ ពីកន្លែងមួយទៅកន្លែងមួយ» ។ នៅក្នុងខែភ្ជុំ អង្គការបានរៀបចំពេលវេលាធ្វើការ គឺចាប់ពីម៉ោង១ យប់ រហូតដល់ម៉ោង១២ថ្ងៃត្រង់ និងចាប់ពីម៉ោង១ថ្ងៃត្រង់ រហូតដល់ម៉ោង៦ល្ងាច ទើបបានសម្រាក។ លោកតា បានបន្តថា «ខ្ញុំត្រូវធ្វើការភ្ជួររាស់ដី និងលើកទំនប់ចាប់ពីម៉ោង ១ យប់ ដល់ម៉ោង៦ល្ងាច។ ខ្ញុំពិតជាមិនដឹងថា នេះគឺជាផែនការរបស់ខ្មែរក្រហមអីទេ ទាំងថ្ងៃទាំងយប់។ ក្នុងយប់មួយពេលកំពុងភ្ជួររាស់ដីដាំដំឡូង ខ្ញុំរមួលពោះឃ្លានបំពង់។ គិតដល់ត្រឹមនេះ គឺអស់រយៈពេលជាច្រើនឆ្នាំហើយ ដែលខ្ញុំមិនបានហូបនំបុ័ង។ ខ្ញុំនៅចាំបានថា ខ្ញុំក្រោកនៅម៉ោង៤ទៀបភ្លឺដើម្បីធ្វើនំបុ័ង ប៉ុន្តែក្នុងរបបខ្មែរក្រហម ខ្ញុំក្រោក



ផ្លូវលំទៅផ្ទះលោកតា នួន ហុងលីម នៅភូមិកោះថ្មី ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្ដា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្ទះរបស់លោកតា នួន ហុងលីម នៅភូមិកោះថ្មី ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (ស៊ាង ចិន្ដា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅម៉ោង១យប់ គឺត្រឹមតែធ្វើការភ្ជួររាស់ដីដោយបង្ខំតាមបញ្ជារបស់ខ្មែរក្រហម» ។ លោកតា បានធ្វើការនៅក្នុងកងចល័ត រហូតដល់កងទ័ពខ្មែរក្រហមភូមិភាគនិរតីបានមកដល់ភូមិកោះថ្មី នៅក្នុងឆ្នាំ១៩៧៨។ កងទ័ពខ្មែរក្រហមភូមិភាគនិរតី បានចាប់ផ្តើមចាប់កម្មាភិបាលខ្មែរក្រហមភូមិភាគបូព៌ាយកទៅសម្លាប់ចោលជាបន្តបន្ទាប់។ ចាប់តាំងពីពេលនោះមក ការធ្វើការហួសកម្លាំង ការវាយធ្វើបាប ការបង្អត់អាហារ និងការសម្លាប់ គឺកើតមានកាន់តែច្រើនឡើង។ នៅដើមឆ្នាំ១៩៧៩ លោកតា លីម និងគ្រួសារបានរួចផុតជីវិតពីរបបខ្មែរក្រហម និងបានបន្តអាជីពធ្វើនំបុ័ងលក់រហូតដល់ឆ្នាំ១៩៩៦។ លោកតា លីម នៅតែមានការចងចាំយ៉ាងល្អអំពីរឿងរ៉ាវជីវិត និងបទពិសោធន៍ ការដាំដំឡូង និងបន្លែផ្សេងៗក្នុងរបបខ្មែរក្រហម ដើម្បីចែករំលែកដល់កូនចៅ និងក្មេងៗ ជំនាន់ក្រោយឲ្យដឹងអំពីប្រវត្តិសាស្ត្រនេះ។

គួររំឭកផងដែរថា «ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហម» នៅខេត្តកំពង់ចាម មានដាក់បង្ហាញអំពីពិព័រណ៍ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សានុសិស្ស គរុសិស្ស លោកគ្រូ/អ្នកគ្រូ អ្នករស់រានមានជីវិត អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទូទៅ ដើម្បីស្វែងយល់បន្ថែមទៅលើប្រវត្តិសាស្ត្រខ្មែរក្រហម។ នៅក្នុងផ្ទាំងនីមួយៗ មានការរចនានូវស្លឹកដំឡូងមី ដែលបានបង្កប់អត្ថន័យការធ្វើពលកម្ម និងការរួចផុតពីការអត់ឃ្លានក្នុងរបបខ្មែរក្រហម។



ផ្ទាំងពិព័រណ៍នៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហម ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)




ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហមខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



សៀវភៅសម្រាប់សាធារណជន អាននៅការិយាល័យស្រាវជ្រាវ និងបណ្ណាល័យខ្មែរក្រហម ខេត្តកំពង់ចាម។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ភាពឈឺចាប់ក្រោយរបបប៉ុលពតដួលរលំ

ហ៊ាន ពិសី



ភោគ ឡាង អាយុ៥៨ បច្ចុប្បន្នរស់ភូមិទួលស្វាយថ្មី ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ភោគ ឡាង ភេទស្រី អាយុ៥៨ មានទីកន្លែងកំណើតនៅភូមិព្រៃពោន ឃុំព្រៃពោន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ឡាង បច្ចុប្បន្នរស់ភូមិទួលស្វាយថ្មី ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ឡាង បានចែករំលែកបទពិសោធន៍ជីវិតរបស់ខ្លួនដូចខាងក្រោមថា៖

ខ្ញុំគឺជាកូនស្រីម្នាក់ក្នុងចំណោមបងប្អូន ១០នាក់ នៃគ្រួសារកសិករ នៅក្នុងខេត្តព្រៃវែង។ ឪពុករបស់ខ្ញុំឈ្មោះ ភោគ ញាក់ និងម្តាយរបស់ខ្ញុំឈ្មោះ ហុនគឿន។ ដោយសារតែជីវភាពគ្រួសារ លំបាក ខ្ញុំបានឈប់រៀននៅត្រឹមថ្នាក់ទីមួយ។ នៅក្នុងឆ្នាំ១៩៧០ ខ្ញុំមានអាយុប្រហែល ១០ឆ្នាំ។ ខ្ញុំនៅចាំបានថា នៅក្នុងភូមិរបស់ខ្ញុំមានការទម្លាក់គ្រាប់បែកជាច្រើនពីសំណាក់កងទ័ពវៀតណាមខាងត្បូង ឬធីវគី ជាហេតុធ្វើឲ្យប្រជាជនត្រូវរត់ភៀសខ្លួនទៅរស់នៅក្នុងវត្ត។ នៅអំឡុងពេលនោះ កងទ័ពវៀតណាមតែងតែចាប់បង្ខំប្រជាជនយកទៅទាំងគ្មានមូលហេតុ ជាពិសេសនារីក្រមុំៗ។ ក្រោយមក កងទ័ពវៀតណាម បានមកត្រួតពិនិត្យផ្ទះរបស់ខ្ញុំ ព្រោះសង្ស័យថាឪពុករបស់ខ្ញុំលាក់កូនក្រមុំ។ បងស្រីរបស់ខ្ញុំ ដោយខ្លាចវៀតណាមធ្វើបាប គាត់បានយកធ្យូងគូមុខមាត់ និងព្យាយាមកុហកកងទ័ពវៀតណាមថា ខ្ញុំគឺជាកូនស្រីរបស់គាត់។ ប៉ុន្តែកងទ័ពវៀតណាមពុំបានជឿបងស្រីរបស់ខ្ញុំឡើយ ហើយនៅតែចាប់បង្ខំបងស្រីរបស់ខ្ញុំយកទៅដដែល។ ឪពុករបស់ខ្ញុំក៏បានចូលទៅរារាំងកងទ័ពវៀតណាម ដែលបម្រុងនឹងនាំខ្លួនបងស្រីខ្ញុំយកទៅ។ ជាហេតុធ្វើឲ្យកងទ័ពវៀតណាមខឹង និងបានទាញកាំភ្លើងមកវាយឪពុក និងម្តាយរបស់ខ្ញុំស្ទើរស្លាប់។ ខណៈពេលដែលឪពុកម្តាយរបស់ខ្ញុំកំពុងប្រទាញប្រទង់គ្នាជាមួយកងទ័ពវៀតណាម បងស្រីរបស់ខ្ញុំក៏ឆ្លៀតឱកាសរត់ចូលទៅលាក់ខ្លួនក្នុងព្រៃ ដើម្បីគេចពីការចាប់ខ្លួននោះ។ ហេតុការណ៍នេះពិតជាធ្វើឲ្យខ្ញុំភ័យខ្លាំងណាស់ ប៉ុន្តែខ្ញុំ

មិនអាចជួយឪពុកម្តាយបានឡើយ ក្រៅពីស្រែកយំ។ ការរស់របស់ប្រជាជននៅពេលនោះ មានការលំបាកវេទនាណាស់ និងមិនហ៊ានស្នាក់នៅផ្ទះទេ ព្រោះខ្លាចកងទ័ពវៀតណាមធ្វើបាប។

ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានទទួលបានជ័យជម្នះនៅទីក្រុងភ្នំពេញ។ ខ្មែរក្រហមក៏ចាប់ផ្តើមជម្លៀសគ្រួសារខ្ញុំទៅកាន់ភូមិអំពិល ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ខ្មែរក្រហមបានឲ្យយើងរស់នៅក្នុងផ្ទះមួយដែលមានសមាជិកចំនួនបីគ្រួសារ។ បន្ទាប់មក ខ្មែរក្រហមបានបែងចែកការងារឲ្យយើងធ្វើនៅតាមកងនីមួយៗ ដែលម្តាយរបស់ខ្ញុំធ្វើជាចុងភៅនៅក្នុងរោងបាយ។ ចំណែកឪពុករបស់ខ្ញុំ ខ្មែរក្រហមបានបញ្ជូនឲ្យទៅបិតចម្រូង ហើយពេលយប់ត្រូវប្តូរមកយាមឃ្លាំងអង្ករសហករណ៍វិញ។ រីឯខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើជាប្រធានក្រុមនៅក្នុងកងកុមារនៅជើងរមៀត។ កងកុមាររបស់ខ្ញុំ ខុសប្លែកពីកងកុមារដទៃទៀត ព្រោះកងកុមារជើងរមៀត គឺជាកងដែលមានកុមារមានអាយុចាប់ពី១៥ ឆ្នាំឡើង ដែលជាក្រុមត្រៀមចូលទៅកងចល័ត។ ការងាររបស់យើងគឺកាប់ទន្ទ្រានខែត្រសម្រាប់ធ្វើជី និងដកស្មួងទៅតាមការបញ្ជារបស់ខ្មែរក្រហម។ ចំពោះការហូបចុក យើងទទួលបានបាយ និងបបរឆ្លាស់គ្នាក្នុងមួយសប្តាហ៍ម្តង។ ចំណែកម្ហូបយើងហូបគ្រប់គ្រាន់មិនសូវជួបការខ្វះខាតឡើយ។ កុមារទាំងអស់ត្រូវបានអនុញ្ញាតឲ្យរៀននៅពេលព្រឹក ចាប់ពីម៉ោង៧ ដល់ម៉ោង១១ថ្ងៃត្រង់ ចំណែកពេលថ្ងៃ ចាប់ពីម៉ោង ១ រសៀល ដល់ម៉ោង ៥ ល្ងាច ។ កុមារទាំងអស់ត្រូវចូលធ្វើការជាធម្មតាទៅតាមកងរៀងៗខ្លួន។ ជំនាន់នោះខ្ញុំរៀនចេះចាំបានខ្លះៗដែរ ហើយអាចសរសេរសំបុត្របានថែមទៀតផង។ នៅក្នុងកងកុមារតែងតែមានការប្រជុំទិតៀនអំពីការងារដោយនិយាយកសាងគ្នាទៅវិញទៅមកថានរណាខ្ជិលច្រអូស ឬមិនសូវយកចិត្តទុកដាក់ជាមួយការងារ។ ការប្រជុំទិតៀននេះត្រូវធ្វើឡើងក្នុងមួយសប្តាហ៍ម្តង។ រយៈពេលដែលខ្ញុំរស់នៅក្នុងជំនាន់នោះ អ្វីដែលធ្វើឲ្យគ្រួសារខ្ញុំសោកស្តាយបំផុតនោះគឺ ការស្លាប់បាត់បង់ជីវិតរបស់បងប្អូនប្រុសស្រីរបស់ខ្ញុំចំនួន ៦ នាក់។ ខ្ញុំចាំមិនភ្លេចទេថា បងប្រុសទីមួយរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាប់ចងស្លាបសេកយកទៅសម្លាប់រួមទាំងកូនស្រី និងប្រពន្ធដែលមានផ្ទៃពោះជិតគ្រប់ខែ។ ខ្ញុំបានជួបមុខបងប្រុសជាលើកចុងក្រោយ ដោយខ្ញុំបានរត់ទៅឱបបងប្រុសទាំងទឹកភ្នែក ដោយសារអាណិតបង នៅខណៈពេលដែលខ្មែរក្រហមបណ្តើរគាត់យកទៅសម្លាប់។ បន្ទាប់មក ខ្មែរក្រហមក៏បំបែកខ្ញុំចេញពីបងប្រុស ហើយក៏បន្តយកគាត់ទៅសម្លាប់ រួចទម្លាក់ចូលក្នុងស្រះមួយស្ថិតនៅឆ្ងាយពីស្រុកកំពង់ត្របែក។ ក្រោយមក ម្តាយខ្ញុំបានទទួលដំណឹងថាកូនប្រុសមួយទៀត ត្រូវបានខ្មែរក្រហមធ្វើទារុណកម្មដោយចាត់តាំងឲ្យធ្វើការធ្ងន់គ្មានពេលសម្រាក និងបង្អត់បាយរហូតដល់ស្លាប់។ បន្តមកបងប្រុស ទី៣ ក៏ត្រូវលង់ទឹកទន្លេស្លាប់ទៀត។ ដោយឡែកបងស្រីខ្ញុំបីនាក់ទៀតបានបាត់ខ្លួនដោយមិនដឹងថាស្លាប់ឬរស់នោះទេ។ ខ្ញុំតែងតែស្រក់ទឹកភ្នែក នៅពេលខ្ញុំនឹកឃើញពីទិដ្ឋភាពឈឺចាប់ទាំងនេះ ហើយការចងចាំក៏មិនដែលរលុបចេញពីខួរក្បាលខ្ញុំម្តងណាឡើយ។

លុះឆ្នាំ១៩៧៩ នៅពេលដែលវៀតណាមវាយលុកចូលមកប្រទេសកម្ពុជា គ្រួសាររបស់ខ្ញុំ និងប្រជាជនជាច្រើនគ្រួសារផ្សេងទៀត បានរត់ភៀសខ្លួនចេញពីស្រុកកំពង់ត្របែក ឆ្ពោះទៅខាងលិចទន្លេ គឺនៅម្តុំក្លែងគង់។ ប៉ុន្តែក្នុងពេលធ្វើដំណើរនោះ ប្រជាជនមួយចំនួនក៏បានវិលត្រឡប់ទៅស្រុកកំណើតតាមការអំពាវនាវរបស់រដ្ឋអំណាច ដែលស្នើសុំឲ្យប្រជាជនវិលចូលមាតុភូមិវិញ។ ចំណែកប្រជាជនមួយចំនួនទៀតបានបន្តដំណើរទៅមុខជាមួយខ្មែរក្រហម។ ពេលនោះគ្រួសារខ្ញុំក៏បានវិលត្រឡប់ក្រោយ ព្រោះយើងគិតថា បើបន្តទៅមុខទៀត គឺមានតែសេចក្តីស្លាប់ប៉ុណ្ណោះ។ នៅពេលដែលយើងមករស់នៅក្នុងភូមិកំណើតវិញ ក៏មិនមានភាពស្ងប់សុខប៉ុន្មានដែរ។ កាលណោះ មានពូម្នាក់ធ្លាប់ជាអតីតមេសហករណ៍ ហើយក៏ជាអ្នកដែលបានធ្វើបាបប្រជាជននៅក្នុងភូមិរបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហម ត្រូវបានប្រជាជននៅក្នុងភូមិរួមគ្នាសម្លាប់ចោលទាំង

គ្រួសារគ្មានឲ្យសល់ម្នាក់ឡើយ។ ទាំងនេះ គឺកើតចេញពីការបង្កើតគំនុំបន្ទាប់ពីរបប ប៉ុល ពត ដួលរលំទៅ។

នៅអំឡុងឆ្នាំ១៩៩០ ខ្ញុំបានរៀបការនិងមានកូនស្រីម្នាក់។ លុះកូនស្រីខ្ញុំអាយុបានមួយឆ្នាំ ទើបអ៊ុនគាត់ ចាប់ផ្ដើមចូលមកប្រទេសកម្ពុជា។ មុនពេលបោះឆ្នោតឆ្នាំ១៩៩៣ អ៊ុន គាត់ បានធ្វើការណែនាំក៏ដូចជាជួយលើកទឹកចិត្តប្រជាជនឲ្យចូលរួមចុះឈ្មោះ និងធ្វើប័ណ្ណបោះឆ្នោត។ ខ្ញុំក៏បានចូលរួមចុះឈ្មោះនៅពេលនោះដែរ។ បន្ទាប់មកដោយសារជីវភាពខ្វះខាត ខ្ញុំបានចាកចេញពីស្រុកកំណើតមកតាមប្ដីដើម្បីធ្វើជាកម្មករលីសែងនៅបឹងត្រកួនក្នុងប្រទេសថៃអស់រយៈពេលបីឆ្នាំ។ ក្រោយមកប្រហែលឆ្នាំ២០០៤ យើងបានសម្រេចចិត្តធ្វើដំណើរមករស់នៅអន្លង់វែងតាមរយៈអ្នកស្គាល់គ្នា។ នៅពេលដែលខ្ញុំមកដល់អន្លង់វែង រដ្ឋាភិបាលបានចាប់ផ្ដើមចែកដីធ្លីសម្រាប់ឲ្យប្រជាជនបង្កបង្កើនផល និងរស់នៅគ្រប់ៗគ្នាក្នុងឃុំត្រពាំងតាវ ។ ដូច្នេះ យើងក៏ចាប់ផ្ដើមប្រកបរបរចិញ្ចឹមជីវិត និងបន្តរស់នៅអន្លង់វែងរហូតមកទល់ពេលបច្ចុប្បន្ន។



ភោគ ឡាង ជាមួយកូនប្រុស និងចៅៗ ថតជាមួយ ហ៊ាន ពិសី (រូបនៅខាងឆ្វេង) និង មេក វិន (រូបនៅខាងស្ដាំ) គឺជាក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម៉ក សំអឿនៈ អតីតពេទ្យសហករណ៍

គាត ស្រីឡែន



ម៉ក សំអឿន អាយុ៦០ឆ្នាំ គឺជាជនជាតិភាគស្មៀង រស់នៅភូមិក្តុលផ្សារ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងរបបខ្មែរក្រហម ម៉ក សំអឿន ត្រូវបានកម្មាភិបាលខ្មែរក្រហមបញ្ជូនទៅរៀនវិជ្ជាពេទ្យបឋមនៅមន្ទីរស្រុកត្រមូងតំបន់២១ រយៈពេលប្រហែលមួយខែ បន្ទាប់មក ខ្មែរក្រហមបានចាត់តាំងឲ្យធ្វើពេទ្យប្រចាំនៅសហករណ៍ភូមិកោះថ្ម ឃុំទន្លូង ស្រុកត្រមូង តំបន់ ២១ ភូមិភាគបូព៌ា។ ម៉ក សំអឿនបានរៀបរាប់បទពិសោធន៍ជីវិតដែលបានឆ្លងកាត់សម័យសង្គ្រាម និងរបបខ្មែរក្រហមដូចខាងក្រោម៖

ខ្ញុំឈ្មោះ ម៉ក សំអឿន ភេទប្រុស អាយុ៦០ឆ្នាំ ជនជាតិភាគស្មៀង និងមានស្រុកកំណើតនៅភូមិក្តុលផ្សារ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ ម៉ក កុប និងម្តាយឈ្មោះ ញ៉ឹម សួន។ ខ្ញុំមានបងប្អូនចំនួន ៩នាក់គឺស្រី៦ និងប្រុស ៣ នាក់។ ខ្ញុំមានប្រពន្ធឈ្មោះ ហួត សារឹម យើងមានកូនចំនួន ៦ នាក់ ស្រី៤នាក់ និងប្រុស ២នាក់។ សព្វថ្ងៃខ្ញុំរស់នៅភូមិក្តុលផ្សារ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។

កាលពីខ្ញុំនៅក្មេង ខ្ញុំបានរៀនសូត្រដល់ត្រឹមថ្នាក់ទី ១០ នៅក្នុងសាលាវត្តក្តុល ដែលបច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតជាវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្តុលផ្សារ។ ខ្ញុំបានឈប់រៀន នៅពេលមានបាតុកម្មប្រឆាំងរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅឆ្នាំ ១៩៧០។ នៅពេលនោះ ប្រទេសជាតិមានភាពវឹកវរ ហើយលោកគ្រូ អ្នកគ្រូ មានការភ័យខ្លាច និងឈប់មកបង្រៀននៅសាលាព្រោះលោកគ្រូ អ្នកគ្រូ ភាគច្រើនជាអ្នកមកពីចម្ងាយ។

បន្ទាប់ពីឈប់រៀន ខ្ញុំបានមកនៅផ្ទះ និងជួយការងារឪពុកម្តាយ ដូចជា ធ្វើស្រែចម្ការ និងដាំដំណាំផ្សេងៗ នៅក្នុងភូមិ។ នៅក្នុងឆ្នាំ ១៩៧០ ដដែល ទាហានសហរដ្ឋអាមេរិក និងទាហានធីវគី បានចូលមកនៅក្នុងភូមិរបស់ខ្ញុំ។ ទាហានសហរដ្ឋអាមេរិក បានបោះបន្ទាយនៅក្នុងភូមិពងទឹក និងភូមិកោះថ្ម ក្នុងឃុំទន្លូង ស្រុកមេមត់។ កាលនោះ ខ្ញុំបានឃើញទាហានសហរដ្ឋអាមេរិកមានមាឌធំៗ ទាហានខ្លះមានសម្បុរខ្មៅ និងខ្លះទៀតសម្បុរស។ ទាហានសហរដ្ឋអាមេរិកទាំងនោះបានជិះឡានចូលមកដល់ភូមិ។ នៅ

ខណៈពេលនោះក៏មានកងទ័ពវៀតកុងបានចូលមកដល់ភូមិរបស់ខ្ញុំដែរ។ កងទ័ពវៀតកុង បាននាំគ្នាលាក់ខ្លួននៅពេលឃើញមានវត្តមានទាហានសហរដ្ឋអាមេរិកមកដល់។ នៅពេលនោះ អ្នកភូមិបាននាំគ្នាជួយលាក់ និងយកកងទ័ពវៀតកុងចូលក្នុងលេណដ្ឋាន ពីព្រោះបើទាហានសហរដ្ឋអាមេរិកឃើញ និងមានការទម្លាក់គ្រាប់បែក ដែលនាំឲ្យមានគ្រោះថ្នាក់ដល់អ្នកភូមិជាមិនខាន។ នៅពេលយប់ ខ្ញុំតែងតែឮសូរសំឡេងគ្រាប់កាំភ្លើង ដែលធ្វើឲ្យគ្រួសារខ្ញុំ និងអ្នកភូមិមានការភ័យខ្លាចយ៉ាងខ្លាំង។ កងទ័ពវៀតកុង តែងតែពឹងពាក់ឲ្យអ្នកភូមិជួយរកផ្លូវវាង ដើម្បីងាយស្រួលគេចខ្លួនពីទាហានអាមេរិក។ ទាហានអាមេរិកបានស្នាក់នៅក្នុងភូមិអស់រយៈពេលប្រមាណ ២ ទៅ ៣ខែ ក៏ដកត្រឡប់ទៅវិញអស់។

នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅក្នុងឆ្នាំ ១៩៧៥ ប្រជាជននៅភូមិរបស់ខ្ញុំ ត្រូវបានចាត់តាំងឲ្យធ្វើស្រែចម្ការប្រវាស់ដៃ គឺធ្វើស្រែចម្ការតាមគ្រួសាររៀងៗខ្លួន ប៉ុន្តែត្រូវជួយគ្នាទៅវិញទៅមក។ នៅពេលប្រមូលផលត្រូវយកទៅទុកតាមផ្ទះ និងហូបបាយតាមផ្ទះរៀងៗខ្លួន។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមលែងអនុញ្ញាតឲ្យអ្នកភូមិទាំងអស់ធ្វើស្រែចម្ការប្រវាស់ដៃ និងហូបតាមផ្ទះទៀតហើយ គឺអ្នកភូមិទាំងអស់ត្រូវធ្វើការងាររួម និងហូបរួមនៅតាមសហករណ៍។ អ្នកភូមិក្តុលទាំងអស់មានចំនួនប្រហែលជាង ២០០នាក់ ទាំងចាស់ ទាំងក្មេង ត្រូវមកហូបបាយរួមនៅរោងបាយក្នុងវត្តក្តុល។ ក្រោយពេលហូបបាយរួច អ្នកភូមិត្រូវចេញទៅធ្វើការងារនៅតាមវាលស្រែ ដូចជា លើកភ្លឺស្រែ ដកស្ទូង និងធ្វើចម្ការ ជាដើម។

នៅអំឡុងឆ្នាំ ១៩៧៦ នេះដែរ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅរៀនបច្ចេកទេសពេទ្យបឋមនៅស្រុកត្រមូង តំបន់ ២១ រយៈពេលប្រហែលមួយខែ។ ការរៀនក្បួនពេទ្យនោះ គឺរៀនចាក់ថ្នាំ និងរៀនឲ្យស្គាល់ពីជំងឺគ្រុនក្តៅ ជំងឺគ្រុនញាក់ និងជំងឺផ្សេងៗទៀត។ ចំពោះថ្នាំនៅពេលនោះមានតែថ្នាំអាចម៍ទន្សាយ និងវីតាមីនតិចតួចប៉ុណ្ណោះ។ បន្ទាប់ពីរៀនចប់ ខ្មែរក្រហមបានចាត់តាំងខ្ញុំ ធ្វើពេទ្យ



ឪពុករបស់ ម៉ក សំអឿន ឈ្មោះ ម៉ក កុប នៅក្នុងសម័យសង្គមរាស្ត្រនិយម។ ( ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សហករណ៍ប្រចាំនៅភូមិកោះថ្ម។ នៅក្នុងសហករណ៍ភូមិកោះថ្មនេះ មានពេទ្យតែម្នាក់ប៉ុណ្ណោះ គឺរូបខ្ញុំ។ ចំណែកនៅក្នុងឃុំទន្លូងទាំងមូលមានពេទ្យចំនួន ៤នាក់ សម្រាប់ព្យាបាលអ្នកជំងឺ ។ នៅក្នុងសហរកណ៍ គ្មានកន្លែងសម្រាប់សម្រាកព្យាបាលនោះទេ ពេទ្យត្រូវដើរតាមផ្ទះប្រជាជន ប្រសិនបើមានប្រជាជនមិនស្រួលខ្លួន ឬមានជំងឺ ពេទ្យត្រូវទៅដល់ផ្ទះអ្នកជំងឺ ដើម្បីពិនិត្យមើលថាតើប្រជាជននោះឈឺអ្វីនិងត្រូវចាក់ថ្នាំដែរ ឬក៏អត់។ ប្រជាជននៅក្នុងភូមិ ភាគច្រើនមានជំងឺគ្រុនក្តៅ រាក និងមានសង្វប់ស្ទើររៀងរាល់ថ្ងៃ។ កាលនោះពេទ្យមានថ្នាំតែបន្តិចបន្តួច ដូចជា បេអង វីតាមីនសេដាក់ក្នុងដប់ទឹកក្រូចមីរីនដា។ នៅពេលពេទ្យទៅព្យាបាល

តាមផ្ទះ ពេទ្យត្រូវស្ពាយវីតាមីនសេ ៨ ដប់ សម្រាប់ចាក់ឲ្យអ្នកភូមិៗ នៅពេលនោះក៏មានថ្នាំគ្រាប់ខ្លះដែរ ហើយថ្នាំភាគច្រើនផលិតនៅប្រទេសចិនៗ ពេលមានប្រជាជនឈឺធ្ងន់ ខ្ញុំមិនបានមើលថែអ្នកជំងឺនៅក្នុងសហករណ៍ទេ គឺខ្ញុំបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យនៅស្រុកត្រមូង ព្រោះទីនោះមានគ្រូពេទ្យដែលមានជំនាញខ្ពស់ជាងពេទ្យនៅតាមសហករណ៍ៗ ពេលដែលបញ្ជូនអ្នកជំងឺទៅពេទ្យស្រុក គឺខ្ញុំដឹកអ្នកជំងឺតាមកង់ ឬរទេះៗ ពេលខ្លះអ្នកជំងឺត្រូវបានដាក់ក្នុងអង្រឹង ដោយចងអង្រឹងភ្ជាប់នឹងកង់ និងមានសាច់ញាតិអ្នកជំងឺទៅជាមួយៗ បន្ទាប់មក ខ្ញុំត្រូវត្រឡប់មកសហករណ៍វិញៗ

នៅចុងឆ្នាំ១៩៧៧ ឬ ឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញពីភូមិកោះថ្ម ភូមិក្តុល និងភូមិផ្សេងៗទៀត ក្នុងឃុំទន្លូង ឲ្យមករស់នៅភូមិស្រែតាពិជ និងភូមិកូនក្រពើក្នុងឃុំជាំតាម៉ៅ ពីព្រោះខ្មែរក្រហមបានចាប់ផ្តើមធ្វើសង្គ្រាមតាមព្រំដែន ជាមួយប្រទេសវៀតណាមៗ ចាប់តាំងពីជម្លៀសប្រជាជនចេញពីភូមិក្តុលមកនៅភូមិស្រែតាពិជខ្ញុំលែងធ្វើជាពេទ្យទៀតហើយៗ

នៅឆ្នាំ១៩៧៨ ឪពុករបស់ខ្ញុំត្រូវបានយោធាខ្មែរក្រហមចោទថាក្បត់អង្គការ និងត្រូវបានចាប់ខ្លួននៅភូមិស្រែតាពិជ ពីព្រោះគាត់ធ្លាប់ធ្វើជាមេកងធំគ្រប់គ្រងប្រជាជននៅក្នុងភូមិក្តុលចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ៗ ពេលយោធាខ្មែរក្រហមចាប់ខ្លួនឪពុកខ្ញុំ ខ្មែរក្រហមបានប្រាប់ថា យកគាត់ទៅរៀននៅភូមិខ្លាយ និងភូមិពងទឹក ក្នុងឃុំទន្លូងៗ នៅពេលនោះ ខ្ញុំបានឃើញកងយោធាខ្មែរក្រហមចាប់ឪពុកខ្ញុំចងស្លាបសេកទៅខាងក្រោយ រួមជាមួយប្រធានកងតូច កងធំផ្សេងទៀតៗ ប៉ុន្មានថ្ងៃក្រោយមក ខ្មែរក្រហមបានបញ្ជូនកម្មាភិបាលម្នាក់ទៀតមកធ្វើជាប្រធានកងជំនួសឪពុកខ្ញុំៗ អ្នកភូមិបាននិយាយប្រាប់ថា ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់ហើយ គឺខ្មែរក្រហមបានវាយគាត់ និងវាយប្រធានកងផ្សេងៗទៀតទម្លាក់ចូលទៅក្នុងអណ្តូងទឹកៗ

ខ្ញុំនិងប្រជាជនបានរស់នៅភូមិស្រែតាពិជ និងភូមិកូនក្រពើបានរយៈពេល ៤ ទៅ ៥ខែ ខ្មែរក្រហមបានជម្លៀសយើងឲ្យទៅរស់នៅភូមិរលួស ក្នុងស្រុកស្ទួល ខេត្តក្រចេះវិញៗ រយៈពេលប្រមាណមួយខែក្រោយមក ស្រាប់តែកងទ័ពវៀតណាមបានវាយចូលមក ហើយខ្មែរក្រហមក៏បានជម្លៀសខ្ញុំ និងប្រជាជន បន្តឲ្យទៅរស់នៅភូមិថ្មគ្រែ ក្នុងទីរួមខេត្តក្រចេះៗ ប្រហែលមួយសប្តាហ៍ក្រោយមក ខ្មែរក្រហមបានបញ្ជូនគ្រួសារខ្ញុំតាមកាណូត មកនៅភូមិល្វា ស្រុកចំការលើ ក្នុងខេត្តកំពង់ចាមៗ នៅទីនោះ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យធ្វើការងារនៅក្នុងកងចល័ត និងត្រូវធ្វើការងារពលកម្ម ដូចជា ច្រូតស្រូវ និងនេសាទត្រីៗ

នៅពេលខ្ញុំកំពុងធ្វើការងារច្រូតកាត់ មានឧទ្ធម្ភាគចក្របានហោះមកទាបៗ និងបានប្រកាសឲ្យប្រជាជនត្រឡប់ទៅស្រុកកំណើតវិញៗ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងត្រឡប់មកភូមិក្តុលៗ ពេលមកដល់ភូមិដំបូង ខ្ញុំឃើញនៅសល់តែផ្ទះម្តាយខ្ញុំមួយប៉ុណ្ណោះ ហើយមានព្រៃដុះព័ទ្ធជុំជិតៗ ចំណែកផ្ទះអ្នកភូមិផ្សេងទៀត ត្រូវបានខ្មែរក្រហមរុះរើអស់គ្មានសល់ៗ

ក្រោយមក ខ្ញុំបានចូលធ្វើឈ្លបការពារភូមិ ពីព្រោះនៅមានខ្មែរក្រហមធ្វើសកម្មភាពនៅឡើយៗ ខ្មែរក្រហមបានរស់នៅក្នុងព្រៃជ្រៅ និងធ្លាប់បានចូលមកក្នុងភូមិរបស់ខ្ញុំម្តងម្កាលៗ មានអ្នកភូមិខ្លះបានចូលបម្រើកងទ័ពខ្មែរក្រហម ហើយបានមកធ្វើបាបអ្នកភូមិ និងធ្វើសកម្មភាពប្លន់ចាប់ជំរិត និងសម្លាប់ប្រជាជនៗ ភូមិរបស់ខ្ញុំដំបូងមានឈ្លបចំនួន ១២នាក់ នៅការពារសន្តិសុខៗ ខ្ញុំចូលធ្វើឈ្លបបានរយៈពេល ៣ឆ្នាំ ក៏ផ្លាស់មកធ្វើជាប្រធានភូមិក្តុលវិញៗ បន្ទាប់ពីបោះឆ្នោតអាណត្តិទី ១ នៅក្នុងឆ្នាំ១៩៩៣ ខ្ញុំបានជាប់ជាមេឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាមៗ

# វ៉ាន់ មឿន អតីតយោធា ផ្នែកការពារអាកាស

**ផាត ចាន់សុនិតា**



វ៉ាន់ មឿន មានអាយុ៦៨ឆ្នាំ គឺជាមេឃុំរាមអណ្ដើក បច្ចុប្បន្នរស់នៅភូមិរាមអណ្ដើក ឃុំរាមអណ្ដើក ស្រុកគីរីវង់ ខេត្តតាកែវ។។ (លី កុកឆាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

វ៉ាន់ មឿន មានអាយុ៦៨ឆ្នាំ គឺជាមេឃុំរាមអណ្ដើក ដែលបច្ចុប្បន្នរស់នៅភូមិរាមអណ្ដើក ឃុំរាមអណ្ដើក ស្រុកគីរីវង់ ខេត្តតាកែវ។ តាមរយៈវេទិកាប្រវត្តិសាស្ត្រតាមគ្រួសារ មឿន បានចែករំលែកអំពីបទពិសោធន៍ចូលរួមបដិវត្តន៍ខ្មែរក្រហមរបស់ខ្លួន និងដំណើរជីវិតក្រោយរបបកម្ពុជាប្រជាធិបតេយ្យដល់កូនចៅរបស់គាត់ និងក្រុមការងារវេទិកាប្រវត្តិសាស្ត្រតាមគ្រួសារដូចខាងក្រោមថា ៖

ខ្ញុំគឺជាអតីតទាហានខ្មែរក្រហម ដែលបានចូលរួមក្នុងចលនានេះតាំងពីឆ្នាំ១៩៧៣ មកម្ល៉េះ។ នៅមុនពេលចូលរួមជាមួយខ្មែរក្រហម ខ្ញុំបានរៀនសូត្រត្រឹមថ្នាក់ទី១០ចាស់ នៅឯវត្តពោធិ៍អង្គ។ បន្ទាប់មក ខ្ញុំក៏សម្រេចចិត្តបួសរៀននៅវត្តសុបិន អស់រយៈពេលមួយវស្សា។ នៅឆ្នាំ១៩៧៣ ខ្ញុំបានលាចាកសិក្ខាបទដើម្បីចូលបម្រើចលនាបដិវត្តន៍ខ្មែរក្រហម ក្រោមការអូសទាញពីក្រុមយុវជននៅក្នុងភូមិ។ កាលពីចូលរួមចលនាបដិវត្តន៍ដំបូង ខ្ញុំបានទទួលការហ្វឹកហាត់ក្បួនយុទ្ធសាស្ត្របច្ចេកទេសយោធានៅមន្ទីរ ០៥ ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ អស់ប្រមាណជាងមួយឆ្នាំ។

បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រោយពេលខ្មែរក្រហមទទួលជ័យជម្នះទាំងស្រុង លើកងទ័ពសាធារណរដ្ឋខ្មែរ អង្គការបានចាត់តាំងខ្ញុំឲ្យទៅធ្វើជាយោធាជើងទឹកនៅកំពង់សោម ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត ។ «នៅក្នុងក្រុងកំពង់សោមមិនមានប្រជាជនរស់នៅទេ មានតែយោធាប៉ុណ្ណោះនៅជាយក្រុង ម្តុំកងកេង និងម្តុំរាម ទើបមានប្រជាជនរស់នៅ» ។ បន្ទាប់ពីឈរជើងនៅកំពង់សោមបានមួយរយៈ នៅឆ្នាំ ១៩៧៦ ខ្ញុំត្រូវបានផ្លាស់ឲ្យទៅប្រចាំការនៅលើកោះសេះ និងកោះថ្មី ប្រមាណមួយឆ្នាំដើម្បីការពារដែនសមុទ្រកម្ពុជា។ ដូចគ្នានឹងកំពង់សោមដែរនៅលើកោះគ្មានប្រជាជនរស់នៅទេ គឺមានតែទាហានប្រមាណជាង ១០០នាក់ ចាំការពារ និងយាមល្បាត។

អំឡុងពេលដែលខ្ញុំឈរជើងលើកោះ ខ្ញុំនិងយោធាខ្មែរក្រហមដទៃ តែងបានឃើញកប៉ាល់របស់វៀតណាមមកកៀកនឹងប្រជុំកោះអាចម៍សេះ ដែលមានទីតាំងស្ថិតនៅឈមនឹងកោះសេះ។ រាល់ពេលដែលលេចវត្តមានកងទ័ពវៀតណាមមកក្បែរកោះទាំងនោះ យោធាខ្មែរក្រហមក៏បានបាញ់ផ្ទៀងការពារទីប្រជុំកោះភ្លាមៗ។ ក្រៅពីការពារព្រំដែនសមុទ្ររបស់កម្ពុជា យោធាទាំងអស់ ត្រូវដាំដុះ និងចិញ្ចឹមសត្វដើម្បីទ្រទ្រង់ការរស់នៅ ថ្វីត្បិតតែរបបអាហារហូបចុកមិនមានការខ្វះខាត និងមានការផ្គត់ផ្គង់ដោយអង្គការក្តី។ ទន្ទឹមនឹងនេះ ខ្មែរក្រហមតែងផ្តល់ថ្នាំសង្កូវគ្រប់គ្រាន់ ទៅយោធាយាមល្បាតលើកោះ ព្រោះថា យោធាតែងប្រឈមនឹងជំងឺគ្រុនចាញ់។ ក្រៅពីនេះ ខ្ញុំនិងយោធាផ្សេងទៀត ក៏បានធ្វើដំណើរមកកាន់កំពង់សោម ដើម្បីចូលរួមប្រជុំអប់រំចិត្តគំនិតឲ្យស្មោះត្រង់នឹងអង្គការ។ នៅក្នុងពេលប្រជុំនោះ ខ្ញុំធ្លាប់បានឃើញ តាម៉ុក ចូលរួមដែរ។ នៅពេលដែលខ្ញុំស្នាក់នៅកំពង់សោម ខ្ញុំតែងឃើញមានកប៉ាល់ផ្តាច់មីននាំមុខកប៉ាល់ដឹកទំនិញធំៗ របស់ចិនចូលចតនៅកំពង់ផែកំពង់សោម និងកំពង់ផែរាម។ ទន្ទឹមនឹងនេះ មានមន្ទីរពេទ្យដ៏ធំមួយទំហំប្រមាណជាង ១០ហិកតា ឈ្មោះមន្ទីរពេទ្យចំការដូង ស្ថិតនៅរាម។ ខ្ញុំក៏ធ្លាប់បាននៅសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យនោះមួយរយៈដែរ។

ជីវិតជាយោធានៅលើកោះពិតជាឯកោ ព្រោះខ្ញុំត្រូវរស់នៅទីនោះតែម្នាក់ឯង គ្មានបងប្អូនញាតិសន្តានទេ។ ជារៀងរាល់ល្ងាច នៅពេលដែលខ្ញុំសម្លឹងមើលទៅថ្ងៃរៀបលិច ទឹកភ្នែករបស់ខ្ញុំបានស្រក់ចុះមកដោយក្តីនឹករឭក និងព្រួយបារម្ភពី ឪពុកម្តាយ បងប្អូនដែលនៅស្រុកភូមិ មិនដឹងថា មានរឿងអ្វីកើតឡើងចំពោះគាត់»។ ក្រោយពេលឈរជើងនៅតាមបណ្តាកោះមួយចំនួនបានមួយរយៈ ខ្ញុំក៏ត្រូវបានផ្លាស់មកកោះខកញ៉ាតី ស្ថិតនៅក្បែរទីក្រុងភ្នំពេញវិញ។ មុនពេលប្តូរទៅកាន់កោះខកញ៉ាតី ខ្ញុំត្រូវបានបញ្ជូនទៅអូរបែកក្អម ក្នុងទីក្រុងភ្នំពេញ ដើម្បីហាត់រៀនប្រើកាំភ្លើងធំសម្រាប់ការពារដែនអាកាស ដែលអាចបាញ់ក្នុងរយៈកម្ពស់១៥គីឡូម៉ែត្រ និងរយៈបណ្តោយ៣០គីឡូម៉ែត្រ។

បន្ទាប់ពីហាត់រៀននៅទីនេះបានមួយឆ្នាំ អង្គការបានបញ្ជូនកងពលរបស់ខ្ញុំឲ្យទៅឈរជើងការពារនៅលើកោះខកញ៉ាតី ត្រង់ចំណុចទន្លេបួនមុខ។ នៅលើកោះខកញ៉ាតីមានកាំភ្លើងធំ ៨ដើម នាំចូលពីប្រទេសចិនដែលទំនើបបំផុតនៅសម័យនោះ សម្រាប់បាញ់គ្រាប់ទំហំ ១០០ មីលីម៉ែត្រ។ ខ្ញុំគឺជាអ្នកបញ្ជាបាញ់កាំភ្លើងមួយដើមក្នុងចំណោមកាំភ្លើងទាំងនោះ រហូតដល់មានការវាយចូលមកដល់របស់កងទ័ពស្ម័គ្រចិត្តវៀតណាម នៅដើមខែមករា ឆ្នាំ១៩៧៩។ កាំភ្លើងនេះ គឺជាអាវុធដ៏ទំនើបបំផុតរបស់យោធាខ្មែរក្រហម ដោយប្រើរ៉ាដាស្វ័យប្រវត្តិសម្រាប់ចាប់ទីតាំងរបស់សត្រូវដែលពុំអាចមើលដោយភ្នែកទទេ។ ខ្ញុំ ជឿជាក់ថា ប្រជុំកោះ និងកោះនានា គឺជាទីតាំងយុទ្ធសាស្ត្រការពារប្រទេសជាតិរបស់ខ្មែរក្រហម។

ក្រោយពីអស់សង្ឃឹម ក្នុងការយកឈ្នះលើទ័ពវៀតណាម យោធាខ្មែរក្រហមក៏នាំគ្នារត់ ហើយវៀតណាមបានគ្រប់គ្រងទីក្រុងភ្នំពេញទាំងស្រុង។ ខ្ញុំនិងគ្នីគ្នាបានរត់គេចតាមផ្លូវទៅព្រែកព្នៅ រួចហួសទៅដល់កំពង់ស្ពឺ ហើយចុងក្រោយបានត្រឡប់មកស្រុកកំណើតខ្លួនវិញ។ នៅតាមផ្លូវខ្ញុំប្រយុទ្ធគ្នាជាមួយសត្រូវបណ្តើររត់គេចខ្លួនបណ្តើរ ដោយខ្ញុំត្រូវគ្រាប់ចំដៃផ្នែកខាងឆ្វេង និងរងរបួសជាទម្ងន់ ទម្រាំរត់ទៅដល់លើភ្នំ។ រយៈពេលពីរឆ្នាំដែលខ្ញុំរស់នៅលាក់ខ្លួនក្នុងព្រៃក្រាស់ ខ្ញុំបានដើររកជីកមើមក្តួច និងដំឡូងមកធ្វើជាអាហារប្រចាំថ្ងៃ។

នៅឆ្នាំ១៩៨១ ក្រោយពីខ្ញុំបានទទួលដំណឹងពីប្រជាជនដែលចូលព្រៃកាប់ឈើថា ប្រទេសចាប់ផ្តើមមានសន្តិភាពហើយ ខ្ញុំក៏សម្រេចចិត្តចុះពីលើភ្នំ ដោយធ្វើដំណើរថ្មើរជើងត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំមានកាំភ្លើងអាកាមួយដើម អាកាបត់មួយដើម និងសាកាដូប៉ាវ៉ាមួយ។ ក្រោយពេលធ្វើដំណើររយៈពេល ៧ យប់ ៧ថ្ងៃ ខ្ញុំបានមកដល់ផ្សារអង្គតាសោម។ នៅទីនោះ ខ្ញុំបានចូលទៅសម្រាកក្នុងរោងយាមមួយស្របក់ធំ ស្រាប់តែសេនាជនភូមិដើរមកសួរនាំ។ ខ្ញុំក៏ប្រាប់សេនាជនតាមត្រង់ថាខ្ញុំជាទ័ព ប៉ុល ពត»។ សេនាជន មិនបានធ្វើបាបខ្ញុំទេ ប៉ុន្តែបានដកហូតកាំភ្លើងពីខ្ញុំ និងបញ្ជូនទៅកន្លែងឃុំ រង់ចាំឪពុកម្តាយរបស់ខ្ញុំមកធានាត្រឡប់ទៅវិញ។

ក្រោយជួបជុំជាមួយឪពុកម្តាយ ខ្ញុំក៏បានរៀបរាប់ដំណើរឆ្លងកាត់របស់ខ្ញុំប្រាប់ដល់គាត់ៗ ខ្ញុំបានត្រឡប់ទៅស្រុកកំណើត រួចរៀបការប្រពន្ធនៅឆ្នាំ១៩៨១ ក្រោមការរៀបចំរបស់ ឪពុកម្តាយៗ បន្ទាប់ពីរៀបការរួចខ្ញុំមានកូនចំនួន ៨នាក់ និងមានចៅតូចៗជាច្រើនទៀតៗ

ខ្ញុំនៅចាំថា ថ្វីត្បិតតែរបបខ្មែរក្រហមដួលរលំទៅក៏ពិតមែន ប្រទេសកម្ពុជានៅមិនទាន់មានស្ថិរភាពនៅឡើយៗ កងកម្លាំងខ្មែរក្រហមនៅតែបន្តបង្កចលាចលនៅក្នុងសង្គមៗ ខ្មែរក្រហមបានបំផ្ទុះអាវុធ និងឃាត់ខ្លួនមនុស្សនៅឯភ្នំវល្លិ ក្នុងខេត្តកំពត ព្រោះទីនោះគឺជាព្រៃស្តុកងាយស្រួល សម្រាប់ខ្មែរក្រហមធ្វើសកម្មភាពៗ ប្រជាជនមានការភិតភ័យជាខ្លាំងៗ ក្រោយមកដោយមានការអញ្ជើញជាច្រើនលើក ច្រើនសា ឲ្យចូលបម្រើការងារក្នុងរដ្ឋបាលភូមិស្រុករបស់ខ្ញុំ ខ្ញុំសម្រេចចិត្តចូលរួមជាមួយរដ្ឋអំណាច និងរាជរដ្ឋាភិបាលកម្ពុជា រហូតទទួលតំណែងជាមេឃុំរាមអណ្តើក រហូតមកដល់សព្វថ្ងៃ ដោយមិនមានការរើសអើង ទោះបីខ្ញុំធ្លាប់ជាអតីតសមាជិកខ្មែរក្រហមក៏ដោយៗ

ទោះបីជារបបខ្មែរក្រហម បានផុតរលត់ទៅអស់ជាច្រើនទសវត្សរ៍យ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែមានវិប្បដិសារី ចំពោះការសម្រេចចិត្តចូលរួមនៅក្នុងចលនាខ្មែរក្រហមៗ «មកដល់ពេលបច្ចុប្បន្ននេះ ខ្ញុំនៅតែមានវិប្បដិសារីដក់ជាប់ក្នុងចិត្តរហូតមក ដោយចាញ់បោកតាមការឃោសនាមនោគមវិជ្ជារបស់ខ្មែរក្រហម ដែលបានដឹកនាំប្រទេសឲ្យមានការសម្លាប់រង្គាលទៅលើប្រជាជនខ្មែររាប់លាននាក់»ៗ ដើម្បីប៉ះប៉ូវនូវកំហុសកន្លងមក ខ្ញុំតែងចែករំលែកបទពិសោធន៍របស់ខ្ញុំទៅកាន់កូនចៅ ដើម្បីឲ្យក្មេងជំនាន់ក្រោយទាំងនេះយល់ដឹងឲ្យបានស៊ីជម្រៅ និងកុំឲ្យជាន់ដានចាស់របស់ខ្ញុំទៀតៗ



យោធាខ្មែរក្រហមនៅក្នុងលេណដ្ឋានត្រៀមប្រយុទ្ធៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សុំ សឿម ៖ អតីតមេបញ្ជាការ វរសេនាតូច-៥១

***មេក វិន***



សុំ សឿម ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមប្រាប់ដល់ មេក វិន អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (មេក វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សុំ សឿម ភេទប្រុស អាយុ៦៣ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានចែករំលែកអំពីរឿងរ៉ាវដែលគាត់ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមដូចខាងក្រោម ៖

មុនឆ្នាំ១៩៧០ ខ្ញុំរស់នៅក្នុងគ្រួសារកសិករដែលមានឪពុក គឺជាជនជាតិចិន និងម្តាយគឺជាជនជាតិខ្មែរ។ គ្រួសារខ្ញុំបានរស់នៅជួបជុំគ្នាយ៉ាងរីករាយ និងមានជីវភាពធូរធារ។ រៀងរាល់ពេលព្រឹក ខ្ញុំត្រូវជួយធ្វើកិច្ចការឪពុកម្តាយរបស់ខ្ញុំ។ ចំណែកឯនៅពេលថ្ងៃខ្ញុំទៅរៀននៅសាលាដូចក្មេងៗដទៃទៀតដែរ។ ខ្ញុំនៅចាំបានថា ពេលខ្ញុំមានអាយុ១២ឆ្នាំ សេនាប្រមុខ លន់ នល់បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីតំណែងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

នៅចន្លោះឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ ខ្ញុំរួមទាំងសិស្សានុសិស្សប្រហែល ៣០-៤០នាក់ ផ្សេងទៀតបាននាំគ្នារត់ចូលព្រៃម៉ាកគីជាមួយលោកគ្រូដែលបង្រៀននៅក្នុងថ្នាក់។ កាលនោះខ្ញុំរៀនដល់ថ្នាក់ទី១០ ។ ដោយសារតែនៅវ័យក្មេង ខ្ញុំឆាប់ជឿពាក្យលួងលោមបញ្ចុះបញ្ចូលរបស់គ្រូ។ បណ្តាលឲ្យខ្ញុំត្រូវចាកចេញពីឪពុកម្តាយ និងបងប្អូន។ ក្រោយពីបានធ្វើដំណើរទៅដល់ព្រៃម៉ាកគី ខ្ញុំក៏បានជួបជាមួយមេកងពលម្នាក់ ឈ្មោះ តាវឿន។ ដោយក្តីអាណិត និងស្រឡាញ់ តាវឿន បានយកខ្ញុំទៅធ្វើជានីរសាររបស់គាត់។ ខ្ញុំមានតួនាទីយកសំបុត្រទៅសមរភូមិខាងមុខម្តងម្កាល និងអមដំណើរមេរបស់ខ្ញុំនៅពេលមានប្រជុំនៅតាមភូមិភាគ។ ក្រៅពីនោះ ខ្ញុំទទួលភារកិច្ចចម្អិនអាហារ និងដាំទឹកក្តៅ ជូនមេរបស់ខ្ញុំដែរ។ ខ្ញុំនៅធ្វើជានីរសារបានមួយឆ្នាំ តាវឿន ក៏ឲ្យខ្ញុំឈប់ ហើយបញ្ជូនខ្ញុំឲ្យចូលធ្វើជាកងទ័ពវិញ ។

នៅឆ្នាំ១៩៧៣ ខ្ញុំបានចូលជាកងទ័ពខ្មែរក្រហម និងបានទៅឈរជើងនៅសមរភូមិជាមួយកងកម្លាំងខ្មែរក្រហមជាច្រើននាក់ទៀត។ ទិសដៅរបស់កងកម្លាំងខ្មែរក្រហមគឺឡើងទៅវាយជាមួយកងទ័ព លន់ នល់។ ខ្ញុំ និងកងកម្លាំងខ្មែរក្រហមជាច្រើននាក់ទៀតបានទៅត្រៀមតាមគោលដៅរៀងៗខ្លួនដើម្បីទប់ទល់ជាមួយកងទ័ព លន់ នល់។ ខណៈពេលដែលកំពុងវាយប្រយុទ្ធគ្នា កងទ័ព លន់ នល់ បានទម្លាក់គ្រាប់បែក និងគ្រាប់គីមី យ៉ាងសន្ធឹកសន្ធាប់ដែលធ្វើឲ្យខូចខាតសម្ភារ និងគ្រឿងសព្វាវុធជាច្រើន។ សំណាងល្អកងកម្លាំងខ្មែរក្រហមទាំងអស់មិនរងរបួសធ្ងន់ធ្ងរ ប៉ុ

មានការស្លាប់។

នៅឆ្នាំ១៩៧៥ យោធាខ្មែរក្រហម បានវាយយកទីក្រុងភ្នំពេញបាន។ ខណៈពេលនោះ ខ្ញុំមានសេចក្ដីត្រេកអរ និងសប្បាយរីករាយយ៉ាងខ្លាំង ព្រោះខ្ញុំគិតថា នៅពេលទទួលបានជ័យជម្នះ ខ្ញុំនិងអាចត្រឡប់ទៅស្រុកកំណើតជួបជុំឪពុកម្ដាយវិញ។ ប៉ុន្តែ ជាអកុសលខ្ញុំមិនអាចត្រឡប់ទៅជួបគ្រួសារបានទេ ដោយសារតែខ្ញុំមានរបួសត្រង់កំភួនជើងពេលធ្វើសង្គ្រាម។ ខ្ញុំត្រូវនៅព្យាបាលក្នុងទីក្រុងភ្នំពេញ។ ក្រោយពីខ្ញុំព្យាបាលនៅមន្ទីរពេទ្យលោកសង្ឃ អស់រយៈពេលមួយខែ ខ្ញុំបានត្រឡប់ទៅនៅតាមសមរភូមិក្រោយវិញ។ បន្ទាប់មកទៀត ខ្ញុំត្រូវបានបញ្ជូនឲ្យទៅនៅឈរជើងនៅក្នុងទឹកដី ខេត្តកំពង់ចាមមួយរយៈ។

លុះដល់ឆ្នាំ១៩៧៧ ខ្ញុំបានទទួលដំណឹងថាឪពុកម្ដាយរបស់ខ្ញុំត្រូវបានគេសម្លាប់ចោលទាំងគ្រួសារ។ ដំណឹងនេះធ្វើឲ្យខ្ញុំមានកំហឹងយ៉ាងខ្លាំង។ ខ្ញុំចាំបានថា អ្នកដែលសម្លាប់ឪពុកម្ដាយរបស់ខ្ញុំ គឺជាអ្នកនៅក្នុងភូមិជាមួយគ្នា និងមានតួនាទីគឺជាឈ្លបភូមិ។ ដោយសារតែចង់បានមុខមាត់ បុណ្យស័ក្តិ ឈ្លបភូមិបានរាយការណ៍ទៅថ្នាក់លើថាគ្រួសាររបស់ខ្ញុំក្បត់អង្គការ និងជាសែស្រឡាយចិន។ នៅសម័យខ្មែរក្រហម អ្នកដែលមានឈ្មោះជាប់សែស្រឡាយចិន គឺឈ្លបយកទៅសម្លាប់ទាំងគ្រួសារ ទោះសាមីខ្លួនមិនបានប្រព្រឹត្តអ្វីខុសក៏ដោយ។ ខ្ញុំមានការសោកស្ដាយចំពោះឪពុកម្ដាយ បងប្អូនដែលបានស្លាប់យ៉ាងអាណោចអាធម្ម ទើបធ្វើឲ្យខ្ញុំចង់សងសឹកឃាតករដែលសម្លាប់គ្រួសាររបស់ខ្ញុំវិញ។

នៅក្នុងឆ្នាំ១៩៧៩ ពេលកងទ័ពស្ម័គ្រចិត្តវៀតណាមចូលវាយបែកបន្ទាយខ្មែរក្រហម។ ខ្ញុំរួមទាំងកងកម្លាំងខ្មែរក្រហមជាច្រើននាក់ទៀត បានរត់ភៀសខ្លួនទៅភ្នំឱរ៉ាល់ដែលស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ។ ក្រោយពីបានធ្វើដំណើរទៅដល់ទីនោះ កងកម្លាំងខ្មែរក្រហមទាំងអស់ ហាក់មានសភាពទ្រុឌទ្រោមយ៉ាងខ្លាំង ដោយសារតែពេលធ្វើដំណើរតាមផ្លូវមានការខ្វះខាតស្បៀងអាហារ និងទឹកផឹក។

នៅទីនោះ យើងនាំគ្នាដើររកជីកមើមក្ដួចយកមកធ្វើអាហារសម្រាប់ហូបដើម្បីមានជីវិតរស់។ ការអត់ឃ្លាន និងខ្វះស្បៀងអាហារហូបចុកបែបនេះ មិនអាចឲ្យយើងបន្តរស់នៅទីនោះបានទៀតទេ។ មិនយូរប៉ុន្មាន ខ្ញុំ និងកងកម្លាំងដែលនៅសេសសល់បានសម្រេចចិត្តចាកចេញពីភ្នំឱរ៉ាល់ ឆ្ពោះទៅកាន់ភ្នំដងរែក។ ខ្ញុំបានចំណាយពេលអស់ជាច្រើនខែទើបដើរទៅដល់ច្រក១០០៣ ដែលស្ថិតនៅក្នុងខេត្តព្រះវិហារ។ នៅទីនោះ មេកងពល និងមេកងវរសេនាធំចាប់ផ្ដើមប្រមូលកម្លាំងតាមភូមិភាគ តាមភូមិស្រុក មកជួបជុំគ្នាវិញ។ ក្រោយពីប្រមូលកម្លាំងបានហើយ មេកងពលធំ បានបង្កើត និងបែងចែកកម្លាំងទៅជាកងពលតូចៗ។ កាលណោះ ខ្ញុំនៅកងពលធំ៧៨៥ ហើយបន្ទាប់មកខ្ញុំត្រូវបានអង្គភាពបញ្ជូនឲ្យទៅវាយនៅសមរភូមិនៅទន្លេសាប។ ដើម្បីទៅដល់គោលដៅ ខ្ញុំត្រូវធ្វើដំណើរចុះពីលើភ្នំដងរែកដោយថ្មើរជើងរហូតដល់ខេត្តកំពង់ធំ ទើបជិះទូក ឆ្ពោះទៅកាន់ទន្លេសាប។ ទូកដែលខ្ញុំជិះមានប្រវែងពី៨-៩ម៉ែត្រ។ ខ្ញុំមិនចង់វាយជាមួយកងទ័ពខ្មែរទេ ព្រោះមុនពេលខ្ញុំចេញទៅវាយជាមួយវៀតណាម ខ្ញុំបានសរសេរសំបុត្រផ្ញើទៅតាមរយៈអ្នកស្រុកឲ្យប្រាប់កងទ័ពខ្មែរឆាប់ចាកចេញពីទីនោះឲ្យអស់ និងលឿនបំផុត។ ខ្ញុំមិនចង់ឃើញកងទ័ពខ្មែរវាយគ្នាឯងទេ។

នៅឆ្នាំ១៩៨២ ខ្ញុំបានទទួលតំណែងជាមេបញ្ជាការវរសេនាតូច-៥១ ។ កងកម្លាំងដែលខ្ញុំគ្រប់គ្រងមានចំនួន ១១០នាក់។ ក្រោយពីបានទទួលតំណែង ខ្ញុំបានទៅលេងបងប្អូននៅស្រុកកំណើត។ ក្រោយមក ខ្ញុំបានចាកចេញពីជួរកងទ័ព និងលះបង់គំនុំសងសឹកចោលទាំងអស់ ដោយខ្ញុំចង់បានតែសេចក្ដីសុខ និងរស់នៅដោយភាពស្មោះត្រង់ជាមួយញាតិជិតខាងរហូតមកដល់សព្វថ្ងៃ។



សុំ សឿម និងកូនប្រុស បច្ចុប្បន្នរស់នៅក្នុងឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (មេក វិន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សោម ហេង៖ ខ្ញុំជាទាហានរបស់ សោភឹម នៅឆ្នាំ ១៩៧៧

*មីន សាណាស់*



សោម ហេង (សោម ហេង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងវ័យ ៦២ឆ្នាំ នៅឆ្នាំនេះ សោម ហេង កំពុងរស់នៅជាមួយកូន និងចៅរបស់គាត់ឯខេត្តព្រះវិហារ។ ឆ្លៀតពេលទំនេរពីការងារក្នុងផ្ទះ និងស្រែចម្ការ ហេង តែងតែប្រើប្រាស់បណ្តាញទំនាក់ទំនងហ្វេសប៊ុកផ្ទាល់ខ្លួនក្នុងការបញ្ចេញគំនិត និងទស្សនៈផ្ទាល់ខ្លួនអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រហម និងតាមដានព័ត៌មានអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ កន្លងទៅនេះ ទំព័រហ្វេសប៊ុកផ្លូវការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឈ្មោះ Genocide Education in Cambodia បានសរសេរឃ្លាមួយរៀបរាប់ថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)៖ ថ្វីត្បិតតែប្រជាជនកម្ពុជាប្រមាណជាង ២លាននាក់ ត្រូវបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហមយ៉ាងណាក្តី ក៏នៅមានអ្នករស់រានមានជីវិតពីរបបនេះប្រមាណជាង ៥លាននាក់ទៀត បន្តរៀបរាប់រឿងរ៉ាវជីវិតរបស់ខ្លួន។ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា» និងបានភ្ជាប់ រូបថតមួយសន្លឹកបង្ហាញពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាស្ត្រីក្នុងវ័យចំណាស់ម្នាក់ កំពុងឈរញញឹមនៅលើកំណាត់ផ្លូវក្រាលគ្រួសក្រហម នាទេសភាពវាលស្រែក្នុងទីជនបទមួយកន្លែង នៃស្រុកត្រាំកក់ ខេត្តតាកែវ។ ហេង បានចូលមើលទំព័រហ្វេសប៊ុកនេះ បានអានឃ្លាប្រយោគខ្លីដែលជាសំណេររបស់លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបានសរសេរឃ្លាមួយក្នុងទម្រង់នៃការបញ្ចេញមតិ (Comment) ថា «ខ្ញុំជាទាហានរបស់ សោភឹម ចូលបម្រើកងទ័ពនៅឆ្នាំ១៩៧៧» ។ សោម ហេង គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ក្នុងចំណោមអ្នករស់រានមានជីវិតប្រមាណ ៥លាននាក់ទៀត ដែលកំពុងចង់ប្រាប់យើងអំពីរឿងរ៉ាវរបស់គាត់ឆ្លងកាត់បទពិសោធន៍ជូរចត់ក្នុងរបបខ្មែរក្រហម។

នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្ញើទំនាក់ទំនងតាមទូរស័ព្ទទៅកាន់ ហេង ដើម្បីសួរនាំលម្អិតពីឃ្លាដែលគាត់បាន

សរសេរ ក្នុងន័យចងក្រងឯកសារសម្រាប់ជាចំណេះដឹងដល់ក្មេងៗជំនាន់ក្រោយៗ ហេង បានសម្តែងការរីករាយ និងសប្បាយចិត្តក្នុងការចែករំលែករឿងរ៉ាវរបស់គាត់ប្រាប់ដល់យើងៗ គាត់មានស្រុកកំណើតនៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង ហើយបច្ចុប្បន្នគាត់រស់នៅក្នុងឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ហេង គឺជាកម្មករចម្ការកៅស៊ូក្នុងខេត្តកំពង់ចាម មុនពេលគាត់ស្ម័គ្រចិត្តចូលធ្វើជាកងទ័ពរបស់ សោ ភឹម ក្នុងឆ្នាំ១៩៧៧ តាមរយៈការអូសទាញរបស់ប្រធានការដ្ឋានចម្ការកៅស៊ូខ្លាយឈ្មោះ លុក ។ តាមរយៈការនិយាយប្រាប់ពី ហេង បានឲ្យដឹងថា ប្រធានការដ្ឋាន ប្រធានក្រុម និងប្រធានកងទាំងអស់នៃចម្ការកៅស៊ូខ្លាយ គឺសុទ្ធតែជាខ្សែរយៈទាក់ទងរបស់ សោភឹម ដែលមានតួនាទីអូសទាញ និងកៀងគរកម្លាំងដើម្បីប្រឆាំងអង្គការ តាមផែនការដែលបានគ្រោងទុកជាស្រេចតាំងពីឆ្នាំ១៩៧៦។ កន្លះខែក្រោយការចូលធ្វើជាកងទ័ពរបស់ ហេង ព្រឹត្តិការណ៍កម្ទេចសត្រូវក្បត់អង្គការនៅក្នុងភូមិភាគបូព៌ាបានកើតឡើងកាន់តែខ្លាំងឡើងៗ។ សោ ភឹម ត្រូវបានអង្គការតាមរកចាប់ខ្លួន ហើយកម្មាភិបាលជាច្រើននាក់ទៀត ក៏ត្រូវបានចាប់ខ្លួននិងសម្លាប់ជាបន្តបន្ទាប់។ ហេង និងទាហានខ្មែរក្រហមឯទៀតដែលស្ម័គ្រចិត្តចូលដំណាលគ្នាត្រូវបានប្រកាសរំសាយស្ងាត់ៗ ហើយគាត់ត្រូវបានផ្លាស់ប្តូរទីកន្លែងធ្វើការមកនៅចម្ការកៅស៊ូពាមជាំងវិញ។

ខាងក្រោមនេះ គឺជាការដកស្រង់ពាក្យសម្តីរបស់ ហេង ដោយសង្ខេបចេញពីកិច្ចសម្ភាសន៍រយៈពេល ៥៥នាទី ជាមួយ ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាមករៀបរៀងជាឃ្លាឃ្លោងដូចខាងក្រោម៖

---

«ខ្ញុំមានអាយុ ៦២ឆ្នាំ ។ បច្ចុប្បន្ន ខ្ញុំរស់នៅឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ខ្ញុំធ្លាប់ធ្វើជា ទាហានរបស់ សោ ភឹម បានកន្លះខែក្នុងឆ្នាំ១៩៧៧។ ក្រោយមកខ្ញុំនិងទាហានឯទៀត ត្រូវរំសាយទៅវិញបន្ទាប់ពីមានព្រឹត្តិការណ៍តាមចាប់ សោ ភឹម ដោយសារគាត់បានក្បត់ជាមួយថ្នាក់ដឹកនាំខ្មែរក្រហម។ ខ្ញុំចូលធ្វើទាហាននេះ គឺក្នុងគោលបំណងត្រៀមកម្លាំងទៅវាយ (ប្រយុទ្ធ) ជាមួយទាហានខ្មែរក្រហមខាងភូមិ ភាគនិរតីនិងទីក្រុងភ្នំពេញ។ កាលនោះ ខ្ញុំនិងក្មេងៗឯទៀតក្នុងភូមិប្រហែលជា ៣០នាក់ ត្រូវឈ្មោះ លុក ប្រធានការដ្ឋានចម្ការកៅស៊ូខ្លាយ ស្ថិតនៅភូមិខ្លាយ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម ជាអ្នកជ្រើសរើសឲ្យធ្វើការស្ម័គ្រចិត្តចូលរួមក្នុងកងកម្លាំងយោធារបស់ សោ ភឹម។

កាលពីក្មេងខ្ញុំនៅចាំបានថា ប្រហែលនៅឆ្នាំ១៩៦៧ ម្តាយឪពុកខ្ញុំបានលែងលះគ្នា។ កាលនោះខ្ញុំរស់នៅក្នុងខេត្តព្រៃវែង។ ម្តាយខ្ញុំបានយកប្តីថ្មីមួយទៀតដែលមានស្រុកកំណើតនៅស្រុកមេមត់។ នាពេល នោះ ខ្ញុំដែលជាកូនពៅក្នុងចំណោមបងប្អូនប្រាំនាក់ ក៏ត្រូវមករស់នៅជាមួយម្តាយនិងឪពុកចុង ដែលជាកម្មករចម្ការកៅស៊ូក្នុងស្រុកមេមត់ ខេត្តកំពង់ចាម។ ចាប់តាំងពីឆ្នាំ ១៩៧០ រហូតដល់ឆ្នាំ១៩៧២ ខ្ញុំសង្កេតឃើញនៅមានវត្តមានជនជាតិបារាំង នៅគ្រប់គ្រងចម្ការកៅស៊ូ និងទិញជ័រកៅស៊ូពីខ្មែរនៅឡើយទេ។

នៅពេលខ្ញុំមានអាយុ ១៣ឆ្នាំ ខ្ញុំបានចូលរៀនជាមួយកូនសិស្សលោកនៅក្នុងវត្តកន្ទួត ភូមិជាំកន្ទួត ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម ដែលមានឈ្មោះ ធុន និង ខា ជាគ្រូបង្រៀន។ ទោះបីជាតំបន់មេមត់ត្រូវកងកម្លាំងរំដោះគ្រប់គ្រងហើយក៏ដោយ ក៏ខ្ញុំនៅតែអាចបន្តការសិក្សារបស់ខ្ញុំបានដដែល។

ក្នុងចន្លោះឆ្នាំ១៩៧៤និង១៩៧៥ គ្រួសារខ្ញុំត្រូវផ្លាស់ប្តូរទីលំនៅមករស់នៅភូមិ ឡាំបោ ឃុំជាំតាម៉ៅ ស្រុកមេមត់។ រស់នៅទីនោះបានមួយឆ្នាំ ទើបខ្មែរក្រហមទទួលបានជ័យជម្នះ។ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានគ្រប់គ្រងប្រទេសទាំងមូល គ្រួសារខ្ញុំក៏ត្រូវអង្គការជម្លៀសឲ្យមកធ្វើការនៅការដ្ឋានចម្ការកៅស៊ូខ្លាយ ស្ថិតនៅភូមិខ្លាយ ឃុំជាំក្រវៀន ស្រុកមេមត់។ ការងារដែលខ្ញុំត្រូវទទួលក្រៅពីទៅរៀន គឺចៀរជ័រកៅស៊ូឲ្យខ្មែរក្រហម។



សូ វណ្ណា ហៅ សោ ភីម និងប្រពន្ធឈ្មោះ ប្រែង ហៅ យាយការ៉ូ នៅមុខប្រាសាទអង្គរវត្ត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងអំឡុងចុងឆ្នាំ១៩៧៦ ជិតចូលឆ្នាំ ១៩៧៧ ឪពុកចុងរបស់ខ្ញុំត្រូវអង្គការខ្មែរក្រហមចាប់យកទៅសម្លាប់ចោល ដោយសារតែមានមិត្តភក្តិគាត់ម្នាក់ឈ្មោះ ឆាយ ខស្សាហ៍មកអង្គុយលេងជាមួយគាត់នៅលើផ្ទះ និងបានជជែកគ្នាពីរឿងនាំគ្នារត់ទៅប្រទេសវៀតណាម។ ខ្ញុំនៅចាំបានថា ក្រុមទាហានបានចាប់និងបណ្ដើរគាត់ចេញពីផ្ទះនៅម៉ោង ៦ល្ងាច។ ខណៈពេលនេះហើយ ដែលប្រជាជនជាច្រើននាក់នៅក្នុងការដ្ឋានចម្ការកៅស៊ូ បានបាត់ខ្លួនស្ទើរតែអស់ពីភូមិ។ បងប្រុស បងថ្លៃស្រី និងក្មួយប្រុសតូចរបស់ខ្ញុំ ក៏ត្រូវអង្គការ ចាប់យកទៅសម្លាប់ចោលដោយគ្មានមូលហេតុដែរ។ ស្ថានភាពរស់នៅរបស់ខ្ញុំ និងកម្មករក្នុង ការដ្ឋានចម្ការកៅស៊ូមានភាពប្រែប្រួលទៅជាលំបាកជាងមុន។ របបអាហារ ក៏ត្រូវកាត់បន្ថយរហូតដល់គ្រប់គ្នាហូបបបរលាយជាមួយទំពាំងបុក្កូចទៅវិញ។

ដល់ឆ្នាំ១៩៧៧ អង្គការឲ្យខ្ញុំឈប់រៀន ហើយឲ្យមកធ្វើជាកម្មករចៀរជ័រកៅស៊ូជូនអង្គការរហូត។ ខ្ញុំត្រូវងើបពីព្រលឹមទៅធ្វើការងារ ហើយត្រូវធ្វើការរហូតដល់ម៉ោង ២ ប្រពាសៀល ទើបខ្ញុំអាចឈប់សម្រាកបាន។ ចំណែកការហូបចុកនិងស្នាក់នៅរបស់កម្មករក្នុងការដ្ឋានចម្ការកៅស៊ូវិញ គឺគ្រប់គ្រាន់ជាងប្រជាជនដែលរស់នៅក្នុងសហករណ៍។

ដើមឆ្នាំ១៩៧៨ ក្រោយពីខ្ញុំនិងកងទ័ពឯទៀតត្រូវរំសាយ អង្គការបានបញ្ជូនខ្ញុំឲ្យមកធ្វើការនៅ ចម្ការកៅស៊ូពាមជាំងវិញ។ ការងាររបស់ខ្ញុំ នៅតែជាអ្នកចៀរជ័រកៅស៊ូដដែល។ ខ្ញុំបានឮថា អង្គការតាមចាប់ សោ ភីម ព្រោះសង្ស័យថាបានក្បត់នឹងអង្គការបដិវត្តន៍។ ប៉ុន្តែ កាលនោះខ្ញុំក៏បានឮថា គាត់ (សោ ភីម) មិនព្រមឲ្យអង្គការចាប់ខ្លួនទេ គឺគាត់សុខចិត្តបាញ់សម្លាប់ខ្លួនឯង។ ក្រោយពីការស្លាប់របស់ សោ ភីម អង្គការបានយកសាកសពរបស់គាត់ដាក់លើឡាន ហើយសពរបស់គាត់ត្រូវគេក្លាសេទឹកកក លាយជាមួយអង្កាម ហើយបើកបែរចូលទៅកាន់ការដ្ឋានចម្ការកៅស៊ូពាមជាំង។ កម្មករចម្ការកៅស៊ូទាំងអស់ ទទួលបានការអនុញ្ញាតឲ្យមើលមុខជនក្បត់ជាតិនេះ។ ចំណែកខ្ញុំមិនហ៊ានទៅមើលជាមួយអ្នកឯទៀតទេ។ ខ្ញុំឈរនៅឆ្ងាយពីឡានដឹកសពប្រហែលជាប្រាំម៉ែត្រ។ ខ្ញុំបានឮសំឡេងអង្គការស្រែកហៅកម្មករឲ្យមកមើល ហើយប្រាប់ថា នេះជាខ្មោចរបស់ សោ ភីម ជាជនក្បត់ជាតិ។ ក្នុងពេលជាមួយគ្នានេះ យោធាខ្មែរក្រហមនៅខាងមេមត់ ក៏កំពុងមានការប្រយុទ្ធគ្នាជាមួយកងកម្លាំងវៀតណាមនៅតាមព្រំដែនដែរ។

ក្រោយបែកក្នុងឆ្នាំ១៩៧៩ ខ្ញុំបានត្រឡប់មករកបងប្អូននៅស្រុកកំណើតខ្ញុំវិញ ស្ថិតនៅឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ បន្ទាប់មកនៅឆ្នាំ១៩៨៣ ខ្ញុំបានរៀបការជាមួយប្រពន្ធឈ្មោះ ចែម សុធា ព្រមទាំងមានកូនចំនួន៣នាក់ (ប្រុសមួយ និងស្រីពីរនាក់)។ ពេលរៀបចំគ្រួសាររួច ខ្ញុំមិនដឹងធ្វើការអ្វីក្នុងស្រុកកំណើត ហើយមិនទម្លាប់ក្នុងការរស់នៅស្រុកកំណើតផង ខ្ញុំក៏នាំប្រពន្ធនិងកូនត្រឡប់មកធ្វើការជាកម្មករចម្ការកៅស៊ូវិញ គឺនៅចម្ការកៅស៊ូថ្មពេជ្រ។ ក្រោយមក ខ្ញុំក៏ចូលបម្រើជាកងកម្លាំងស្ម័យត្រាណការពារភូមិពីក្រុមខ្មាំងខ្មែរក្រហម។

បន្ទាប់មក ខ្ញុំបានលាឈប់ ហើយចូលបម្រើជាកងការពារជនជាតិសូវៀតក្នុងចម្ការកៅស៊ូជប់។ ក្រោយមកទៀត ខ្ញុំដាក់ពាក្យធ្វើជាបុគ្គលិករដ្ឋបាលខាងចម្ការកៅស៊ូពាមជាំង។ រហូតដល់ឆ្នាំ២០១០ ខ្ញុំបានសុំលាឈប់ពីការងារ ហើយប្តូរទីលំនៅមករស់នៅខេត្តព្រះវិហាររហូតដល់សព្វថ្ងៃ។ មូលហេតុដែលខ្ញុំសម្រេចចិត្តមករស់នៅខេត្តព្រះវិហារ គឺខ្ញុំមកតាមកូន និងចៅខ្ញុំដែលមកលក់ដូរឥវ៉ាន់នៅលើប្រាសាទព្រះវិហារ។ ខ្ញុំក៏ចាប់ផ្តើមប្រកបអាជីពថ្មីជាជាងថតរូបក្នុងតំបន់ព្រះវិហារ។ ថ្មីៗនេះ ខ្ញុំបានឈប់ប្រកបរបរជាជាងថតរូបតទៅទៀត ព្រោះភ្ញៀវទេសចរណ៍ទាំងអស់សុទ្ធតែមានទូរសព្ទដៃដែលអាចថតរូបខ្លួនឯងបានរៀងៗខ្លួន។ ឥឡូវកូនៗ មិនឲ្យខ្ញុំធ្វើអ្វីទេ គឺឲ្យខ្ញុំនៅតែផ្ទះ។ ខ្ញុំមិនចេះនៅស្ងៀមមួយកន្លែងទេ។ ខ្ញុំតែងធ្វើនេះបន្តិច ធ្វើនោះបន្តិចនៅក្នុងបរិវេណផ្ទះ ដូចជាចិញ្ចឹមមាន់ ចិញ្ចឹមទា និងធ្វើស្រែចម្ការ»។



គិលានដ្ឋានដែលត្រូវបានបោះបង់ចោលក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


សូ វណ្ណា ហៅ សោ ភឹម (រូបថតស្ថិតនៅចំកណ្តាលក្នុងឯកសណ្ឋានពណ៌ខ្មៅ) និងយោធាខ្មែរក្រហម កំពុងទស្សនកិច្ចអង្គភាពប្រយុទ្ធស្ម័គ្រចិត្តវៀតណាម ក្នុងឆ្នាំ១៩៧៣។ រូបថតនេះ ថតមិនយូរប៉ុន្មានមុនពេលក្រុមខុទ្ទាមសម្ព័ន្ធមិត្តបានចាប់ផ្តើមបើកការវាយប្រហារមកលើមូលដ្ឋានយោធាក្រៅ ក្នុងខេត្តកំពង់ចាមដែលជាផ្នែកមួយនៃសង្គ្រាមស៊ីវិលប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ដឹកនាំដោយសេនាប្រមុខ លន់ នល់។ សោ ភឹម បានក្លាយជាលេខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំភូមិភាគបូព៌ា នៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយគាត់បានធ្វើអត្តឃាតនៅថ្ងៃទី៣ ខែមិថុនាឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/វី អិន អេ)

# ក្រោយរដ្ឋប្រហារភូមិរបស់ខ្ញុំទទួលរងការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹក

គា រស្មី



ហាស់ ឆឹម អាយុ៨០ឆ្នាំ អតីតគ្រូបង្រៀន កើតនៅភូមិអង្គរស ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង២ រសៀល ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅជួបសម្ភាសន៍ជាមួយអតីតគ្រូបង្រៀនម្នាក់ ឈ្មោះ ហាស់ ឆឹម ហៅ តាវ ភេទប្រុស អាយុ ៨០ឆ្នាំ ។ ហាស់ ឆឹម កើតនៅភូមិអង្គរស ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ហាស់ ឆឹម បានរៀបការនៅអាយុ២០ឆ្នាំ ជាមួយឈ្មោះ ប៉ែន សុំ។ ក្រោយមកប្រពន្ធរបស់គាត់បានស្លាប់នៅអាយុ ៦៨ ឆ្នាំ។ ហាស់ ឆឹម មានកូនចំនួនប្រាំបីនាក់ ក្នុងនោះមានស្រីចំនួនបីនាក់។ សព្វថ្ងៃ ហាស់ ឆឹម គឺជាគ្រូបង្រៀនចូលនិវត្តន៍ម្នាក់ ដែលបានចំណាយពេលវេលាស្ទើរតែពេញមួយជីវិតរបស់គាត់ ធ្វើជាគ្រូបង្រៀន នៅតាមភូមិ និងសាលារៀន លើកលែងតែជីវិតក្រោមរបបខ្មែរក្រហមប៉ុណ្ណោះ ដែលគាត់គឺជាកសិករដូចប្រជាជនឯទៀតដែរ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបពីដំណើរជីវិតរបស់ ហាស់ ឆឹម និងព្រឹត្តិការណ៍ដែលបានកើតមាននៅក្នុងភូមិដែលគាត់រស់នៅ៖

នៅក្នុងសម័យសង្គមរាស្ត្រនិយម ថ្វីត្បិតតែនៅក្នុងភូមិមានសុវត្ថិភាព សម្បូរសប្បាយ មានសាលារៀន មន្ទីរពេទ្យ វត្តអារាម ស្ពាន ថ្នល់ និងប្រជាជនមានជីវភាពល្អប្រសើរ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ (ចាស់) ប៉ុណ្ណោះ។ សាលាដែលខ្ញុំរៀន គឺនៅសាលាបឋមសិក្សាអង្គរស។ នៅឆ្នាំ១៩៦៧ ខ្ញុំបានស្ម័គ្រចិត្តធ្វើគ្រូបង្រៀននៅក្នុងភូមិ គឺបង្រៀនសិស្សប្រមាណជាង ៣០នាក់ ទាំងកុមារ និងមនុស្សចាស់។ ការបង្រៀនរបស់ខ្ញុំក្នុងពេលនោះ គឺបង្រៀននៅតាមផ្ទះ និងនៅក្រោមដើមឈើ។ ខ្ញុំបានចូលរួមទទួលដំណើររបស់សម្តេចព្រះ នរោត្តម សីហនុ ចំនួនពីរលើក គឺម្តងនៅភូមិរបោះព្រីង នៅក្នុងខេត្តព្រៃវែង និងម្តងទៀតនៅក្រោលគោ នៅក្នុងខេត្តស្វាយរៀង។ រៀងរាល់ការយាងមកដល់របស់សម្តេចព្រះ នរោត្តម សីហនុ ម្តងៗ គឺតែងតែមានការប្រគំតន្ត្រី និងបង្កបរិយាកាសរាំលេងសប្បាយរីករាយជាខ្លាំង ហើយថែមទាំងមានតារាចម្រៀងល្បីៗជំនាន់នោះដូចជា អ្នកនាង រស់ សេរីសុទ្ធា និង លោក ស៊ិន ស៊ីសាមុត ចូលរួមផង។

នៅឆ្នាំ១៩៧០ ដោយសារតែមិនពេញចិត្តជាមួយ លន់ នល់ ដែលបានធ្វើរដ្ឋប្រហារទម្លាក់ សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ ប្រជាជននៅក្នុងភូមិ បាននាំគ្នាចូលរួមធ្វើបាតុកម្មប្រឆាំងនឹងការគ្រប់គ្រងរបស់ លន់ នល់។ នៅអំឡុងឆ្នាំដដែលសម្តេចព្រះ នរោត្តម សីហនុ បានប្រកាសតាមវិទ្យុថា ឲ្យប្រជាជនទាំងអស់ចូលព្រៃម៉ាគី ដើម្បីតស៊ូជាមួយទាហាន លន់ នល់។ ចាប់តាំងពីពេលនោះមក ភូមិឃុំរបស់ខ្ញុំទទួលរងនូវការទម្លាក់គ្រាប់បែកជាបន្តបន្ទាប់ ដែលការទម្លាក់ទាំងនោះ គឺភាគច្រើនគឺកើតឡើងនៅពេលព្រឹកៗ គុម្ពឫស្សី

មួយគុម្ពធំនៅជាប់របងផ្ទះរបស់ខ្ញុំ ក៏ត្រូវបានបំផ្លាញដោយការទម្លាក់គ្រាប់បែកនេះដែរ។ ឥទ្ធិពលរបស់អំបែងគ្រាប់ និងកម្លាំងខ្យល់របស់គ្រាប់ បានធ្វើឲ្យផ្ទះខ្ញុំ និងផ្ទះប្រជាជនមួយចំនួនទៀត ដែលស្ថិតនៅក្នុងចម្ងាយដី ១០០ ទៅ២០០ម៉ែត្រ រួមទាំង សត្វចិញ្ចឹមមួយចំនួន ត្រូវបានបំផ្លាញ។ ក្រៅពីការទទួលរងនៅក្នុងភូមិខ្ញុំ ក៏នៅមានការទម្លាក់គ្រាប់បែកដូចគ្នានេះនៅតាមភូមិមួយចំនួនទៀតក្នុងឃុំអង្គរស ដូចជានៅខាងលិចភូមិអង្គរស,ក្បែរវត្តអង្គរស និងភូមិពន្លៃ។ បើតាមខ្ញុំដឹង មូលហេតុដែលនាំឲ្យមានការទម្លាក់គ្រាប់បែកនេះ គឺដោយសារតែមានមូលដ្ឋានទ័ពរបស់វៀតកុង បោះទីតាំងនៅក្នុងភូមិមួយចំនួនក្នុងឃុំ។ ក្រៅពីការទម្លាក់គ្រាប់បែក ក៏នៅមានការវាយឆ្មក់ខ្លះទៀត ដែលអាចមើលឃើញថា ជាការវាយឆ្មក់បំផ្លាញខ្សែរយៈទាក់ទងរបស់ខ្មែររំដោះ ដូចជា ការដេញបាញ់កម្ទេចមធ្យោបាយធ្វើដំណើរ (ម៉ូតូ) របស់ប្រជាជន និងមធ្យោបាយផ្សេងៗទៀតដែលអាចបង្កលក្ខណៈងាយស្រួលក្នុងធ្វើដំណើរទាក់ទងគ្នានៅក្នុងមូលដ្ឋាន។ យន្តហោះម្យ៉ាង ដែលអ្នកភូមិនិយមហៅថា "អាកាវ៉ូ" គឺជាប្រភេទយន្តហោះដែលអាចផ្លុំខ្យល់បំប៉ើងផ្ទះប្រក់ស្លឹកត្នោតបុស្សរៃនិងទីកន្លែងដែលត្រូវបានសង្ស័យថាមានលាក់មធ្យោបាយធ្វើដំណើរផ្សេងៗ របស់វៀតកុង និងខ្មែររំដោះ។ នៅឆ្នាំ១៩៧១ ខ្ញុំ និងអ្នកភូមិឯទៀត បានមើលឃើញរថក្រោះប្រមាណ ៧០គ្រឿង បើកបរកាត់ភូមិអង្គរស ឆ្ពោះទៅមូលដ្ឋានទ័ពនៅគោខ្មុក។ នៅពេលនោះខ្ញុំមើលទៅផ្ទៃមេឃឃើញយន្តហោះខ្មៅពេញមេឃ និងឮសំឡេងយ៉ាងខ្ទរខ្ទើង។ ឃើញសភាពបែបនេះ ខ្ញុំភិតភ័យញ័រដៃជើងនិងនាំកូនៗ ទៅពួននៅត្រង់សេ។ ព្រឹត្តិការណ៍នេះធ្វើឲ្យខ្ញុំមិនឃ្លានបាយទឹក នឹកឃើញតែកូនៗ មិនដឹងគេចផុតឬអត់។ នៅពេលមួយក្នុងឆ្នាំដដែល មានការប្រយុទ្ធគ្នាមួយបានកើតឡើងនៅគោខ្មុក។ នៅក្នុងហេតុការណ៍ប្រយុទ្ធគ្នានេះ យើងសង្កេតឃើញមានយន្តហោះមួយគ្រឿងធ្លាក់នៅទីតាំង «ទួលប៉ុស្តិ៍» ស្ថិតនៅក្នុងទឹកដីឃុំអង្គរស និងរថក្រោះចំនួន ១១ គ្រឿងផ្សេងទៀតត្រូវបានបំផ្លាញ។ លើសពីនេះទៅទៀត សង្គ្រាមនេះបានបំផ្លាញទ្រព្យសម្បត្តិ ស្រែចម្ការ និងសត្វចិញ្ចឹមរបស់ប្រជាជននៅម្តុំនោះអស់ជាច្រើនៗ រហូតដល់ឆ្នាំ១៩៧៤



ក្មេងៗកំពុងអង្គុយលេងក្បែរគុម្ពឫស្សី ដែលជាអតីតទីតាំងទម្លាក់គ្រាប់បែកនៅអំឡុងឆ្នាំ១៩៧០ បណ្តាលឲ្យគុម្ពឫស្សីបែកចេញជាពីរគុម្ពផ្សេងគ្នា។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

វត្តមានរបស់ទាហានធីវគី និងវៀតកុង បានបាត់អស់ពីឃុំអង្គរស។ ជាមួយគ្នានេះដែរទ្រព្យសម្បត្តិឯកជនរបស់ប្រជាជន ត្រូវបានប្រមូលដាក់ជារបស់រួមជាបណ្តើរៗ។

បន្ទាប់ពីទទួលបានជ័យជម្នះថ្ងៃ១៧ មេសា ១៩៧៥ គ្រូបង្រៀនមួយចំនួនត្រូវបានបញ្ឈប់ លើកលែងតែគ្រូបង្រៀនមួយចំនួនដែលអង្គការទុកចិត្តប៉ុណ្ណោះ ទើបអាចបង្រៀនក្មេងៗបន្តទៀតបាន។ ចំណែក ខ្ញុំក៏ត្រូវខ្មែរក្រហមបញ្ឈប់រួចបញ្ជូនឲ្យទៅភ្ជួរដីធ្វើស្រែ និងគ្រប់គ្រងម៉ាស៊ីនបូមទឹកដាក់ស្រែនៅស្ពានឈើជ័យធ្លក រហូតដល់ឆ្នាំ១៩៧៩។ នៅក្នុងរបបខ្មែរក្រហម អង្គការមិនបានអនុញ្ញាតឲ្យមានការចាយលុយ ឬលក់ដូរទេ ហើយការរស់នៅរបស់ប្រជាជនក៏មិនមានសិទ្ធិសេរីភាពពេញបរិបូរណ៍ដែរ។ ប្រជាជនគឺតម្រូវឲ្យធ្វើការធ្ងន់ៗ និងចាប់យកទៅរៀនសូត្រ ប្រសិនបើនិយាយត្អូញត្អែរអំពីការងារដែលបានដាក់ឲ្យធ្វើ ព្រោះអង្គការគិតថាជាខ្មាំង ឬជន្លូវក្នុងសាច់។ ចំពោះការហូប



*ទេសភាពវាលស្រែនារដូវប្រាំងនៅក្នុងស្រុកមេសាង ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

អាហារវិញ ប្រជាជនហូបមិនឆ្អែតឡើយ គឺហូបតែបបរជាប្រចាំ។ ប៉ុន្តែយូរៗម្តង អង្គការឲ្យយើងហូបឆ្អែតម្តង គឺហូបបាយស្រួយ។

ពីចុងឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមខាងភូមិភាគនិរតី (និយាយរដឺនៗ) បានចូលមកគ្រប់គ្រងក្នុងភូមិភាគបូព៌ា រួចបានធ្វើការផ្លាស់ប្តូរប្រធានសហករណ៍មួយចំនួន ហើយបញ្ជូនឲ្យទៅរៀនសូត្រដោយមិនឃើញត្រឡប់មកវិញ។ ចាប់តាំងពីឆ្នាំនោះមក ប្រជាជនជាច្រើននាក់ ត្រូវបានជម្លៀសទៅកាន់តំបន់ដីខ្វាញ់ជាបន្តបន្ទាប់ ហើយប្រជាជនដែលជម្លៀសមកពីខាងព្រំដែនវៀតណាម ក៏ត្រូវយកមកសម្លាប់នៅឃុំអង្គរសអស់ជាច្រើននាក់ដែរ។ ក្នុងពេលនោះគ្រួសាររបស់ខ្ញុំ មិនត្រូវបានជម្លៀសទៅទេ។ រហូតដល់ចុងឆ្នាំ១៩៧៨ ប្រជាជនទាំងអស់ត្រូវបង្ខំឲ្យចាកចេញពីផ្ទះសម្បែងឆ្ពោះទៅទិសខាងលិច ដើម្បីគេចចេញពីកងទ័ពវៀតណាម ក្នុងនោះគ្រួសាររបស់ខ្ញុំក៏ធ្វើដំណើរទៅជាមួយដែរ។ ក្នុងពេលជម្លៀស កងទ័ពវៀតណាម បានស្ទាក់ដំណើរជម្លៀសរបស់ប្រជាជននៅស្រុកបាភ្នំ ហើយបានប្រាប់ឲ្យប្រជាជនទាំងនោះវិលត្រឡប់មកផ្ទះសម្បែងរៀងៗខ្លួនវិញ។ គ្រួសាររបស់ខ្ញុំក៏បានធ្វើដំណើរត្រឡប់មកផ្ទះវិញដែរ។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ដោយសារតែស្រឡាញ់អាជីពជាគ្រូបង្រៀន ខ្ញុំបានស្ម័គ្រចិត្តធ្វើជាគ្រូបង្រៀនម្តងទៀត ហើយបានបង្រៀនប្រជាជននៅក្នុងភូមិអង្គរស រហូតដល់ថ្ងៃដែលខ្ញុំត្រូវបានកោះហៅឲ្យទៅសិក្សាបន្ថែម នៅសាលាគរុកោសល្យ និងវិក្រឹត្យការខេត្តព្រៃវែង ដើម្បីបំពេញវិជ្ជាខាងបង្រៀន។ បន្ទាប់ពីបញ្ចប់វគ្គសិក្សាជំនាញគ្រូបង្រៀនរួចមក ខ្ញុំបានត្រឡប់មកភូមិកំណើត និងបានធ្វើគ្រូបង្រៀនរហូតដល់ថ្ងៃដែលខ្ញុំចូលនិវត្តន៍នៅឆ្នាំ១៩៩៩។ សព្វថ្ងៃនេះ ខ្ញុំរស់នៅជាមួយកូនៗរបស់ខ្ញុំក្នុងភូមិអង្គរស ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ឆ្លៀតពេលទំនេរ និងដើម្បីបំបាត់ការអផ្សុក ខ្ញុំធ្វើបង្គីរ និងដាំដំណាំតិចតួចនៅក្នុងបរិវេណផ្ទះ។

# ខ្ញុំមិនចង់រំឭករឿងពីអតីតកាល

*សុខ វណ្ណៈ*



អ៊ាន អាយុ៧៤ឆ្នាំ គឺជាសមាជិកក្រុមប្រឹក្សា ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំបានជួបរឿងរ៉ាវជាច្រើនស្ទើរតែមិនអាចរៀបរាប់បាន។ ខ្ញុំនិងប្រជាជនជាច្រើនគ្រួសារនៅក្នុងភូមិរបស់ខ្ញុំបានជួបការលំបាកយ៉ាងខ្លាំងដោយសារ សង្គ្រាម និងការទម្លាក់គ្រាប់បែក។ ឪពុករបស់ខ្ញុំ រួមទាំងប្អូនប្រុស របស់ខ្ញុំម្នាក់បានស្លាប់ដោយសារការទម្លាក់គ្រាប់បែកនេះ។ ម្តាយខ្ញុំនិងប្អូនៗចំនួន៤នាក់ទៀត បានស្លាប់ដោយសារយោធាខ្មែរក្រហមចាប់យកទៅសម្លាប់, ប្អូនស្រីជីដូនមួយពីរនាក់បានស្លាប់ក្នុងពេលជម្លៀស និងប្អូនប្រុសពីរទៀតដែលជាយោធាខ្មែរក្រហមនៅភូមិភាគបូព៌ា បានស្លាប់ដោយសារយោធាមកពីមជ្ឈិមចាប់ខ្លួនយកទៅសម្លាប់ ដោយបានចោទថា ក្បាលយួនខ្លួនខ្មែរ។

ខ្ញុំឈ្មោះ អ៊ាន សព្វថ្ងៃមានអាយុ៧៤ឆ្នាំ មានប្រពន្ធឈ្មោះ ស៊ិត មានកូនចំនួន ១០នាក់។ ប៉ុន្តែបានស្លាប់ចំនួន ៧នាក់នៅសល់តែ ៣ នាក់តែប៉ុណ្ណោះ ។ សព្វថ្ងៃខ្ញុំប្រកបមុខរបរធ្វើចម្ការ និងមានតួនាទីជាសមាជិកក្រុមប្រឹក្សា ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។

## កាលពីកុមារភាព

ខ្ញុំមានឪពុកឈ្មោះ ជុំ ម្តាយឈ្មោះ ឡី និងមានបងប្អូនចំនួន ១០នាក់។ ខ្ញុំគឺជាកូនច្បង ក្នុងគ្រួសារ។ ខ្ញុំបានរស់នៅជាមួយឪពុកម្តាយតាំងពីតូចរហូតដល់ពេញវ័យ។ ខ្ញុំបានចូលរៀននៅអាយុប្រហែល ៨ឆ្នាំ ។ កាលនោះនៅក្នុងភូមិរបស់ខ្ញុំមិនទាន់មានសាលារៀនទេ។ ដូច្នេះ ឪពុករបស់ខ្ញុំបានយកខ្ញុំទៅផ្ញើជាមួយព្រះសង្ឃនៅវត្តមេមត់។ ខ្ញុំធ្វើជាកូនសិស្សលោក និងបានរៀនសូត្រអក្សរសាស្ត្ររហូតចេះអាននិងចេះសរសេរអក្សរ។ នៅពេលអាយុ ១៨ឆ្នាំ ខ្ញុំបានបួសជាព្រះសង្ឃបានពីរវស្សានៅវត្តមេមត់ដដែល។ កាលនោះ ដោយសារខ្ញុំមើលឃើញឪពុកម្តាយមានជីវភាពក្រលំបាក ណាមួយប្អូនៗរបស់ខ្ញុំនៅតូចៗ ខ្ញុំក៏លាចាកសិក្ខាបទ ដើម្បីមកជួយមើលថែប្អូនៗនិងជួយធ្វើស្រែចម្ការឪពុកម្តាយ។ នៅឆ្នាំ១៩៦៩ ខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយនារីម្នាក់រស់នៅក្នុងស្រុកភូមិជាមួយគ្នាដែលចាស់ៗបានផ្សំផ្គុំឲ្យយើង។ បន្ទាប់ពីរៀបការរួច ខ្ញុំនិងប្រពន្ធរបស់ខ្ញុំបានប្រកបមុខរបរធ្វើចម្ការនៅក្នុងភូមិ។

## នៅអំឡុងឆ្នាំ១៩៧០

នៅឆ្នាំ១៩៧០ នៅពេលកើតមានរដ្ឋប្រហារទម្លាក់

សម្តេចព្រះ នរោត្តម សីហនុ ប្រជាជនទាំងចាស់ទាំងក្មេង នាំគ្នាទៅធ្វើបាតុកម្មដើម្បីទាមទារអំណាចឲ្យសម្តេចឪមកគ្រប់គ្រងប្រទេសជាតិវិញ។ នៅតាមភូមិប្រជាជនភាគច្រើននាំគ្នាទៅធ្វើបាតុកម្ម ប៉ុន្តែគ្មានអាវុធ (កាំភ្លើង) នៅក្នុងដៃទេ មានតែដំបង និងកាំបិតនៅជាប់ខ្លួនប៉ុណ្ណោះ។ ប្រជាជនចេញទៅធ្វើបាតុកម្មបានប្រហែលជាពីរថ្ងៃ ក៏បានត្រឡប់ចូលមកក្នុងភូមិវិញ ព្រោះប្រជាជនធ្វើដំណើរទៅមុខមិនរួចដោយសារកងទ័ព លន់ នល់ បាញ់បង្ក្រាប។ នៅក្នុងឆ្នាំ១៩៧០ ដដែល ភូមិរបស់ខ្ញុំមិនទាន់ក្លាយជាតំបន់រំដោះភ្លាមៗទេ ប្រជាជននៅក្នុងភូមិខ្ញុំបានឃើញឧទ្ធម្ភាគចក្រធំៗ ដែលអាចដឹករថក្រោះបានហោះចូលមកៗ កាលនោះមានឧទ្ធម្ភាគចក្រចំនួន ១០គ្រឿង បានចុះចតនៅក្នុងភូមិរបស់ខ្ញុំ។ បន្ទាប់មក បានដាក់បន្ទាយនៅតាមចម្ការ ដែលមានចម្ងាយប្រហែលជាង១គីឡូម៉ែត្រពីភូមិ។ ខ្ញុំបានឃើញកងទ័ពអាមេរិកាំងមានទាំងស្បែកខ្មៅ និងស្បែកសដើរចូលមកក្នុងភូមិជាមួយទាហានធីវគី (វៀតណាមខាងត្បូង) ប៉ុន្តែកងទ័ពអាមេរិកាំងមិនបានធ្វើបាបប្រជាជនទេ។ កងទ័ពអាមេរិកាំងទាំងនោះបានសួរសុខទុក្ខប្រជាជននៅក្នុងភូមិ ព្រមទាំងផ្តល់ថ្នាំពេទ្យដល់ប្រជាជនណាដែលមានជំងឺទៀតផង។ ប្រជាជនទាំងអស់នៅក្នុងភូមិបានឃើញកងទ័ពអាមេរិកាំងស្នាក់នៅក្នុងភូមិបានរយៈពេលប្រហែលជាបីខែតែប៉ុណ្ណោះ។ ពេលកងទ័ពអាមេរិកាំងចាកចេញទៅអស់ ខ្ញុំឃើញទាហានធីវគី បន្តស្នាក់នៅក្នុងភូមិ។ ពេលនោះប្រជាជននៅក្នុងភូមិរបស់ខ្ញុំ មានការភ័យខ្លាចដោយសារទាហានធីវគី ដើរអុកឡុកផ្ទះប្រជាជននៅក្នុងភូមិ ដូចជា ដើរចាប់មាន់ ទា ជ្រូក ថែមទាំងឡើងទៅលើផ្ទះប្រជាជនមួយចំនួនរុករករបស់របរមានតម្លៃ ដូចជា មាសប្រាក់ជាដើម។ គ្មានប្រជាជនណាម្នាក់ហ៊ានតវ៉ាប្រឆាំងទេ ព្រោះទាហាន ធីវគី ទាំងនោះបានបើកសោកាំភ្លើងរួចជាស្រេច និងបានឡើងលើផ្ទះរបស់ខ្ញុំផ្ទាល់។

## នៅឆ្នាំ១៩៧១

បន្ទាប់ពីទាហានអាមេរិកាំង និងទាហាន ធីវគី ចេញទៅបាត់អស់ ខ្ញុំឃើញកងកម្លាំងបដិវត្តន៍ខ្មែរក្រហម និងកងទ័ព វៀតកុង បានចូលមកក្នុងភូមិវាយប្រយុទ្ធគ្នាជាមួយទាហាន លន់ នល់។ ពេលនោះភូមិរបស់ខ្ញុំបានប្រែជាតំបន់រំដោះ និងជាតំបន់គ្រោះថ្នាក់បំផុតដែលមានទាំងយន្តហោះទម្លាក់គ្រាប់បែកបេ ៥២ (បេណាំហាយជាភាសាវៀតណាម) និងគ្រាប់ផ្លោងមកពីតំបន់របស់ លន់ នល់ ចូលមកក្នុងភូមិ និងចម្ការក្បែរៗភូមិ។ ប្រជាជននាំគ្នាជីកត្រង់សេនៅក្រោមផ្ទះលាក់ខ្លួន ហើយពេលខ្លះប្រជាជនត្រូវហូបបាយនៅក្នុងត្រង់សេទៀតផង។ ប្រជាជនក្នុងភូមិមួយចំនួនដែលឈឺចាប់នឹងការទម្លាក់គ្រាប់បែកទាំងនោះ ក៏នាំគ្នាចូលបម្រើចលនាបដិវត្តន៍ខ្មែរក្រហម។ នៅក្នុងឆ្នាំ១៩៧១ ប្អូនប្រុសរបស់ខ្ញុំពីរនាក់មានឈ្មោះ ជុំ ឈាន និង ជុំ បឿនបានចូលបម្រើចលនាខ្មែរក្រហម ដោយប្អូនម្នាក់ចូលធ្វើជាពេទ្យស្រុក និងម្នាក់ទៀតចូលធ្វើជាយោធាស្រុកត្រាំមូង។ នៅអំឡុងពេលនោះទោះបីការទម្លាក់បែកច្រើនយ៉ាងណាក៏ដោយ ក៏ប្រជាជនឪពុក និងប្អូនប្រុសខ្ញុំម្នាក់ រួមទាំងអ្នកភូមិ ៧នាក់ផ្សេងទៀត បានចេញទៅធ្វើស្រែចម្ការនៅភូមិសាទុំ ឃុំជាំក្រវៀន ជាប់ព្រំប្រទល់ប្រទេសវៀតណាម ដោយសារមិនអាចទ្រាំទ្រនឹងភាពអត់ឃ្លានបាន។ ប្រជាជន បានសង់ខ្ទមស្នាក់នៅបណ្តោះអាសន្ន ដើម្បីធ្វើចម្ការស្រាប់ តែយន្តហោះមកទម្លាក់គ្រាប់បែកសម្លាប់ឪពុក និងប្អូនប្រុសខ្ញុំ រួមទាំងអ្នកភូមិចំនួន ៧នាក់ទៀត ដោយសាកសពខ្ទេចទៅជាបំបែកៗ។ យើងប្រមូលបំណែកសាកសពដែលនៅសេសសល់មកធ្វើបុណ្យ ហើយការធ្វើបុណ្យនៅពេលនោះ មិនបានត្រឹមត្រូវតាមទំនៀមទម្លាប់សាសនាទេ ព្រោះសង្គ្រាមកាន់តែខ្លាំង។

## នៅឆ្នាំ១៩៧៥

នៅឆ្នាំ១៩៧៥ ពេលរបបខ្មែរក្រហមឡើងកាន់អំណាច នៅតំបន់របស់ខ្ញុំរស់នៅត្រូវបានអង្គការបែងចែកស្រុកមេមត់ជាពីរគឺ ស្រុកមេមត់ និងស្រុកត្រាំមូង ស្ថិតក្នុងតំបន់ ២១ នៃភូមិភាគបូព៌ា។ ប្រជាជននៅក្នុងភូមិរបស់ខ្ញុំមិនទាន់ចូលក្នុងសហករណ៍ភ្លាមៗទេ គឺនៅធ្វើការងារប្រវាស់ដៃចែកផលដំណាំគ្នា និងហូបបាយតាមផ្ទះរៀងៗខ្លួននៅឡើយ។ នៅចុងឆ្នាំ១៩៧៦ អង្គការចាប់ផ្តើមប្រមូលទ្រព្យសម្បត្តិឯកជនដាក់រួមទាំងអស់។ ពេលនោះអង្គការបានបែងចែកកម្លាំងប្រជាជនទៅតាមវ័យ ដូចជា ស្ត្រីចាស់ៗដែលមានអាយុ៦០ឆ្នាំ ទៅ៧០ឆ្នាំ មើលក្មេងតូចៗដែលម្តាយរបស់ពួកគេទៅធ្វើការតាមការដ្ឋាន។ ចំពោះបុរសវ័យចំណាស់ អង្គការចាត់តាំងឲ្យវេញខ្សែគោ ប្ញុធ្វើបង្គី ល្អី និងដងវែក។ រីឯកុមារាកុមារី មានអាយុចាប់ពី៧ឆ្នាំ ដល់១៨ឆ្នាំ អង្គការបានចាត់តាំងឲ្យដើររើសអាចម៍គោដើម្បីយកទៅធ្វើជីដាក់ស្រែ។ កុមារទាំងនោះ ក៏អាច

លើកទំនប់បានដែរ។ ចំណែកកងចល័តយុវជនយុវនារី ត្រូវទៅធ្វើកងចល័ត ឬចូលធ្វើជាយោធា។ ចំពោះប្រជាជនដែលមានប្រពន្ធកូននៅភូមិស្រែ ដាំដុះនិងធ្វើចម្ការ គឺត្រូវហូបបាយរួមនៅតាមភូមិ ឬ សហករណ៍ ដូចជា សហករណ៍ឈូក និងខ្លះទៀតហូបរួមនៅតាមការដ្ឋាន។

## នៅអំឡុងឆ្នាំ ១៩៧៧-៧៨

សភាពការណ៍នៅក្នុងភូមិរបស់ខ្ញុំកាន់តែអាក្រក់ឡើងៗ ចំពោះរបបហូបចុក ថែមទាំង មានការស្រាវជ្រាវយកមនុស្សទៅសម្លាប់ចោលទៀតផង។ នៅអំឡុងពេលនោះ កម្មាភិបាលខ្មែរក្រហមមកពីមជ្ឈិម និងមកពីភូមិភាគនិរតីបានចុះមកចាប់គណៈឃុំឈ្មោះ តាហាប់ តាកុំ គណៈស្រុក គណៈតំបន់ឈ្មោះ សុទ្ធ និងយោធាស្រុកត្រមូងជាច្រើនទៀត ក្នុងនោះក៏មានប្អូនប្រុសរបស់ខ្ញុំពីរនាក់ទៀត ដែលជាយោធាស្រុកឈ្មោះ ជុំ ឈាន និងជុំ ប៉ឿន ដោយកុហកថាហៅទៅរៀនសូត្រ តែតាមការពិតយកទៅសម្លាប់ចោលទាំងអស់។ មានយោធាខ្មែរក្រហមមួយចំនួនដែលដឹងខ្លួន ក៏ដោះសម្លៀកបំពាក់ និងបោះអាវុធចោលរួចចូលមករស់នៅក្នុងភូមិវិញ ដោយបន្ទំខ្លួនធ្វើការក្នុងកងចល័ត។ ស្របពេលសភាពការណ៍កំពុងតែជ្រួលច្របល់ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧៨ អង្គការបានជម្លៀសប្រជាជនទាំងអស់ចេញពីភូមិ។ នៅពេលនោះខ្ញុំរួមទាំងគ្រួសារ និងប្រជាជនក្នុងភូមិនាំគ្នាធ្វើដំណើរដោយថ្មើរជើង និងខ្លះមានរទេះគោរទេះក្របីសម្រាប់ដាក់អីវ៉ាន់ និងមនុស្សចាស់ជរាចេញពីភូមិ។ នៅពេលធ្វើដំណើរនោះមានយោធាខ្មែរក្រហមក្មេងៗឈរចាំភ្ជង់កាំភ្លើងពីក្រោយរហូតប្រជាជនចេញផុតអស់។ ខ្ញុំដើរកាត់ព្រៃ ដោយគ្មានអាហារហូបចុកគ្រប់គ្រាន់ ហើយប្រជាជនខ្លះក៏ឈឺស្លាប់ជាបន្តបន្ទាប់ ជាពិសេសចាស់ៗ និងកូនក្មេងៗ។ ខ្ញុំបានធ្វើដំណើរទៅដល់ភូមិស្រែរនាម អង្គការបានដកហូតយករទេះគោក្របីទាំងអស់ ហើយឲ្យខ្ញុំរើអីវ៉ាន់ចេញពីរទេះរួចធ្វើដំណើរបន្តទៅមុខទៀត។ រឿងដែលខ្ញុំមិនចង់រំឭកនោះ គឺម្តាយនិងប្អូនៗរបស់ខ្ញុំមិនព្រមធ្វើដំណើរទៅមុខ ហើយគាត់សម្រេចចិត្តត្រឡប់មកស្រុកកំណើតវិញ ក៏ត្រូវយោធាខ្មែរក្រហមចាប់យកទៅសម្លាប់នៅយប់នោះតែម្តង។ ខ្ញុំមិនអាចសុំអនុញ្ញាតពីអង្គការដើម្បីមើលសាកសពម្តាយ និងបងប្អូនខ្ញុំជាលើកចុងក្រោយទេ។ ខ្ញុំបាននាំក្រុមគ្រួសារខាងប្រពន្ធបន្តដំណើរទៅមុខរហូតដល់ខេត្តក្រចេះ។ ខ្ញុំបានទៅដល់ស្រុកសំបូរ និងបានរស់នៅក្នុងភូមិអំពិលទឹកខាងជើង។ ប្រជាជននៅទីនោះមិនរើសខ្ញុំទេ និងមានចិត្តល្អ ហើយថែមទាំងមានចិត្តអាណិតអាសូរខ្ញុំទៀត។ យើងចុះធ្វើការងារតាមការដ្ឋាន និងហូបចុកជាមួយគ្នាដោយ មិនបែងចែកអ្នកជម្លៀស ឬអ្នកមូលដ្ឋានចាស់ទេ។ ចំពោះកម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិដែលខ្ញុំរស់នៅមិនបានរឹតបណ្តឹង និងធ្វើបាបខ្ញុំឡើយ គឺឲ្យខ្ញុំរស់នៅធម្មតាដូចអ្នកមូលដ្ឋានដែរ។ មិនបានយូរប៉ុន្មានគឺនៅខែវិច្ឆិកា ឆ្នាំ១៩៧៨ ខ្ញុំនិងគ្រួសារ ត្រូវបានអង្គការជម្លៀសចេញពីស្រុកសំបូរ រស់នៅភូមិតាំងគោកជិតវត្តស្វាយភ្លើងវិញ។ ខ្ញុំបានមកដល់ស្រុកតាំងគោកក្នុងរដូវច្រូតកាត់ ដូចនេះការហូបចុកមិនសូវខ្វះខាតទេ។ ពេលនោះ កូនខ្ញុំទាំងពីរនាក់បានស្លាប់ដោយសារជំងឺកញ្ជ្រិល និងគ្មានថ្នាំព្យាបាល។

## នៅឆ្នាំ ១៩៧៩

នៅឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមវាយចូលមកដល់ប្រទេសកម្ពុជា ខ្ញុំភ័យផងអរផង និងនឹកឃើញស្រុកកំណើត។ ខ្ញុំបាននាំក្រុមគ្រួសារដើរសំដៅមករកស្រុកកំណើតវិញ។ យើងធ្វើដំណើរទាំងយប់ទាំងថ្ងៃមកដល់ទឹកឆាក្នុងទឹកដីខេត្តកំពង់ចាម និងដើររកម្ហូបអាហារដោយខ្លួនឯង។ យើងធ្វើដំណើររយៈពេលជាង ១០ ថ្ងៃបានមកដល់ភូមិកំណើតវិញ។ ដំបូង មានប្រជាជនត្រឡប់មកវិញជាង ១០គ្រួសារប៉ុណ្ណោះ ហើយគ្រួសារនីមួយៗបាត់បង់សមាជិកគ្រប់ៗគ្នា គ្រួសារខ្លះស្លាប់ទាំងអស់តែម្តង។ ខ្ញុំបានរស់នៅក្នុងភូមិវិញ និងចាប់ផ្តើមប្រកបមុខរបរធ្វើស្រែចម្ការតាមទម្លាប់ពីដើមមក។ នៅក្នុងភូមិរបស់ខ្ញុំនៅរវាងពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨២ មានកងទ័ពវៀតណាមចាំការពារប្រជាជនក្នុងភូមិ ព្រោះនៅមានយោធាខ្មែរក្រហម ធ្វើសង្គ្រាមឈ្លបប្រឆាំងជាមួយកងទ័ពវៀតណាម ហើយយោធាខ្មែរក្រហមទាំងនោះបានលបចូលមកក្នុងភូមិ រកស្បៀងអាហារពីប្រជាជន។ នៅឆ្នាំ១៩៩៣ បន្ទាប់ពីបោះឆ្នោតរួចហើយ ប្រជាជននៅទូទាំងប្រទេស ចាប់មានសិទ្ធិសេរីភាពជាបណ្តើរៗ ហើយរហូតដល់ឆ្នាំ១៩៩៨ ទើបកងកម្លាំងខ្មែរក្រហមដែលនៅសេសសល់បានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ទើបប្រទេសកម្ពុជាមានសុខសន្តិភាព។

# នៅតែរឭកដល់ឪពុក និងបងដែលបាន ស្លាប់ក្នុងរបបខ្មែរក្រហម

**ទូច វណ្ណេត**



តុង សុកា កំពុងត្បាញក្រមា នៅក្រោមផ្ទះ។
(ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ តុង សុកា កើតនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៦០ នៅភូមិចំការ៣០ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំគឺជាកូនទី២ ក្នុងចំណោមបងប្អូនប្រុសស្រី ចំនួន ៨នាក់ នៃគ្រួសារកសិករ។ ដោយសារតែភាពក្រីក្រ ខ្ញុំមិនបានរៀនសូត្រជ្រៅជ្រះទេ ពីព្រោះខ្ញុំត្រូវជួយធ្វើការងារផ្ទះឪពុកម្ដាយ។ នៅអាយុប្រហែល ១០ឆ្នាំ ខ្ញុំបានដឹងអំពីរដ្ឋប្រហាររបស់ លន់ នល់ ទម្លាក់សម្ដេចព្រះនរោត្តម សីហនុ នៅទីក្រុងភ្នំពេញនាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ពីព្រោះចាស់ៗ បាននិយាយអំពីការផ្លាស់ប្តូររបបដឹកនាំ។ ទោះបីយ៉ាងណា ខ្ញុំនៅតែធ្វើការងារផ្ទះ និងចម្ការដូចធម្មតា។ បន្ទាប់ពីរដ្ឋប្រហារ ការប្រយុទ្ធរវាងទាហាន លន់ នល់ និងកងកម្លាំងរំដោះខ្មែរក្រហមបានកើតឡើងជាច្រើនដង ទាំងផ្លូវគោក និងផ្លូវទឹក។ កងកម្លាំងរំដោះខ្មែរក្រហមតែងតែលបចូលភូមិដើម្បីកៀរយកប្រជាជន ប៉ុន្តែអ្នកភូមិមួយចំនួនមានភាពភ័យតក់ស្លុត និងរត់ភៀសខ្លួនទៅកាន់ទីរួមខេត្តកំពង់ចាម។ ទាហាន លន់ នល់ បាន បើកការវាយប្រហាររហូតដល់ខ្មែរក្រហមដកកម្លាំងទៅវិញ។ ភូមិរបស់ខ្ញុំនៅពេលនោះ គឺជាតំបន់ប្រទាញប្រទង់រវាងទាហាន លន់ នល់ និងកងកម្លាំងរំដោះខ្មែរក្រហមរហូតដល់ចុងឆ្នាំ១៩៧៣ ខ្មែរក្រហមបានវាយរំដោះយកតំបន់នេះបានទាំងស្រុង។

នៅពេលដែលខ្មែរក្រហមបានឡើងគ្រប់គ្រងប្រទេស នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅក្នុងកងចល័ត និងធ្វើស្រែចម្ការនៅសហករណ៍រួម ស្ថិតនៅភូមិចំការ ៣០ ។ រហូតដល់ឆ្នាំ១៩៧៦ ខ្ញុំត្រូវបានចាត់តាំងឲ្យចូលក្នុងសហករណ៍ ទ្រានធ្វើការដាំដំណាំ និងលើកទំនប់ត្រួយចេក។ ខ្ញុំត្រូវបានចាត់តាំងឲ្យរែកដីឲ្យបាន ២ម៉ែត្រគាក្នុង ១ថ្ងៃ ដោយគ្មានពេលសម្រាក និងមិនមានអាហារហូបចុកគ្រប់គ្រាន់ឡើយ។ ប្រសិនបើមិនបានគ្រប់តាមផែនការកំណត់ទេ ខ្ញុំត្រូវអង្គការដាក់ពិន័យ និងមិនឲ្យហូបអាហារឡើយ។ ខ្ញុំធ្វើការលើកទំនប់ចេកក្នុងរដូវប្រាំង ចំណែករដូវវស្សា អង្គការបានចាត់តាំងខ្ញុំទៅដកស្ទូង និងដាំដំណាំផ្សេងទៀត។ ខ្ញុំត្រូវធ្វើការតាំងពីព្រលឹមទល់ព្រលប់ ប៉ុន្តែទទួលបានបបររាវតែមួយចានតែប៉ុណ្ណោះ។ នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំត្រូវអង្គការបញ្ជូនទៅលើកទំនប់នៅជាប់ព្រំប្រទល់ជាមួយនឹងស្រុកកងមាស

អស់រយៈពេល៩ខែ។ ក្នុងអំឡុងពេលធ្វើការនៅការដ្ឋានទំនប់ ខ្ញុំទទួលបានត្រឹមបបរគ្រាប់ពោតតែប៉ុណ្ណោះ។ ខ្ញុំនៅចាំពាក្យសម្លុត និងគម្រាមរបស់អង្គការ «ប្រសិនបើមិនចង់ទៅរៀនសូត្រ ត្រូវខំប្រឹងធ្វើការ»។ នៅពេលដែលឮពាក្យនេះ ខ្ញុំពិតជាមានអារម្មណ៍ភ័យតក់ស្លុតពីព្រោះបងរបស់ខ្ញុំត្រូវបានអង្គការយកទៅរៀនសូត្រ និងបាត់ខ្លួន។

នៅក្នុងឆ្នាំ១៩៧៨ អង្គការបានបញ្ជូនខ្ញុំទៅធ្វើការលើកទំនប់នៅសហករណ៍គគរវិញ។ នៅពេលមកដល់សហករណ៍គគរ ទើបខ្ញុំដឹងថា ឪពុករបស់ខ្ញុំត្រូវបានអង្គការយកទៅរៀនសូត្រ។ អ្នកភូមិម្នាក់បានប្រាប់ខ្ញុំថា ឪពុករបស់ខ្ញុំត្រូវឈ្លបវាយសម្លាប់ចោលបាត់ទៅហើយ។ ខ្ញុំពិតជានឹករឭកដល់ឪពុក ដែលបានស្លាប់បាត់បង់ជីវិតទាំងមិនមានកំហុស ហើយខ្ញុំភ័យខ្លាចអង្គការយកសមាជិកគ្រួសារទៅសម្លាប់បន្តទៀត ។ ការធ្វើកម្លាំងពលកម្មគ្មានពេលសម្រាក ការវាយធ្វើបាប ការបង្អត់អាហារ និងការកាប់សម្លាប់ បន្តកើតមានកាន់តែច្រើនឡើង។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំបានឃើញយោធាខ្មែរក្រហមមានអាយុចន្លោះពី ១៦ឆ្នាំ ដល់ ២០ឆ្នាំ បានដើរឆ្លងកាត់ភូមិរបស់ខ្ញុំ ឆ្ពោះទៅកាន់ទិសខាងលិច។ ខ្ញុំបានរួចរស់ជីវិតនៅពេលរបបខ្មែរក្រហមដួលរលំនៅដើមខែមករា ឆ្នាំ១៩៧៩។ ខ្ញុំតែងតែនឹករឭកដល់ឪពុក និងបងរបស់ខ្ញុំដែលបានបាត់បង់ជីវិតក្នុងរបបនោះ។ រយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ គឺស្ថិតនៅក្នុងការចងចាំរបស់ខ្ញុំ អំពីការបាត់បង់សមាជិកគ្រួសារ និងជីវិតដ៏លំបាកក្នុងរបបខ្មែរក្រហម។



ទិដ្ឋភាពតាមដងផ្លូវក្នុងភូមិចំការ ៣០ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សៀក ហេង៖ ចូលកងសែងយោធា រងរបួសព្រោះចង់ហូបឆ្អែត

*វី លក្ខិណា*



*សៀក ហេង សព្វថ្ងៃខ្ញុំគឺជាជំទប់ទី១ នៃឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាម។ (ស៊ុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ សៀក ហេង ភេទស្រី អាយុ ៦៣ឆ្នាំ។ សព្វថ្ងៃខ្ញុំគឺជាជំទប់ទី១ នៃឃុំត្រមូង។ ខ្ញុំកើតនៅភូមិដាំទ្រៀក ឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ) ។ ឪពុករបស់ខ្ញុំឈ្មោះ សៀក វ៉ាត និងម្តាយឈ្មោះ ហៀ ហុង។ ខ្ញុំមានបងប្អូនង្កើតទាំងអស់ចំនួន ៦ នាក់ គឺស្រីចំនួន ៥នាក់ និងប្រុសចំនួន ១ នាក់។ ខ្ញុំបានរៀនសូត្រត្រឹមថ្នាក់ទី ៩នៅសង្គមចាស់ នៅសាលាបឋមសិក្សាមេមត់។ ខ្ញុំបានឈប់រៀនបន្ទាប់ពីកើតមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០ ហើយខ្ញុំបានមកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ។

បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅក្នុងភូមិរបស់ខ្ញុំចាប់ផ្តើមមានការទម្លាក់គ្រាប់បែកដែលបណ្តាលឲ្យឆេះផ្ទះ និងស្លាប់ប្រជាជនមួយចំនួន។ ផ្ទះរបស់ខ្ញុំក៏ត្រូវភ្លើងឆេះដែរនៅពេលនោះ។

ខ្ញុំនៅចងចាំទិដ្ឋភាពដែលយន្តហោះមកទម្លាក់គ្រាប់បែកឆេះផ្ទះរបស់ខ្ញុំ ប៉ុន្តែឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំមិនមានរងរបួសទេ ព្រោះពេលដែលយន្តហោះមកទម្លាក់ម្តងៗ ខ្ញុំនិងក្រុមគ្រួសារបានរត់ចូលទៅពួនក្នុងលេណដ្ឋានដែលឪពុករបស់ខ្ញុំជីកនៅក្នុងចម្ការទុរេនក្បែរៗផ្ទះ។ បន្ទាប់ពីស្ងប់ស្ងាត់ការទម្លាក់គ្រាប់បែក ទើបឪពុកម្តាយរបស់ខ្ញុំត្រឡប់មកសាងសង់ខ្ទមស្នាក់នៅជាបណ្តោះអាសន្ន។ ចំណែកប្រជាជនក្នុងភូមិផ្សេងទៀត ក៏បានជីកលេណដ្ឋាននៅក្នុងចម្ការទុរេន

ដែរ។ ប្រសិនបើ គ្រួសារណាមានឪពុកម្តាយអាយុច្រើនពិបាករត់គេច ទើបនៅសម្ងំលាក់ខ្លួននៅក្នុងភូមិ។ នៅថ្ងៃមួយ យន្តហោះបានមកទម្លាក់គ្រាប់បែកចំប្រជាជនដែលបានពួននៅក្នុងលេណដ្ឋាន បណ្តាលឲ្យស្លាប់អស់ចំនួន ៣ គ្រួសារ។ ខ្ញុំបានសង្កេតឃើញថា មុនពេលយន្តហោះមកទម្លាក់គ្រាប់បែកម្តងៗ តែងតែមានឧទ្ធម្ភាគចក្រហោះស៊ើបការណ៍ថា តើមានកងទ័ពវៀតកុងចូលក្នុងភូមិឬអត់? ប្រសិនបើមានកងទ័ពវៀតកុងចូលមកក្នុងភូមិ ទើបមានយន្តហោះមកទម្លាក់គ្រាប់។

នៅអំឡុងពេលនោះ ទាហានធីវគី បានចូលមកក្នុងភូមិក្នុងបំណងរកកងទ័ពវៀតកុង។ ពេលឃើញទាហានធីវគីចូលមក យើងដែលជាក្មេងស្រីៗភិតភ័យយ៉ាងខ្លាំង ហើយបាននាំគ្នារត់ទៅពួននៅក្នុងចម្ការទុរេន ព្រោះទាហានធីវគី ធ្លាប់បានចាប់រំលោភកូនក្រមុំអ្នកភូមិ។នៅពេលដែលទាហានធីវគី ដកចេញទៅវិញ ទើបខ្ញុំត្រឡប់មកផ្ទះវិញ។

នៅឆ្នាំ១៩៧២ ខ្ញុំបានចូលទៅក្នុងព្រៃសាមគ្គីជាមួយវៀតកុង ដែលប្រជាជនទូទៅហៅថាព្រៃម៉ាគី។ ព្រៃនោះស្ថិតនៅជិតផ្ទះរបស់ខ្ញុំ។ ពេលដែលចូលទៅក្នុងព្រៃសាមគ្គី គឺខ្ញុំបានធ្វើស្រែប្រវាស់ដៃ។ នៅឆ្នាំ១៩៧៤ ស្រុកមេមត់ត្រូវបានបំបែកជាពីរ គឺស្រុកត្រមូង និងស្រុកមេមត់ ស្ថិតក្នុងតំបន់២១ភូមិភាគបូព៌ា។ ខ្មែរក្រហមបានកាត់យកឃុំខ្លះនៃស្រុកមេមត់ឲ្យទៅស្រុកត្រមូង។ ចំណែកឃុំមួយចំនួនទៀតស្ថិតនៅក្នុងស្រុកមេមត់ខ្លះ គឺនៅដដែល។ ស្រុកត្រមូងមានចំនួន៨ឃុំ គឺឃុំត្រមូង, ឃុំរូង, ឃុំចាន់មូល, ឃុំជាំ, ឃុំក្រវៀន, ឃុំទន្លូង, ឃុំជាំតាម៉ៅ និងឃុំមេមង។

បន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មករស់នៅក្នុងភូមិរបស់ខ្ញុំ ហើយខ្មែរក្រហមក៏បានចាប់ផ្តើមបង្កើតសហករណ៍នៅក្នុងភូមិរបស់ខ្ញុំដែរ។ ខ្មែរក្រហមបានឲ្យយើងហូបបាយរួម និងបានប្រមូលសម្ភារប្រជាជនដាក់រួមៗ នៅពេលនោះខ្ញុំមានតួនាទីបង្រៀនក្មេងៗ ដោយយកទីធ្លាក្រោមផ្ទះរបស់ប្រជាជនធ្វើជាថ្នាក់រៀន។ សិស្សដែលខ្ញុំបង្រៀនមានចំនួនសរុប ៣០ នាក់ ។ សិស្សត្រូវមកដល់ថ្នាក់រៀននៅពេលព្រឹក ហើយចាប់ផ្តើមរៀនអក្សរ «ក,ខ និងរៀនរាប់លេខ» ។ បន្ទាប់ពីរៀនចប់ សិស្សដែលមានវ័យក្មេងៗ ត្រូវទៅហូបបាយនៅរោងបាយរួមមុនចាស់ៗ ។ នៅពេលថ្ងៃ ក្មេងៗត្រូវបានចាត់តាំងឲ្យទៅកាប់ទន្ទ្រានខេត្រ កើបអាចម៍គោ យកទៅបាចនៅស្រែ។ នៅក្នុងឃុំត្រមូង មានគ្រូបង្រៀនចំនួន ៣នាក់ បង្រៀនក្មេងៗតាមភូមិ។ ចេវ ជឿន គឺជាកម្មាភិបាលដែលគ្រប់គ្រងគ្រូបង្រៀននៅក្នុងភូមិ ដែលមាន ខ្ញុំ, ហន, និងម្នាក់ទៀតខ្ញុំមិនចាំឈ្មោះ ព្រោះពេលខ្មែរក្រហមជម្លៀសគាត់ទៅតំបន់ក្រចេះ គាត់ត្រូវយោធាខ្មែរក្រហមសម្លាប់នៅទីនោះ។ នៅក្នុងតំបន់ ២១ ពេលនោះមានគណៈឃុំត្រមូងឈ្មោះ ឯក ឡាយ, គណៈស្រុកត្រមូង ឈ្មោះ តាសុខ និងអនុរបស់គាត់ឈ្មោះ គង ឈុំ។

នៅក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញពីភូមិឲ្យទៅខាងខេត្តក្រចេះ ហើយខ្ញុំនិងក្រុមគ្រួសារក៏ត្រូវជម្លៀសទៅជាមួយប្រជាជនផ្សេងទៀតដែរ។ ពេលជម្លៀសនោះខ្ញុំត្រូវបែកពីឪពុកម្តាយ និងបងៗរបស់ខ្ញុំ។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើង ដោយយប់ត្រង់ណា គឺត្រូវដេកត្រង់កន្លែងនោះ។ ពេលឈប់សម្រាកនៅតាមផ្លូវ យោធាខ្មែរក្រហមបានបើកអង្ករឲ្យខ្ញុំដាំបាយហូប។ ពេលព្រឹកឡើងយោធាខ្មែរក្រហមដេញឲ្យខ្ញុំធ្វើដំណើរបន្តទៅមុខទៀត។ ទៅដល់ខេត្តក្រចេះ ខ្ញុំបានជួបឪពុកម្តាយវិញ។ ខ្មែរក្រហមបានបែងចែកឪពុកម្តាយខ្ញុំឲ្យទៅនៅកងចាស់ៗ ចំណែក



*សៀក ហេង សព្វថ្ងៃខ្ញុំគឺជាជំទប់ទី១នៃឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាម។ (ស៊ុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំនៅកងចល័ត។ កាលនោះខ្ញុំមានអាយុ១៩ឆ្នាំ ដែលជាវ័យពេញកម្លាំង ដូច្នេះខ្មែរក្រហមបានប្រើខ្ញុំឲ្យធ្វើស្រែ ស្ទូងស្រូវ ដកសំណាប រហូតដល់ម៉ោង ១០យប់ ទើបឲ្យឈប់សម្រាក។ នៅវេលាម៉ោង ៥ព្រឹក ប្រធានកងបានដើរដាស់សមាជិក និងឲ្យទៅតម្រង់ជួរច្រៀងបទគោរពទង់ជាតិ។ បន្ទាប់មកសមាជិកកងចល័តត្រូវដើរទៅធ្វើការ ដោយទម្រាំដើរដល់វាលស្រែ គឺមេឃភ្លឺល្អម។ ខ្ញុំទទួលបានរបបបបរលាយពោត និងសម្លរត្រកួន។ បន្ទាប់ពីខ្ញុំហូបអាហារថ្ងៃត្រង់រួច ខ្ញុំត្រូវចុះធ្វើការរហូតដល់ម៉ោង ៧យប់ ទើបបានហូបបាយម្ដងទៀត ហើយបន្តធ្វើការរហូតដល់ម៉ោង ១០ យប់។ ទោះជា ហូបមិនឆ្អែត ក៏ខ្ញុំមិនហ៊ានលួចពោត ឬដំឡូងហូបដែរ ព្រោះខ្ញុំបានឃើញពូម្នាក់រស់នៅឃុំថ្មគ្រែ បានលួចពោតហូប ប៉ុន្តែត្រូវយោធាខ្មែរក្រហមឃើញ និងចាប់គាត់យកទៅបាញ់សម្លាប់ភ្លាមៗនៅមុខកងចល័ត។ ខ្ញុំបានលាក់ប្រវត្តិរូបដោយប្រាប់យោធាខ្មែរក្រហមថា ខ្ញុំគឺជាកងចល័ត ព្រោះគ្រូបង្រៀនជាមួយខ្ញុំត្រូវបានសម្លាប់ដោយសារយោធាខ្មែរក្រហមបានស៊ើបដឹងពីប្រវត្តិរូប។

នៅខេត្តក្រចេះ កងចល័តហូបមិនគ្រប់គ្រាន់ឡើយ ហើយថែមទាំងត្រូវធ្វើការគ្មានពេលសម្រាកទៀត។ ក្រោយមក ខ្ញុំបានឮប្រជាជននិយាយថា «ប្រសិនបើទៅសែងយោធាខ្មែរក្រហមដែលរងរបួសនៅសមរភូមិយកទៅដាក់នៅមន្ទីរពេទ្យ នឹងទទួលបានរបបអាហារហូបគ្រប់គ្រាន់» ។ ពេលនោះ ខ្ញុំបានស្ម័គ្រចិត្តទៅសែងអ្នករបួស។ ក្រុមរបស់ខ្ញុំមានសមាជិក៤នាក់ចាំសែងយោធាដែលរងរបួស។ យើងសែងបណ្ដាក់គ្នា ពីមួយដំណាក់ទៅមួយដំណាក់តាមទីតាំងដែលកំណត់ រហូតដល់មន្ទីរពេទ្យ។ បំណងរបស់ខ្ញុំនៅពេលនោះគឺគ្រាន់តែចង់ហូបឆ្អែតតែប៉ុណ្ណោះ។ នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ខេត្តក្រចេះ យោធាខ្មែរក្រហមបានជម្លៀសខ្ញុំ និងប្រជាជនតាមកាណូតទៅស្រុកស្ទឹងត្រង់ ស្ថិតនៅភូមិភាគកណ្ដាលវិញ។ ខ្ញុំឃើញខ្មែរក្រហមជីករណ្ដៅធំៗ ដើម្បីត្រៀមសម្លាប់ប្រជាជនរួចទម្លាក់ចូលក្នុងរណ្ដៅនោះ។ ពេលខ្ញុំដើរទៅធ្វើការកាត់ទីនោះ ខ្ញុំមិនដែលហ៊ានងាកមើលរណ្ដៅទាំងនោះឡើយ។ ខ្ញុំនៅស្ទឹងត្រង់បានរយៈពេលប្រមាណមួយសប្ដាហ៍ កងទ័ពវៀតណាមបានវាយចូលមកដល់។ ខ្ញុំត្រូវបានយោធាខ្មែរក្រហមជម្លៀសចេញពីស្ទឹងត្រង់ ចំណែកប្រជាជនខ្លះទៀតបានរត់គេចទៅស្រុកកំណើតវិញ។ ខ្ញុំបានដើរមកដល់កំពង់ចាម ក៏សុំរថយន្តកងទ័ពវៀតណាមជិះត្រឡប់មកស្រុកកំណើតវិញ។ ពេលមកដល់ស្រុកកំណើត ខ្ញុំមិនបានជួបជុំជាមួយឪពុកម្ដាយទេ។ រយៈពេល ១០ ថ្ងៃក្រោយមក ទើបខ្ញុំបានជួបជុំឪពុកម្ដាយ និងបងប្អូនរបស់ខ្ញុំវិញ។ យើងបានចាប់ផ្ដើមរៀបចំសង់ផ្ទះសម្បែងស្នាក់នៅ និងនាំគ្នាធ្វើស្រែ ចម្ការ ដើម្បីចិញ្ចឹមជីវិតរហូតដល់សព្វថ្ងៃ។

# អនុស្សាវរីយ៍ក្នុងរបបខ្មែរក្រហម ដែលម្តាយខ្ញុំចាំមិនភ្លេច

*កែម សុភី*



ម្តាយរបស់ខ្ញុំឈ្មោះ ហាក់ ស៊ីធួក អាយុ៦២ឆ្នាំ រស់នៅភូមិឡឥដ្ឋ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម។ (កែម សុភី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ម្តាយខ្ញុំឈ្មោះ ហាក់ ស៊ីធួក កើតនៅឆ្នាំ ១៩៦០ ក្នុងគ្រួសារកសិករ នៅភូមិកំពង់ថ្ម ឃុំកំពង់ថ្ម ស្រុកសន្ទុក ខេត្តកំពង់ធំ។ គាត់មានបងប្អូនប្រុសស្រីចំនួន ៥ នាក់។ ម្តាយខ្ញុំរៀនបានត្រឹមថ្នាក់ទី ១០ចាស់ នៅសាលាបឋមសិក្សាកំពង់ថ្ម។ ដោយសារតែជីវភាពក្រីក្រ គាត់បានឈប់រៀនដើម្បីជួយធ្វើស្រែ និងរកត្រីជាមួយឪពុកម្តាយ រហូតដល់មានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ បន្ទាប់ពីរដ្ឋប្រហារ កងទ័ពរំដោះខ្មែរក្រហម បានចូលមកនៅក្បែរភូមិកំពង់ថ្ម ឃុំកំពង់ថ្ម។ ម្តាយខ្ញុំនិងក្រុមគ្រួសារបានរត់ភៀសខ្លួនទៅរស់នៅក្នុងឃុំក្រយោ ស្រុកសន្ទុក អស់មួយរយៈពេល។ នៅពេលនោះ ទាហាន លន់ នល់ ជាច្រើននាក់ ត្រូវបញ្ជូនទៅប្រយុទ្ធតតាំងជាមួយកងទ័ពរំដោះខ្មែរក្រហម។ ក្រោយពេលកងទ័ពរំដោះខ្មែរក្រហមដកទ័ពថយទៅ ម្តាយខ្ញុំនិងគ្រួសារបានវិលត្រឡប់មករស់នៅក្នុងភូមិកំណើតវិញ។ ទោះបីយ៉ាងណាក៏ដោយ ខ្មែរក្រហមនៅតែដាក់កងទ័ពរំដោះឈរជើង និងបានយកស្រុកសន្ទុកជាសមរភូមិប្រយុទ្ធជាមួយទាហានលន់នល់។ មកដល់ឆ្នាំ១៩៧៣ កងទ័ពរំដោះខ្មែរក្រហមបានវាយយកស្រុកសន្ទុក និងគ្រប់គ្រងភូមិរបស់ម្តាយខ្ញុំ។ នៅពេលនោះ ម្តាយខ្ញុំនិងប្រជាជនដទៃទៀតក្នុងភូមិកំពង់ថ្ម ត្រូវបានកងទ័ពរំដោះខ្មែរក្រហមជម្លៀសទៅរស់នៅតំបន់រំដោះ វាលត្បែងកោង ស្ថិតនៅក្នុងភូមិបឹង ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ។

រហូតដល់ខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនមករស់នៅភូមិកំណើតវិញ ដោយពេលនោះគាត់មានអាយុ១៧ឆ្នាំ ។ ម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការនៅក្នុងកងចល័តនារី។ ប្រធានកងចល័តនារីដែលម្តាយខ្ញុំមិនបានចាំឈ្មោះ បានឲ្យគាត់ទៅដកសំណាប ស្ទូង វែកដី លើកភ្លឺស្រែ ជីកប្រឡាយទឹក និងដើររកជីលេខមួយ (ជីលាមកស្រស់) ក្នុងមួយថ្ងៃឲ្យបាន១០០គីឡូ។ ម្តាយខ្ញុំត្រូវក្រោកនៅម៉ោង៤ព្រឹក ដើម្បីដកសំណាប និងស្ទូងស្រូវឲ្យគ្រប់តាមការកំណត់របស់អង្គការ។ នៅវេលាម៉ោង ១២ ថ្ងៃ

ត្រង់ គឺជាពេលសម្រាកហូបអាហារ។ គាត់បានហូបតែបបររាវមួយចានលាយជាមួយត្រកួន និងអំបិលតិចតួចដើម្បីយកជាតិតែប៉ុណ្ណោះ។ នៅវេលាម៉ោង១រសៀល ម្តាយខ្ញុំត្រូវបន្តទៅស្ទូងស្រូវឲ្យរួចរាល់តាមផែនការកំណត់មុនម៉ោង ៥ល្ងាច ។ របបអាហារពេលល្ងាចនៅតែជាបបររាវមួយចានលាយជាមួយត្រកួន និងអំបិលតិចតួចដដែល។ នៅពេលយប់ខ្លះគាត់បានឆ្លៀតពេលដកសំណាបទុកសម្រាប់ស្ទូងនៅពេលព្រឹក។ ម្តាយខ្ញុំបន្តធ្វើការដកស្ទូង គ្មានពេលសម្រាក និងគ្មានអាហារហូបគ្រប់គ្រាន់រហូតដល់ឆ្នាំ១៩៧៧។ នៅឆ្នាំ១៩៧៨ គាត់ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យមកធ្វើការនៅទីលានបោកស្រូវវិញ។ នៅទីនោះមានមនុស្សជាច្រើននាក់ធ្វើការ និងមានគោក្របីបីនឹម។ ម្តាយខ្ញុំត្រូវប្រើកម្លាំងដៃខ្លាំងដើម្បីបោកយកគ្រាប់ស្រូវ។ ដំបូងគាត់ត្រូវយកឃ្នាប ដើម្បីកៀបស្រូវចំនួន២កណ្តាប់ និងបោកលើបន្ទះក្តារដែលត្រូវបានដាក់ឲ្យទ្រេត។ ម្តាយខ្ញុំត្រូវបំពេញការងារបោកស្រូវជារៀងរាល់ថ្ងៃ។

នៅពេលដែលកងទ័ពវៀតណាមបានវាយចូលមកនៅដើមខែមករា ឆ្នាំ១៩៧៩ ម្តាយរបស់ខ្ញុំបានដើរស្វែងរកឪពុកម្តាយ បងប្អូន និងសាច់ញាតិដែលបានបែកបាក់ក្នុងរបបខ្មែរក្រហម និងបានជួបជុំគ្នាវិញ។ នៅឆ្នាំ១៩៨០ គាត់បានរៀបការជាមួយឪពុករបស់ខ្ញុំ និងបានប្រកបរបរធ្វើស្រែចម្ការ និងឡើងត្នោតយកទឹករំងាស់ធ្វើស្ករទៅលក់នៅផ្សារ ដើម្បីយកប្រាក់ចិញ្ចឹមជីវិត។



ផ្ទះរបស់ម្តាយខ្ញុំបច្ចុប្បន្នស្ថិតនៅភូមិ ឡឥដ្ឋ សង្កាត់បឹងកុក ក្រុងកំពង់ចាម ខេត្តកំពង់ចាម។ (កែម សុភី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទិដ្ឋភាពវាលស្រែនៅក្នុងខេត្តកំពង់ចាម។ (កែម សុភី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!



























# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

ដារ៉ារដ្ឋ មេត្តា

(តពីលេខមុន)

### ៦.១.៦. ការតាមដានសេចក្តីរាយការណ៍សារព័ត៌មានបរទេស

**៤៨០.** គណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក. បានបញ្ជាឲ្យក្រសួងឃោសនាការនិងព័ត៌មាននៃកម្ពុជាប្រជាធិបតេយ្យ « តាមដានដំណឹង[...] ឲ្យជាប់ រាល់ម៉ោង រាល់ថ្ងៃ » និងបញ្ជូនរបាយការណ៍ ដើម្បីធ្វើយ៉ាងណាអាចចាត់វិធានការសមស្របបាន។ បែបបទលម្អិតត្រូវបានបង្កើតឡើងសម្រាប់ក្រសួងឃោសនាការ និងព័ត៌មានធ្វើការសង្ខេបនិងរាយការណ៍អំពីដំណឹងបរទេសទាំងនេះជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍។ តាមសេចក្តីណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដល់បុគ្គលិកក្រសួងឃោសនាការ និងព័ត៌មាន ត្រូវតាមដានការផ្សាយព័ត៌មានបរទេសដែលបានផ្សាយជាភាសាអង់គ្លេស និងបារាំង។ សេចក្តីរាយការណ៍មកពីទីភ្នាក់ងារសារព័ត៌មានក្រៅប្រទេស និងសេវាកម្មព័ត៌មានបញ្ជូនទូរលេខ ត្រូវបានទទួលតាមរយៈទូរពុម្ពបន្ទាប់មកត្រូវបានថតចម្លង និងបកប្រែទៅជាភាសាខ្មែរសម្រាប់ចែកចាយបន្ត។

**៤៨១.** បុគ្គលិកនៅក្រសួងការបរទេសបានបំពេញការងារស្រដៀងគ្នាដូចជាការស្តាប់វិទ្យុបរទេសដែលផ្សាយអំពីកម្ពុជាប្រជាធិបតេយ្យ និងរៀបចំព្រឹត្តិប័ត្រសង្ខេបសម្រាប់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក.។ សាក្សី សួង ស៊ីគឿន ដែលធ្លាប់ធ្វើការនៅក្រសួងការបរទេសចាប់តាំងពីឆ្នាំ១៩៧៥ ហើយក្រោយមកបានក្លាយជាប្រធាននាយកដ្ឋានព័ត៌មាននិងឃោសនាការ នៅក្នុងឆ្នាំ ១៩៧៧ បានលើកឡើងថា គាត់និងសហការីរបស់គាត់ទទួលខុសត្រូវក្នុងការតាមដានកម្មវិធីផ្សាយជាភាសាបារាំង អង់គ្លេស ចិន និង វៀតណាម។ ពួកគាត់ត្រូវបានគេណែនាំឲ្យរាយការណ៍ជូន អៀង សារី អំពីព័ត៌មានដែលពួកគាត់បានស្តាប់ឮ ដោយមិនត្រូវបន្ថែមឬ បន្ថយព័ត៌មានឡើយ។

## ៦.២ ប្រព័ន្ធនៃទំនាក់ទំនងការងារ

**៤៨២.** លក្ខន្តិកៈ ប.ក.ក. បានកំណត់គោលការណ៍រួមថា «ថ្នាក់ក្រោមត្រូវរាយការណ៍ជូនថ្នាក់លើអំពីសភាពការណ៍និងអំពីកិច្ចការដែលខ្លួនបានធ្វើ » និង « ថ្នាក់លើជូនដំណឹងដល់ថ្នាក់ក្រោមអំពីសភាពការណ៍រួម និងអំពីសេចក្តីណែនាំដែលជាទិសការងារផ្សេងៗ»។

**៤៨៣.** ក្នុងការអនុវត្តជាក់ស្តែង កម្រិតនីមួយៗនៅក្នុងឋានានុក្រមនៃ ប.ក.ក. បានទំនាក់ទំនងគ្នាភាគច្រើនត្រឹមតែជាមួយ ថ្នាក់លើ នឹងថ្នាក់ក្រោមផ្ទាល់របស់ខ្លួនតែប៉ុណ្ណោះ។ ទំនាក់ទំនងខ្សែទទឹងនៅក្រៅគណៈកម្មាធិការមជ្ឈិមគឺមានតិចតួចៗ ជាទូទៅថ្នាក់តំបន់ (លើកលែងតែតំបន់ស្វយ័ត) ស្រុកនិងឃុំមិនមានទំនាក់ទំនងជាមួយនឹងគណៈកម្មាធិការមជ្ឈិមដោយផ្ទាល់ទេ តែត្រូវបញ្ជូននិងទទួលព័ត៌មានពីថ្នាក់លើឬថ្នាក់ក្រោមរបស់ខ្លួនតាមរយៈខ្សែបង្អាក់នៃការបញ្ជា។

### ៦.២.១. ទំនាក់ទំនងនៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស

**៤៨៤.** កំណត់ហេតុប្រជុំដែលនៅមានរហូតដល់ពេលនេះបានបង្ហាញថា គណៈកម្មាធិការមជ្ឈិមនិងគណៈកម្មាធិការអចិន្ត្រៃយ៍បានប្រជុំជាទៀងទាត់ ដើម្បីពិភាក្សាគ្នាអំពី

*គោលនយោបាយរបស់ ប.ក.ក.។ លើសពីនេះទៀត សមាជិកជាន់ខ្ពស់របស់ ប.ក.ក. ដែលរួមមានប៉ុល ពត, នួនជា និង ខៀវ សំផន បានជួបជុំគ្នាជាហូរហែរនៅមន្ទីរ ក-១ និងមន្ទីរ ក-៣។*

**៤៨៥.** *មេដឹកនាំ ប.ក.ក. ក៏បានឆ្លើយឆ្លងគ្នាតាមរយៈសំបុត្រផងដែរ។ ឧទាហរណ៍ សាក្សី អៀង តាន (ដែលធ្លាប់ធ្វើការនៅមន្ទីរ ក-១ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) បានចងចាំអំពីការបញ្ជូនសំបុត្រទៅវិញទៅមករវាង ប៉ុល ពត និង នួនជា ព្រមទាំងរវាង ប៉ុល ពត និង សុន សេន។ ដូចបានកត់សម្គាល់ខាងលើ ពេលខ្លះមន្ទីររបស់គណៈកម្មាធិការមជ្ឈិមក៏បានពិភាក្សាតាមទូរសព្ទអំពីបទបញ្ជា សំណើ និងព័ត៌មានផងដែរ។*

**៤៨៦.** *ជាធម្មតា ទូរលេខដែលគណៈកម្មាធិការមជ្ឈិមបានទទួលពីថ្នាក់ក្រោម គឺត្រូវបញ្ជូនទៅមន្ទីរ ក-១ ដើម្បីធ្វើការបកប្រែអក្សរសម្ងាត់ (ប្រសិនបើចាំបាច់) រៀបចំចាត់ថែង និងចែកចាយទៅតាមភាពសមស្រប។ សាក្សី អៀង តាន បានជម្រាបជូនអង្គជំនុំជម្រះថា ទូរលេខទាំងអស់ដែលគាត់បានយកទៅជូន ប៉ុល ពត ក្រោយមកត្រូវបានបញ្ជូនទៅឲ្យ នួន ជា ។ ក្រោយពីបានពិនិត្យលើទូរលេខនានានៅក្នុងសំណុំរឿង និងក្រោយពីបានស្តាប់ការបង្ហាញភ័ស្តុតាងដែលថាមានពិនិត្យលើទូរលេខនានានៅក្នុងសំណុំរឿង និងក្រោយពីបានស្តាប់ការបង្ហាញភ័ស្តុតាងដែលថាមានការប្រជុំនិងពិភាក្សាគ្នាជាញឹកញាប់រវាង នួន ជា និង ប៉ុល ពត និង ថាពួកគេបានធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធ អង្គជំនុំជម្រះជឿជាក់ថា ទូរលេខភាគច្រើនដែលគេបានបញ្ជូនទៅឲ្យ ប៉ុល ពត នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា ក៏បានទទួលផងដែរ។*

## ៦.២.២. ទំនាក់ទំនងរវាងគណៈកម្មាធិការមជ្ឈិម និង ភូមិភាគឬតំបន់ស្វយ័ត

**៤៨៧.** *ភូមិភាគនិងតំបន់ស្វយ័តបានរាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការមជ្ឈិម។ នៅក្នុងអង្គប្រជុំមួយដែលតំណាងភូមិភាគនិងតំបន់ស្វយ័តមួយចំនួនបានចូលរួម នៅខែមីនា ឆ្នាំ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍បានចេញសេចក្តីណែនាំស្តីពីនីតិវិធីជាធរមានសម្រាប់សរសេររបាយការណ៍ដូចតទៅ៖*

***ស្តីរាយការណ៍៖*** *ជូនអចិន្ត្រៃយ៍រាល់អាទិត្យអំពីសភាពការណ៍ក្តៅស្រេ។ ជូនណា រាយការណ៍ជាទិដ្ឋភាពរួម ជូនណារាយការណ៍តាមមុខព្រួញមួយៗ។ ស្តីរាយការណ៍ខ្លីៗតាមទូរលេខឲ្យអចិន្ត្រៃយ៍ដឹងសភាពការណ៍ ដើម្បីណែនាំបានទាន់ពេលវេលា។*

**៤៨៨.** *សេចក្តីណែនាំនេះត្រូវបានធ្វើឡើង ស្របតាមមតិយោបល់ដែលបានលើកឡើងនៅទស្សនាវដ្តី «ទង់បដិវត្ត» បោះពុម្ពក្នុងឆ្នាំ១៩៧២ ដែលក្នុងនោះបក្សបានលើកឡើងថា «យើងខ្វះខាតខាងរបាយការណ៍» បានណែនាំឲ្យរៀបចំធ្វើរបាយការណ៍ដើម្បីឲ្យ «ថ្នាក់លើក្តាប់សភាពការណ៍បានច្បាស់លាស់ ហើយណែនាំអនុវត្តជាក់ស្តែង»។ សេចក្តីណែនាំនេះបានណែនាំថា របាយការណ៍ជាក់លាក់និងទៀងទាត់ទាំងអស់ត្រូវរាយការណ៍ «អំពីខ្មាំង» «អំពីប្រជាជន» «អំពីសកម្មភាពការងារគ្រប់ផ្នែក» និង «អំពីទិសនិងវិធានការដោះស្រាយ»។*

**៤៨៩.** *ហេតុដូច្នេះ ភូមិភាគនិងតំបន់ស្វយ័តបានចងក្រងរបាយការណ៍ជូនគណៈកម្មាធិការមជ្ឈិមដោយផ្អែកលើព័ត៌មានដែលថ្នាក់ក្រោមបញ្ជូនមកឲ្យខ្លួន។ របាយការណ៍ទាំងនោះត្រូវបានផ្ញើចេញជាញឹកញាប់ ពេលខ្លះរាល់ថ្ងៃក៏មាន ទោះបីជារបាយការណ៍មួយចំនួនបានរៀបរាប់ដោយសង្ខេបអំពីព្រឹត្តិការណ៍នានា ដែលបានកើតឡើងយូរមកហើយក៏ដោយ។ របាយការណ៍ត្រូវបានបញ្ជូនតាមម៉ាស៊ីនផ្ញើទូរលេខ និងតាមសំបុត្រ។ ពេលខ្លះតំណាង ភូមិភាគនិងតំបន់ស្វយ័ត ក៏បានរាយការណ៍ដោយផ្ទាល់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ផងដែរ។*

**៤៩០.** *ភូមិភាគនីមួយៗមានរយៈពេល ដែលត្រូវបានកំណត់ទុកជាមុនជាក់លាក់សម្រាប់បញ្ជូនទូរលេខមកគណៈកម្មាធិការមជ្ឈិម។ ប៉ុន្តែ គេក៏អាចផ្ញើសារក្រៅពីរយៈពេលដែលបានកំណត់នេះផងដែរ ប្រសិនបើកាលៈទេសៈតម្រូវឲ្យធ្វើបែបនេះ។*

**៤៩១.** *របាយការណ៍មួយចំនួនដែលត្រូវបានផ្ញើមកគណៈកម្មាធិការមជ្ឈិម ត្រូវបានកំណត់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។ របាយការណ៍ទាំងនោះបានបង្ហាញថា ភូមិភាគ*



*ខៀវ សំផន គណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ (រូបខាងស្តាំជួរមុខ) និងគណៈប្រតិភូឡាវ ដឹកនាំដោយ ព្រះអង្គម្ចាស់ សុផានុវង្ស (រូបខាងឆ្វេងជួរមុខ) ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*តំបន់ស្វយ័តបានរាយការណ៍អំពីបញ្ហាផ្សេងៗ ដូចជា ការបង្កបង្កើនផលកសិកម្ម និងការប្រមូលផលស្រូវសកម្មភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង និងខ្មាំងខាងក្រៅ ប្រជាសាស្ត្រ រួមមានចំនួនគូស្រករដែលទើបរៀបអាពាហ៍ពិពាហ៍ថ្មីថ្មោង និងលក្ខខណ្ឌនៃការរស់នៅជាទូទៅ រួមមានបញ្ហាសុខភាព និងការខ្វះស្បៀងអាហារ។ សារដែលផ្ញើមកពីភូមិភាគក៏មានសំណូមពរសុំការសម្រេចសេចក្តីណែនាំលើបញ្ហាដូចគ្នាទាំងនេះ ឬស្នើសុំជំនួយសម្ភារពីគណៈកម្មាធិការមជ្ឈិមផងដែរ។*

**៤៩២.** *ជាទូទៅទូរលេខដែលផ្ញើមកពីភូមិភាគនិងតំបន់ស្វយ័តទៅគណៈកម្មាធិការមជ្ឈិមនោះ គឺត្រូវផ្ញើទៅ «គណៈ៨៧០» ឬ «អង្គការ» ប៉ុន្តែពេលខ្លះត្រូវបានផ្ញើទៅ «អង្គការ៨៧០» ឬទៅ ប៉ុល ពត ផ្ទាល់តែម្តង ។ ដូចអង្គជំនុំជម្រះបានកត់សម្គាល់រួចមកហើយថា កម្មាភិបាលនៃ ប.ក.ក. មិនមែនសុទ្ធតែយល់ថាពាក្យថា «អង្គការ» ឬ «៨៧០» ឲ្យបានច្បាស់លាស់នោះទេ។ បញ្ជីឈ្មោះអ្នកទទួលនៅលើទូរលេខជាច្រើនបញ្ជាក់ថា សារត្រូវបានចម្លងជូនមេដឹកនាំ ប.ក.ក. ជាច្រើននាក់រួមទាំង នួន ជា ផងដែរ។ ទូរលេខជាច្រើនដែលមានសរសេរជាកំណត់សម្គាល់ថា ចម្លងជូន «មន្ទីរ» ត្រូវបានគេបញ្ជូនទៅមន្ទីរ៨៧០។*

**៤៩៣.** *គណៈកម្មាធិការមជ្ឈិម បានបញ្ជូនសេចក្តីណែនាំរួមទៅថ្នាក់ក្រោមតាមរយៈទូរលេខ។ សេចក្តីណែនាំរួមនោះគឺមាន «គ្រប់ផ្នែកទាំងអស់នៃប្រទេស» និង «សភាពការណ៍រួម» ។ ខៀវ សំផន បានផ្ញើទូរលេខជា ទៀង ទាក់ទងនឹងការបែងចែកសម្ភារមូលដ្ឋាន ឬថ្នាក់ក្រោមៗ កម្មាភិបាលថ្នាក់ភូមិភាគ ឬថ្នាក់តំបន់ក៏បានទទួលសំបុត្រមកពីមន្ទីរ ៨៧០ និងថ្នាក់ដឹកនាំ ប.ក.ក. មួយចំនួនផងដែរ រួមទាំងសំបុត្រពី នួន ជា និង ខៀវ សំផន។*

## ៦.២.៣. ទំនាក់ទំនងរវាងភូមិភាគ និងតំបន់

**៤៩៤.** *នៅខណៈពេលមានការកំណត់ពេលវេលាជាក់លាក់សម្រាប់ការបញ្ជូនទូរលេខពីភូមិភាគទៅគណៈមជ្ឈិម ក៏មានកាលវិភាគពេលវេលាដាច់ដោយឡែកសម្រាប់ទំនាក់ទំនងរវាងភូមិភាគ និងតំបន់ផងៗ ការរៀបចំពេលវេលាបែបនេះត្រូវបានធ្វើឡើង ដើម្បីធានាថាទំនាក់*

ទំនងរវាងថ្នាក់ដឹកនាំផ្សេងៗមិនត្រូតគ្នាទេ។

៤៩៥. សាក្សី សួន កានិល ដែលធ្លាប់ធ្វើការនៅអង្គភាពបកប្រែលេខកូដទូរលេខនៃភូមិភាគកណ្ដាល បានផ្ដល់សក្ខីកម្មថា អាជ្ញាធរភូមិភាគកណ្ដាលបានទទួលលេខមកពីតំបន់ផ្សេងៗប្រហែលជាម្ដងក្នុងមួយថ្ងៃ ហើយទទួលបានកាន់តែញឹកញាប់ជាងនេះទៀតចាប់ពីឆ្នាំ១៩៧៨។

## ៦.២.៤. ទំនាក់ទំនងរវាងតំបន់ និងស្រុក

៤៩៦. របាយការណ៍មួយចំនួនពីថ្នាក់ស្រុកបានបញ្ជូនបន្តតាមរយៈថ្នាក់តំបន់ (ហើយក្នុងករណីខ្លះតាមរយៈភូមិភាគ) ទៅកាន់គណៈកម្មាធិការមជ្ឈិមបក្ស។

៤៩៧. ស្រុកបានរាយការណ៍ទៅតំបន់អំពីបញ្ហានានាដូចជាការលើកទំនប់ដីកប្រឡាយ ការបង្កបង្កើនផលសុខាភិបាល និង «សមាសភាពល្អឬមិនល្អ» ។ ក្នុងឋានៈជាលេខាស្រុកកំពង់សៀម សាក្សី ប្រាក់ យុត បានរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំខែសម្រាប់គណៈកម្មាធិការតំបន់ ស្ដីពីការអនុវត្តផែនការនិងសភាពការណ៍នៅក្នុងស្រុក។ ដូចគ្នានេះដែរ ក្នុងឋានៈជាលេខាស្រុកពេជ្រាដា សាក្សី សៅ សារុន បានរម្លឹកពីការផ្ញើរបាយការណ៍ស្ដីពីការបង្កបង្កើនផលស្រូវទៅថ្នាក់តំបន់ប្រហែលជាមួយដងក្នុងមួយសប្ដាហ៍។ មន្ទីរស្រុកមិនមានសមត្ថភាពប្រើម៉ាស៊ីនផ្ញើទូរលេខ។ ហេតុដូច្នេះ របាយការណ៍ជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជូនទៅតំបន់តាមរយៈនីរសារតែប៉ុណ្ណោះ។

៤៩៨. កម្មាភិបាលថ្នាក់ស្រុកនិងថ្នាក់តំបន់ ក៏បានជួបប្រជុំគ្នាជាទៀងទាត់ផងដែរ។ យោងតាមសាក្សី សៅ សារុន លេខាស្រុកមួយចំនួនបានរាយការណ៍



រូបទីពីររាប់ពីឆ្វេង៖ គណៈប្រតិភូទីម័រខាងកើត, សម សាន កម្មាភិបាលក្រសួងការបរទេស និងជាអតីតឯកអគ្គរដ្ឋទូតនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រចាំនៅប្រទេសកូរ៉េខាងជើង និងប្រទេស ឡាវ នៅឆ្នាំ១៩៧៧, ផៅ ពិន អ្នកបកប្រែភាសាអង់គ្លេសមកពីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ និង សារិន ឆាក អតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អំពីសភាពការណ៍នៅក្នុងស្រុករបស់ខ្លួននៅក្នុងអង្គប្រជុំនៃគណៈកម្មាធិការតំបន់ពាក់ព័ន្ធ។

៤៩៩. ខណៈពេលដែលសេចក្តីណែនាំផ្សេងៗ ពីគណៈកម្មាធិការមជ្ឈិមត្រូវបានបញ្ជូនទៅភូមិភាគហើយភូមិភាគបញ្ជូនបន្តទៅថ្នាក់តំបន់ អាជ្ញាធរតំបន់ក៏បានបញ្ជូនសេចក្តីណែនាំទាំងនោះបន្តទៅថ្នាក់ស្រុកផងដែរ។

### ៦.២.៥. ទំនាក់ទំនងរវាងស្រុក និងឃុំ

៥០០. កម្មាភិបាលថ្នាក់ស្រុកបានជួបគ្នាជាញឹកញាប់នឹងកម្មាភិបាលថ្នាក់ឃុំ ឬប្រធានសហករណ៍ ដើម្បីផ្លាស់ប្តូរព័ត៌មាន ឬបទបញ្ជាដែលខ្លួនបានទទួលដោយផ្ទាល់មាត់។ សាក្សី យុន គឹម ដែលជាមេឃុំក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានជម្រាបជូនអង្គជំនុំជម្រះថា ថ្នាក់ដឹកនាំឃុំបានជួបប្រជុំប្រចាំសប្តាហ៍ជាមួយអាជ្ញាធរស្រុក ដើម្បីរាយការណ៍ពីការបង្កបង្កើនផល សុខាភិបាល វប្បធម៌ និង «សភាពការណ៍ខ្មាំង» នៅក្នុងឃុំ។ ក្នុងករណីចាំបាច់ដែលត្រូវទំនាក់ទំនងគ្នានៅចន្លោះពេលនៃការប្រជុំប្រចាំសប្តាហ៍នោះ ស្រុកបានបញ្ជូននីសារចុះទៅដល់ឃុំផ្ទាល់។ សាក្សី នាង អ៊ួច ហៅ តាសាន (ជាប្អូនថ្លៃរបស់តាម៉ុករស់នៅស្រុកត្រាំកក់តាំងពីឆ្នាំ១៩៧៧ ក្រោយមកគាត់ក៏បានក្លាយជាលេខាស្រុក) បានផ្តល់សក្ខីកម្មស្រដៀងគ្នាផងដែរថា កម្មាភិបាលស្រុកបានជួបជាមួយប្រធានកងចល័ត ដើម្បីពិភាក្សាអំពីផែនការការងារ។

៥០១. ភស្តុតាងជាឯកសារដែលមានរហូតដល់ពេលនេះបង្ហាញថា ឃុំក៏បានបញ្ជូនសំណើ និងរបាយការណ៍ជាលាយលក្ខណ៍អក្សរជាប្រចាំទៅស្រុកស្តីពីបញ្ហាមួយចំនួនដូចជា ការចាប់ខ្លួនអាកប្បកិរិយាគួរឲ្យសង្ស័យ និងសភាពការណ៍នៅក្នុងឃុំនិងសហករណ៍។ សាក្សី ប្រាក់ យុត បានផ្តល់សក្ខីកម្មថា គណៈកម្មាធិការស្រុកដែលមានគាត់ជាសមាជិកនោះ បានទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរពីថ្នាក់ឃុំស្តីពីបញ្ហាកសិកម្ម គម្រោងសាងសង់ ការសម្រេចទិចដៅ «កំហុសឆ្គងរបស់ប្រជាជនខ្លះ» ការខ្វះខាតស្បៀងអាហារនិងចំនួនអ្នកឈឺ។ ក្នុងឋានៈជាលេខាស្រុកពេជ្រាដា សាក្សី សៅ សារុន ក៏បានចងចាំអំពីការទទួលបានរបាយការណ៍ពីឃុំនានាស្តីពីការបង្កបង្កើនផលស្រូវ សត្វពាហនៈ និងការចាត់ចែងមូលដ្ឋានជារួមផងដែរ។

### ៦.២.៦. ទំនាក់ទំនងក្រៅប្រទេស

៥០២. ស្ថាប័នរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យបានផ្ញើទូរលេខទៅកាន់ប្រទេសមួយចំនួន ដោយមានការជូនពរការសម្តែងសាមគ្គីភាព និងសារអបអរសាទរក្នុងឱកាសសំខាន់ៗមួយចំនួន។ ប្រទេសសង្គមនិយមជាមិត្តមួយចំនួនក៏បានផ្ញើសារស្រដៀងគ្នានេះត្រឡប់មកវិញផងដែរ។

៥០៣. ស្ថាប័នរដ្ឋនានានៃកម្ពុជាប្រជាធិបតេយ្យនិងមេដឹកនាំ ប.ក.ក. ក៏បានធ្វើការទំនាក់ទំនងជាមួយនឹងបណ្តាឯកអគ្គរាជទូតនៃប្រទេសមួយចំនួន ដែលទទួលការអនុញ្ញាតឲ្យមានតំណាងការទូតនៅកម្ពុជាប្រជាធិបតេយ្យ តាមរយៈកិច្ចប្រជុំនិងការជួបជុំសង្គមផងដែរ។

៥០៤. រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានរក្សាទំនាក់ទំនងជាមួយរដ្ឋមួយចំនួន តាមរយៈការបញ្ជូន និងទទួលគណៈប្រតិភូផ្លូវការពីប្រទេសមួយចំនួន ដូចជា ប្រទេសឡាវ ចិន កូរ៉េខាងជើង និងជប៉ុន។ ជាពិសេស របបកម្ពុជាប្រជាធិបតេយ្យបានផ្ញើនិងទទួលទូរលេខពីប្រទេសវៀតណាម ក្នុងគោលបំណងពិភាក្សាអំពីជម្លោះព្រំដែន និងបានទទួលទូរលេខពីប្រទេសចិន។ អ្នកសារព័ត៌មានមកពីប្រទេសយូហ្គោស្លាវី តួកគី កូរ៉េខាងជើង វៀតណាម អូស្ត្រាលី និង សហរដ្ឋអាមេរិក ក៏បានធ្វើទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនៅពេលនោះ អ្នកសារព័ត៌មានទាំងនោះបានសម្ភាសន៍កម្មាភិបាលក្នុងរបបនោះ និងបានចុះទៅពិនិត្យមើលតាមទីជនបទ ដែលអមដំណើរដោយកម្មាភិបាលរបស់រដ្ឋ ឬ កម្មាភិបាលរបស់បក្ស។

៥០៥. ក្រសួងពាណិជ្ជកម្មនៃកម្ពុជាប្រជាធិបតេយ្យ បានទំនាក់ទំនងជាមួយបណ្តាប្រទេសផ្សេងទៀត ក្នុងគោលបំណងដើម្បីធ្វើពាណិជ្ជកម្មអន្តរជាតិ។ គណៈប្រតិភូពាណិជ្ជកម្មបរទេស ក៏បានមកទស្សនកិច្ចនៅប្រទេសកម្ពុជាផងដែរនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ កិច្ចប្រជុំស្តីពីពាណិជ្ជកម្មជាមួយនឹងឯកអគ្គរដ្ឋទូតនៃបណ្តាប្រទេសនានាក៏បានប្រារព្ធធ្វើឡើងនៅក្រសួងពាណិជ្ជកម្មផងដែរ។

៥០៦. នៅចន្លោះឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩ អៀង សារី បានចូលរួមប្រជុំជាច្រើនលើកច្រើនសានៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក ដោយនៅពេលនោះ គាត់បានបង្ហាញជំហររបស់របបកម្ពុជាប្រជាធិបតេយ្យអំពីស្ថានភាពនៅក្នុងប្រទេសកម្ពុជា និងបញ្ហាអន្តរជាតិជាក់លាក់មួយចំនួន។ នៅពេលដែលកងទ័ពវៀតណាមបានវាយចូលមកជិតដល់ទីក្រុងភ្នំពេញនៅដើមឆ្នាំ១៩៧៩ អៀង សារី បានផ្ញើទូរលេខមួយច្បាប់ដែលជាបណ្ដឹងតវ៉ាជូនក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

## ៦.៣ ទំនាក់ទំនងផ្នែកយោធា

៥០៧. បណ្ដាលទំនាក់ទំនងនៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា បានឆ្លុះបញ្ចាំងអំពីរចនាសម្ព័ន្ធនៃការរាយការណ៍តាមខ្សែបណ្ដោយខាងផ្នែកស៊ីវិលរបស់ ប.ក.ក. ដែលការណ៍នេះមានន័យថា បទបញ្ជាចេញពីសេនាធិការទៅកាន់អង្គភាពថ្នាក់ក្រោមតាមរយៈកងពល។ ព័ត៌មានត្រូវបានរាយការណ៍ឡើងទៅថ្នាក់លើតាមរយៈកងពល។ ពត៌មានត្រូវបានរាយការណ៍ឡើងទៅថ្នាក់លើតាមរយៈខ្សែសង្វាក់នៃការបញ្ជា ហើយតាមធម្មតាមេបញ្ជាការនៅតាមកម្រិតនីមួយៗ ធ្វើការទំនាក់ទំនងតែជាមួយថ្នាក់លើនិងថ្នាក់របស់ខ្លួនតែប៉ុណ្ណោះ។

### ៦.៣.១. ទំនាក់ទំនងជាមួយនឹងមជ្ឈិមបក្ស

៥០៨. សុន សេន ដែលជានាយសេនាធិការ បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាច្រើនដង និងបានរាយការណ៍ជូនគណៈកម្មាធិការអំពីកិច្ចការយោធា និងបញ្ហាការពារជាតិ។ សុន សេន ក៏បានបញ្ជូនសារនិងរបាយការណ៍ជាលាយលក្ខណ៍អក្សរដែលទទួលបានពីមេបញ្ជាការយោធាបន្តទៅឲ្យមេដឹកនាំ ប.ក.ក. រួមទាំង នួន ជា ដោយមានចំណារផ្ទាល់ដៃនិងសំណើសុំការណែនាំផងដែរ។

### ៦.៣.២. ទំនាក់ទំនងរវាងសេនាធិការនិងកងពលធំ

៥០៩. កងពលធំដែលស្ថិតនៅក្រោម ការបញ្ជាផ្ទាល់គណៈកម្មាធិការមជ្ឈិមបានរាយការណ៍ជូនសេនាធិការប្រហែលជាពីរទៅបីដងក្នុងមួយថ្ងៃ។ កងពលធំសេនាធិការទំនាក់ទំនងគ្នាតាមរយៈវិទ្យុទាក់ទង ឬ ប្រសិនបើតម្រូវឲ្យមានការរក្សាការសម្ងាត់ពួកគេទំនាក់ទំនងគ្នាតាមរយៈទូរលេខ ទូរសព្ទ ឬផ្ញើសំបុត្រតាមរយៈនីរសារ។

៥១០. មេបញ្ជាការនិងអនុបញ្ជាការកងពលធំ និងកងវរសេនាធំឯករាជ្យ ក៏បានជួបប្រជុំជាប្រចាំជាមួយនឹង សុន សេន ដោយផ្ទាល់ផងដែរ។ នៅក្នុងអង្គប្រជុំទាំងនេះ មន្ត្រីយោធាបានរាយការណ៍ដល់ សុន សេន អំពីសភាពការណ៍នៅក្នុងអង្គភាពរបស់ខ្លួន ហើយ សុន សេន បានចេញបញ្ជា និង ផ្ដល់ការណែនាំផ្នែកនយោបាយ។ សាក្សី ព្រំ សារ៉ាត ជាមេបញ្ជាការកងវរសេនាធំ ១៨០ ដែលជាចំណុះកងពល ១៦៤ បានផ្ដល់សក្ខីកម្មថា សេនាធិការជាអ្នករៀបចំវគ្គរៀនសូត្រនយោបាយធំៗជារៀងរាល់ឆ្នាំ។ យ៉ាងហោចណាស់ ក៏មានវគ្គរៀនសូត្រនយោបាយធំមួយ ដែលរៀបចំឡើងដោយសេនាធិការ និងទទួលការណែនាំពី សុន សេន ដោយមានការចូលរួមពីកងទ័ពមកពីថ្នាក់កងពល កងវរសេនាធំ កងវរសេនាតូច កងអនុសេនាធំ និងកងអនុសេនាតូច។ ពេលខ្លះកម្មាភិបាលយោធាក៏បានចូលរួមនៅក្នុងអង្គប្រជុំ ឬសន្និបាតធំៗនៅក្នុងភ្នំពេញផងដែរ ដោយអង្គប្រជុំ ឬសន្និបាតខ្លះមានការចូលរួមពីសំណាក់មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក. រួមមាន នួន ជា និង ខៀវ សំផន ផងដែរ។

៥១១. របាយការណ៍ជាលាយលក្ខណ៍អក្សរដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ បានបង្ហាញថា កងពលបានបញ្ជូនព័ត៌មានស្ដីពីសកម្មភាពខ្មាំង កសិកម្មនិងការធ្វើស្រែខ្មាំងផ្ទៃក្នុង និងសកម្មភាពវិទ្ធង្សនានៅក្នុងអង្គភាព និងវឌ្ឍនភាពគម្រោងសាងសង់នានាទៅសេនាធិការទៀងទាត់។ កងពលទាំងនោះក៏បានទាក់ទងសេនាធិការដើម្បីស្នើសុំយោបល់ផ្សេងៗផងដែរ។

### ៦.៣.៣. ទំនាក់ទំនងរវាងកងពលនិងភូមិភាគ

៥១២. កងពលយោធាមួយចំនួន ដែលមិនស្ថិតក្រោមបញ្ជាការរបស់មជ្ឈិមបក្សត្រូវរាយការណ៍ទៅឲ្យខាងភូមិភាគ។ ឧទាហរណ៍ សក្សី មាស សារឿន ដែលជាអនុបញ្ជាការកងពលលេខ១ (ឈរជើងនៅខេត្តកោះកុង) បាន

*កម្មាភិបាលខ្មែរក្រហមជូនដំណើរគណៈប្រតិភូបរទេសទស្សនាទេសភាពនៅតាមដងទន្លេ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



ផ្តល់សក្ខីកម្មថា កងពលរបស់គាត់ត្រូវធ្វើការរាយការណ៍ទៅឲ្យភូមិភាគបស្ចិម។ ផ្ទុយទៅវិញសាក្សី ម៉ឹង វេត មកពីកងពល ១១៧ នៃតំបន់៥០៥ (ខេត្តក្រចេះ) បានផ្តល់សក្ខីកម្មថា កងពលរបស់គាត់បានរាយការណ៍ទៅសេនាធិការ (ឬទៅកងពល ៥០២ របស់មជ្ឈិមដែលនឹងជួយពួកគេក្នុងការចម្លងសារ) ហើយរាយការណ៍ទៅមន្ទីរ ៨៧០ ដោយផ្ទាល់ ក្រោមលក្ខខណ្ឌជាក់លាក់ប៉ុណ្ណោះ។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ប្រព័ន្ធរាយការណ៍មានភាពខុសគ្នាទៅតាមកងពលនីមួយៗ និងទៅតាមកាលៈទេសៈ។

### ៦.៣.៤. ទំនាក់ទំនងនៅក្នុងកងពលធំ

**៥១៣.** បន្ទាប់ពីទទួលបានបទបញ្ជាពីសេនាធិការ មេបញ្ជាការកងពលធំនឹងបញ្ជូនសេចក្តីណែនាំទាំងនេះបន្តទៅអង្គភាពថ្នាក់ក្រោម ហើយជាទូទៅ គឺតាមរយៈការជួបជុំជាមួយនឹងកម្មាភិបាលឬ ជួបជាមួយនឹងមេដឹកនាំរបស់ខ្លួនផ្ទាល់តែម្តង។ ដូចគ្នានេះដែរ បទបញ្ជាទាំងនេះត្រូវបានបញ្ជូនទៅអង្គភាពថ្នាក់ក្រោមតាមរយៈកងវរសេនាធំ ឬកងវរសេនាតូច។

**៥១៤.** មេបញ្ជាការនិងអនុបញ្ជាការកងពលធំព្រមទាំងថ្នាក់ក្រោមៗរបស់ខ្លួនបានធ្វើទំនាក់ទំនងគ្នាតាមរយៈវិទ្យុទាក់ទង តាមរយៈទូរលេខ តាមរយៈនីរសារ និងតាមរយៈការជួបផ្ទាល់តែម្តង។

**៥១៥.** មេបញ្ជាការកងអនុសេនាធំរាយការណ៍ជូនប្រធានរបស់ខ្លួនជាលាយលក្ខណ៍អក្សរ និងតាមរយៈវិទ្យុទាក់ទង។ មេបញ្ជាការកងវរសេនាតូចបញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅមេបញ្ជាការកងវរសេនាធំតាមរយៈនីរសារ។ ដូចនេះផងដែរ កងវរសេនាធំបញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅកងពលធំតាមរយៈទូរលេខ និងនីរសារ ដែលការបញ្ជូននេះត្រូវធ្វើឡើងយ៉ាងហោចណាស់មួយខែម្តង។

### ៦.៣.៥. ទំនាក់ទំនងរវាងកងពលធំ

**៥១៦.** អង្គជំនុំជម្រះបានស្តាប់ភស្តុតាងដែលមិនមានភាពច្បាស់លាស់ ពាក់ព័ន្ធនឹងកម្រិតនិងវិសាលភាពនៃទំនាក់ទំនងការងាររវាងកងពល។ សាក្សី ម៉ឹង វេត បានផ្តល់សក្ខីកម្មថា មេបញ្ជាការ រឿន (គឺ សូ សារឿន) នៃកងពល ៨០១ (កងពលរបស់មជ្ឈិម) និងមេបញ្ជាការ រ៉ុំ នៃកងពល ១១៧ (ខេត្តក្រចេះ តំបន់៥០៥) មិនបានធ្វើទំនាក់ទំនងគ្នាតាមរយៈសេនាធិការនោះទេ ប៉ុន្តែពួកគាត់បានទាក់ទងគ្នាដោយផ្ទាល់តាមរយៈវិទ្យុទាក់ទង ឬទូរលេខ។ សាក្សី មាស វឿន ក៏បានផ្តល់សក្ខីកម្មផងដែរថា ទំនាក់ទំនងខ្សែទទឹងរវាងកងពលធំ យ៉ាងហោចណាស់ក៏បានធ្វើឡើងក្នុងភូមិភាគបស្ចិម នៅថ្នាក់កងវរសេនាធំ ក្នុងគោលបំណងដើម្បីសម្របសម្រួលភារកិច្ច។ ទោះបីជាយ៉ាងណាក្តី សាក្សី ជួន ធី បានផ្តល់សក្ខីកម្មថា មិនមានទំនាក់ទំនងការងាររវាងកងវរសេនាធំដែលគាត់ឈរជើងនៅខេត្តស្វាយរៀង នៅក្នុងភូមិភាគបូព៌ានោះទេ។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ទំនាក់ទំនងរវាងកងពលមួយចំនួនត្រូវបានធ្វើឡើងនៅពេលដែលកាលៈទេសៈតម្រូវ និងបានអនុញ្ញាត។

## ៧ តួនាទីនិងមុខងាររបស់ នួន ជា

**៥១៧.** យោងតាមដីកាដំណោះស្រាយ នៅមុននិងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា គឺជាសមាជិកសំខាន់មួយរូបរបស់មជ្ឈិមបក្ស ហើយគាត់ទទួលខុស

ត្រូវក្នុងការឃោសនាបណ្ដុះបណ្ដាលបញ្ញាវិន័យរបស់កម្មាភិបាល ព្រមទាំងបញ្ហាដែលទាក់ទងនឹងសន្តិសុខខាងក្នុង និងខាងក្រៅ។

**៥១៨.** នៅពេលចាប់ផ្ដើមសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០១ នួន ជាបានលើកឡើងធ្វើសេចក្ដីថ្លែងបើក។ ក្រោយពេលបើកសវនាការនោះមក នៅក្នុងអំឡុងវគ្គសវនាការលើបរិបទប្រវត្តិសាស្ត្រក្នុងសំណុំរឿង០០២/០១ នួន ជា បានយល់ព្រមឆ្លើយនឹងសំណួររបស់ចៅក្រម និងភាគីនានា។ គាត់បានឆ្លើយបញ្ជាក់អំពីតួនាទីនិងមុខងារដទៃទៀតរបស់ គាត់នៅក្នុង ប.ក.ក. ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូចដែលបានកត់សម្គាល់បន្ថែមខាងក្រោម នួន ជា បានបញ្ជាក់អំពីទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងយូរមកហើយជាមួយនឹងបក្ស រួមទាំងតួនាទីរបស់គាត់ជាអនុលេខាបក្ស និងជាសមាជិកនៅក្នុងគណៈកម្មាធិការមជ្ឈិមនិងគណៈកម្មាធិការអចិន្ត្រៃយ៍។ ទោះបីជា នួន ជា បានឆ្លើយបដិសេធនូវតួនាទីផ្លូវការ នៅក្នុងគោលនយោបាយយោធាក៏ដោយ ក៏គាត់បានឆ្លើយបញ្ជាក់អំពីតួនាទី និងមុខងារផ្សេងៗទៀត នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំង ការតែងតាំងគាត់ជាប្រធានសភាតំណាងប្រជាជន និងការទទួលខុសត្រូវទាក់ទងនឹងការបំពាក់បំប៉នកម្មាភិបាលនិងការឃោសនា។ ក្រោយមក នួនជា បានសម្រេចប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួររបស់ចៅក្រមនិងភាគីនានា។ នៅថ្ងៃសវការចុងក្រោយក្នុងសំណុំរឿង ០០២/០១ នួនជា បានធ្វើសេចក្ដីថ្លែងចុងក្រោយនៅចំពោះមុខអង្គជំនុំជម្រះ។

**៥១៩.** នៅពេលចាប់ផ្ដើមសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង០០២/០២ នួន ជា បានលើកឡើងធ្វើសេចក្ដីថ្លែងបើក។ គាត់បានលើកឡើងថា គាត់នឹងប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរនានា។ នៅក្នុងអំឡុងសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ នួន ជា បាននិយាយពីរដងបីដង ដូចជា គាត់បានចោទជាសំណួរចំនួនពីរទៅកាន់អ្នកជំនាញ Elizabeth BECKER នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ គាត់បានបង្ហាញការយល់ឃើញអំពីភាពអាចទុកចិត្តបាននៃភស្តុតាងនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៦ និងគាត់បានឡើងថ្លែងនៅក្នុងអំឡុងពេលសវនាការស្ដីពីមន្ទីរសន្តិសុខ ស-២១ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ដើម្បីបង្ហាញពីការយល់ឃើញរបស់គាត់ អំពីជម្លោះប្រដាប់អាវុធជាមួយវៀតណាម និងតួនាទីរបស់វៀតណាម ចំពោះរបបកម្ពុជាប្រជាធិបតេយ្យនៅពេលនោះ។ នៅថ្ងៃសវនាការចុងក្រោយសំណុំរឿង ០០២/០២ នួនជា បានបដិសេធមិនធ្វើសេចក្ដីថ្លែងចុងក្រោយនៅចំពោះមុខអង្គជំនុំជម្រះឡើយ។

## ៧.១ ព័ត៌មានអំពីសាវតារ និងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ

**៥២០.** នួន ជា ដែលមានឈ្មោះកំណើត ឡៅ គឹមលន កើតនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩២៦ នៅភូមិវត្តគ ឃុំវត្តគ ស្រុកសង្កែ ខេត្តបាត់ដំបង។ ដំបូង នួន ជា បានសិក្សានៅក្នុងខេត្តបាត់ដំបង ហើយក្រោយមកគាត់បានបន្តការសិក្សាថ្នាក់អនុវិទ្យាល័យនៅប្រទេសថៃនៅឆ្នាំ១៩៤១ បន្ទាប់មកទៀត គាត់បានសិក្សាច្បាប់នៅសាកលវិទ្យាល័យ Thammasat នៅទីក្រុងបាងកក ដោយពេលនោះគាត់បានប្រើឈ្មោះ Runglert Laodi ។ ក្នុងអំឡុងពេលនោះ គាត់ក៏បានបម្រើការងារនៅក្រសួងហិរញ្ញវត្ថុ និងក្រសួងការបរទេសប្រទេសថៃផងដែរ។ នៅអំឡុងពេលដែលគាត់នៅក្នុងប្រទេសថៃ នួន ជា បានចូលរួមជាមួយចលនាយុវជន ដើម្បីលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសថៃ និងបានចូលរួមនៅក្នុងការពិភាក្សាអំពីស្ថានការណ៍នៅក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ១៩៤០ គាត់បានចូលរួមជាមួយបក្សកុម្មុយនីស្តថៃ ហើយក្រោយមកបានត្រឡប់មកប្រទេសកម្ពុជាដើម្បីចូលរួមនឹងខ្មែរឥស្សរៈដែលជាចលនាតស៊ូប្រឆាំងនឹងអាជ្ញាធរអាណានិគមនិយមបារាំង។

**៥២១.** ប្រហែលពេលនោះ នួន ជា បានចូលរួមក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន ដោយគាត់បានផ្ដល់មូលហេតុថា គាត់ព្រួយបារម្ភអំពីការប្រព្រឹត្តចំពោះកសិករកម្ពុជាអំពីសំណាក់មន្ត្រីអាណានិគមនិយមបារាំងនិងពួកអ្នកមានជាជនជាតិខ្មែរដែលជាម្ចាស់ដី។ ចាប់ពីអំឡុងឆ្នាំ១៩៥០ នួន ជា មាន

សភាពសកម្មកាន់តែខ្លាំងនៅពេលដែលគាត់បានចូលរួមនៅក្នុងសកម្មភាពអប់រំឃោសនា ដែលរួមទាំងការបោះពុម្ពផ្សាយព័ត៌មាន និងបើកវគ្គបណ្តុះបណ្តាលសម្រាប់កសិករនៅតំបន់ជនបទ។

**៥២២.** ក្នុងចន្លោះឆ្នាំ១៩៥១ ដល់ឆ្នាំ១៩៥៤ នួន ជា ត្រូវបានបក្សបញ្ជូនឲ្យទៅសិក្សា និងទទួលការបណ្តុះបណ្តាលនយោបាយនៅប្រទេសវៀតណាម។ ក្រោយពីកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវក្នុងខែ ឧសភា ឆ្នាំ១៩៥៤ គាត់បានត្រឡប់មកប្រទេសកម្ពុជាវិញ ហើយបានអះអាងថាសមាជិកបក្សត្រូវបានគេចាប់ខ្លួន ឃុំខ្លួន ឬ បានចាកចេញពីចលនាតស៊ូនេះ ហើយថាសកម្មភាពធ្វើស្រែចម្ការរបស់កសិករត្រូវបានរារាំងដោយគោលនយោបាយតឹងតែងរបស់រដ្ឋាភិបាល។ មុនពេលមកតាំងទីលំនៅក្នុងក្រុងភ្នំពេញ នាឆ្នាំ១៩៥៥ នួន ជា បានផ្លាស់ទីលំនៅមួយចំនួននៅទីជនបទ ដូចជា នៅបឹងល្វា តាមដងស្ទឹងជីនិត និងនៅសំឡូត ដើម្បីលាក់បាំងការចូលរួមដ៏សកម្មរបស់គាត់នៅក្នុងចលនាតស៊ូមតិ និងដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួនផងដែរ។

**៥២៣.** នៅទីក្រុងភ្នំពេញ នួន ជា បានបន្តការងារជាសម្ងាត់នៅក្នុងចលនាបដិវត្តន៍ តាមរយៈការចូលរួមជាមួយគណៈកម្មាធិការបក្សក្រុង។ នួន ជា ត្រូវបានគេណែនាំឲ្យស្គាល់ ប៉ុល ពត នៅចន្លោះឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៥៥ ក្រោយពេល នួន ជា បានវិលត្រឡប់មកពីប្រទេសវៀតណាមវិញ។ ប៉ុល ពត នួន ជា ដែលអ្នកទាំងពីរជាសមាជិកបក្សប្រជាជនបដិវត្តន៍កម្ពុជា បានធ្វើការងារជាមួយគ្នាជាលើកដំបូងជាជំនួយការឲ្យ ទូ សាមុត។ ក្រោយមកនៅក្នុងឆ្នាំ១៩៦០ នួន ជា បានជួបជាមួយ អៀង សារី នៅក្នុងឱកាសមហាសន្និបាតបក្សលើកទី១ ដែលពេលនោះ ទូ សាមុត ត្រូវបានតែងតាំងជា លេខាបក្ស នួន ជា ត្រូវបានតែងតាំងជាអនុលេខាបក្ស ហើយបក្សត្រូវបានប្តូរឈ្មោះជាបក្សពលករកម្ពុជា។

**៥២៤.** នៅក្នុងខែមីនា ឆ្នាំ១៩៦៣ ប៉ុល ពត ,អៀង សារី, ខៀវ សំផន និង សុន សេន ក្នុងចំណោមបុគ្គលចំនួន ៣៤ នាក់ ដែលសម្តេច នរោត្តម សីហនុ ចាត់ទុក និងសង្ស័យថា «ពួកឆ្វេងនិយម» ត្រូវបានសម្តេច នរោត្តម សីហនុ កោះហៅ រួមជាមួយនឹងបុគ្គលផ្សេងៗទៀត ក្រោមលេសថាបានបង្កើតរដ្ឋាភិបាលថ្មីមួយ។ ដោយភ័យខ្លាចអំពីការចាប់ខ្លួន អៀង សារី និង ប៉ុល ពត បានចូលរួមជាមួយក្រុមសម្ងាត់មួយនៅក្បែរព្រំដែនវៀតណាម ខណៈដែលនួន ជា បន្តនៅក្រុងភ្នំពេញ។

**៥២៥.** ចាប់ពីឆ្នាំ១៩៦២ នួន ជា បានធ្វើដំណើរទៅតាមទីជនបទដើម្បីជួបជាមួយមេដឹកនាំ ចលនាផ្សេងៗទៀត រួមទាំង ប៉ុល ពត, អៀង សារី និង សុន សេន។ គាត់ក៏បានជួបជាមួយ វន វ៉េត, កែ ពក,សោ ភឹម, កុយ ធួន, រស់ ញឹម នៅពេលដែលមានចលនាបដិវត្តន៍បានរីកចម្រើនទៅមុខៗ ម្តងម្កាល នួន ជា បានធ្វើដំណើរជាសម្ងាត់ពីទីក្រុងភ្នំពេញទៅកាន់មន្ទីរបក្សសំខាន់ៗ រួមទាំងមន្ទីរ ១០០ ដែលដំបូងមានទីតាំងនៅតំបន់ព្រំដែនជាមួយវៀតណាម។ ចាប់ពីឆ្នាំ១៩៦៦ ដល់១៩៦៧ គាត់បានធ្វើដំណើរទៅកាន់



ទស្សនាវដ្តីបោះពុម្ពនៅខែកញ្ញា ឆ្នាំ១៩៧៦ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មន្ទីរ១០០ថ្មី ដែលមានទីតាំងនៅខេត្តរតនគិរី ហើយចាប់ពីឆ្នាំ១៩៧០ គាត់បានធ្វើដំណើរទៅកាន់មន្ទីរ ស-៧១ ដែលមានទីតាំងនៅតាមដងស្ទឹងជីនិត។ ក្រោយមក នៅពេលខ្មែរក្រហមចូលមកជិតដល់ទីក្រុងភ្នំពេញ គាត់ក៏បានធ្វើទស្សនកិច្ច ប-៥ ខេត្តមួយចំនួន និងភូមិភាគផ្សេងៗទៀត ដែលគ្រប់គ្រងដោយខ្មែរក្រហម។

**៥២៦.** *យោងតាម នួន ជា គាត់បានជួបជាមួយ ខៀវ សំផន លើកដំបូងនៅជិតភ្នំឱរ៉ាល់ក្រោយពេល ខៀវ សំផន រត់ចូលព្រៃម៉ាគី ប៉ុន្តែគាត់ពុំចាំបានថា នៅពេលណានោះឡើយ។ ដូចបានកត់សម្គាល់នៅក្នុងចំណុចខាងក្រោមក្នុងផ្នែក ៨ ខៀវ សំផន បងចាំខុសពីហេតុការណ៍នេះទៅវិញ ហើយបានលើកឡើងថា គាត់បានជួប នួន ជា និង ប៉ុល ពត លើកដំបូងនៅ ស-៧១។ អង្គជំនុំជម្រះជឿជាក់ថា ខៀវ សំផន និង នួន ជា ស្គាល់គ្នានៅពេលពួកគេជាសមាជិក ប.ក.ក. នៅត្រឹមខែកញ្ញា ឆ្នាំ១៩៧០។*

**៥២៧.** *ក្នុងឆ្នាំ១៩៧០ នៅពេលសម្តេច នរោត្តម សីហនុ ត្រូវបានទម្លាក់ចេញពីអំណាច នួន ជា បានធ្វើដំណើរទៅកាន់ភូមិភាគបូព៌ា ហើយបានត្រឡប់មកភ្នំពេញវិញក្នុងរយៈពេលពីរបីខែក្រោយមក។ ពេលគាត់នៅទីនោះ គាត់បានបន្តធ្វើដំណើរទៅជួប ប៉ុល ពត និង អៀង សារី ដើម្បីពន្យល់ពួកគាត់អំពីស្ថានការណ៍នៅទីក្រុងភ្នំពេញ និងដើម្បីទទួលការណែនាំពី ប៉ុល ពត។ នៅពេលដែលបដិវត្តន៍មានការរីកចម្រើនទៅមុខ នួន ជា បានចាកចេញពីទីក្រុងភ្នំពេញ ហើយបានចូលរួមជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតរបស់បក្សនៅមន្ទីរ ស-៧១។*

**៥២៨.** *នៅប៉ុន្មានឆ្នាំដំបូងនៃការធ្វើនយោបាយយ៉ាងសកម្មរបស់គាត់នៅប្រទេសកម្ពុជា ការទទួលខុសត្រូវសំខាន់របស់ នួន ជា នៅក្នុងបក្ស រួមមាន ការចូលរួមបង្កើតគោលនយោបាយបក្ស និងមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធី ជាមួយនឹង ប៉ុល ពត ។ នួន ជា ក៏បានបន្តសកម្មភាពផ្តោតទៅលើការផ្សារឃោសនាផងដែរ តាមរយៈការធ្វើដំណើរទៅតាមជនបទ ដើម្បីប្រមូលកម្មាភិបាល និងបើកវគ្គបណ្តុះបណ្តាលដល់កសិករ និងមេដឹកនាំចលនាតស៊ូនៅថ្នាក់មូលដ្ឋាន។ គាត់ក៏ជាបុគ្គលសំខាន់ម្នាក់ក្នុងការចេញទស្សនាវដ្តីទង់បដិវត្តផងដែរ ដែលបានបកស្រាយលម្អិតខាងក្រោម ពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ ជាចុងក្រោយ នៅពេលដែល នួន ជា បានធ្វើការផ្សារទាក់ទងនឹងការអភិវឌ្ឍគោលនយោបាយបក្ស ដែលឯករាជ្យពេញលេញពីបក្សកុម្មុយនីស្តវៀតណាម ជាបណ្តើរៗនោះ គាត់ក៏បានដើរតួនាទីជាអ្នកទំនាក់ទំនងជាមួយបក្សកុម្មុយនីស្តវៀតណាម ដោយធ្វើដំណើរទៅកាន់ប្រទេសវៀតណាមជាច្រើនលើក ដើម្បីជួបជាមួយមេដឹកនាំបក្សកុម្មុយនីស្តវៀតណាម។*

**៥២៩.** *នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា ត្រូវបានគេហៅនាមត្រកូលរបស់គាត់ថា«បងនួន» ឬ «អ៊ំនួន» ព្រមទាំង «សមមិត្តអនុលេខា» ឬ ជាទូទៅហៅ «បង» «បងជាទីគោរព» «បងជាទីស្នេហា» និង «បងធំទីពីរ»។ ទោះបីជា គាត់បដិសេធថាមិនបានធ្វើឈ្មោះ ឬត្រូវបានគេហៅជាទូទៅថា «បងធំទីពីរ» ក៏ដោយ ក៏មានភស្តុតាងបង្ហាញផ្ទុយពីការលើកឡើងនេះ និងមានលក្ខណៈអាចជឿជាក់បាន។ សាក្សីមួយចំនួនបានបញ្ជាក់ថា ឈ្មោះហៅក្រៅនេះ ត្រូវបានប្រើសំដៅចំពោះ នួន ជា ។ ឈ្មោះហៅក្រៅទាំងនេះ ក៏ត្រូវបានលើកឡើងនៅក្នុងទូរលេខ និងរបាយការណ៍ជាច្រើន ដែលពាក់ព័ន្ធនឹងសកម្មភាពរបស់គណៈកម្មាធិការមជ្ឈិមបក្ស ក៏ដូចជា នៅក្នុងចំណាររបស់កម្មាភិបាលទៅលើចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ រួមទាំងសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលបានផ្ញើជូនឬចម្លងជូន នួន ជា។ ជាពិសេស សាក្សី សួន កានិល ដែលជាការីទូរលេខនៃភូមិភាគកណ្តាល ដែលបានរៀបចំទូរលេខដែលទាក់ទងនឹងគណៈកម្មាធិការមជ្ឈិមបក្សបានលើកឡើងថា ការប្រើពាក្យថា «អ៊ំនួន» លើទូរលេខផ្ញើទៅកាន់មន្ទីរ ៨៧០ «ជាការពិត» គឺសំដៅចំពោះ នួន ជា ។ ក្នុងអំឡុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលបានធ្វើឡើងនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ ១៩៧៦ ប៉ុល ពត ដែលត្រូវបានកំណត់ថាជាប្រធានគណៈកម្មាធិការនេះ បានហៅ នួន ជា ថា «សមមិត្ត នួន» ។*

**(តនៅលេខក្រោយ)**

# ភាពខុសគ្នារវាងការថែទាំសុខភាព របស់មេដឹកនាំខ្មែរក្រហម និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

ព្រាំ ផល្លា

យុត្តិធម៌អាចមានអត្ថន័យច្រើនយ៉ាង និងសណ្ឋានផ្សេងៗគ្នា។ សណ្ឋានមួយនៃយុត្តិធម៌ គឺជាសិទ្ធិទទួលបាននូវទម្រង់មួយចំនួន នៃការថែទាំសុខភាពសេវាកម្មវេជ្ជសាស្ត្រ និងសេវាកម្មសុខភាពផ្លូវចិត្ត។ នៅក្នុងប្រទេសកម្ពុជា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ភាគច្រើនយល់ឃើញថា ការដែលត្រូវចោទប្រកាន់ថា ជាមេដឹកនាំខ្មែរក្រហម បុគ្គលនោះប្រាកដជាអាចទទួលបាននូវអត្ថប្រយោជន៍។ នេះដោយសារតែស្ថិតនៅក្នុងការឃុំឃាំង ឬការជាប់ពន្ធនាគារ ទោះបីជាបុគ្គលជាប់ចោទនោះល្អ ឬ អាក្រក់ បុគ្គលនោះនៅតែទទួលបានការថែទាំសុខភាពយ៉ាងល្អប្រសើរ រួមទាំងមានមនុស្សនៅហែហមថែទាំ និងការពារ។

មេដឹកនាំរបបខ្មែរក្រហម ទទួលបានការថែទាំសុខភាពប្រសើរហួសពីការថែទាំដែលជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដទៃទៀត អាចទទួលបានសព្វថ្ងៃនេះ។ ចំណុចនេះ ត្រូវបានលើកឡើងដោយមេដឹកនាំខ្មែរក្រហមផ្ទាល់ ក៏ដូចជា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដទៃទៀត។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ ដែលបម្រើការងារនៅឯទីតាំងឃុំខ្លួន នួន ជា បានប្រាប់ថាលោកបានស្តាប់ឮ នួន ជា និយាយថា ប្រសិនបើគាត់នៅផ្ទះ គាត់អាចនឹងស្លាប់តាំងពីយូរយារណាស់មកហើយ។ នួន ជា បានទទួលស្គាល់ថាការថែទាំសុខភាព ដែលខ្លួនទទួលបាននៅក្នុងមន្ទីរឃុំឃាំង គឺល្អហួសពីអ្វីដែលខ្លួនអាចទទួលបាននៅផ្ទះ។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើន ក៏បានដឹងអំពីរឿងនេះ ព្រមទាំងបានសម្តែងនូវសេចក្តីខកចិត្តជាខ្លាំង។ ជុំ ម៉ី អ្នករស់រានមានជីវិតម្នាក់ពីមន្ទីរ ស-២១ បានលើកឡើងថា ខណៈពេលដែល នួន ជា រស់នៅក្នុងបន្ទប់ម៉ាស៊ីនត្រជាក់ ទទួលបានរបបអាហារបីពេលក្នុងមួយថ្ងៃ មានកន្លែងកម្សាន្ត និងការផ្តល់ផាសុកភាពផ្សេងៗ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើន អង្គុយលើផ្ទៃដីកខ្វក់ ដោយមិនទទួលបានការថែទាំ ឬការគាំពារអ្វីទាំងអស់។

តាមវិធានច្បាប់ ដើម្បីបម្រើដល់សិទ្ធិមនុស្ស ការផ្តល់ការថែទាំផ្នែកវេជ្ជសាស្ត្រដល់ជនជាប់ចោទ និងជនដៃដល់ដែលជាប់ទោសពីបទសម្លាប់រង្គាល គឺជាការចាំបាច់។ ផ្ទុយទៅវិញ តើសិទ្ធិរបស់ជនរងគ្រោះស្ថិតនៅឯណា?

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានបញ្ជាក់យ៉ាងច្បាស់ថា "យុត្តិធម៌អន្តរកាល ត្រូវតែរួមបញ្ចូល លើសពីអ្វីដែលជាសំណងនិមិត្តរូប ដែលត្រូវរួមផ្សំនូវសកម្មភាពដែលយ៉ាងហោចណាស់ជួយធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពរបស់អ្នករស់រានមានជីវិត"។

យុត្តិធម៌ដែលប្រកបដោយអត្ថន័យ មិនត្រឹមតែត្រូវចាប់ផ្តើមចេញពីកិច្ចខិតខំប្រឹងប្រែងស្វែងរកយុត្តិធម៌នៅក្នុងបន្ទប់សវនាការប៉ុណ្ណោះទេ ប៉ុន្តែត្រូវរួមបញ្ចូលកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចបានយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថែមទៀតផង។ យើងអាចចាប់ផ្តើមដោយផ្តល់ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនូវទម្រង់មួយចំនួននៃការថែទាំសុខភាព ការគាំពារ និងសេវាកម្មដែលជួយធ្វើឲ្យប្រសើរឡើង នូវសុខុមាលភាពរបស់អ្នកទាំងអស់នោះ។



រូបពីឆ្វេង ៖ នួន ជា និងជំនួយការរបស់គាត់ ព្រំ ផល្លា។ (ប្រភពរូបថត៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)

# នៅតែទន្ទឹងរង់ចាំដំណឹងពី
## សមាជិកក្រុមគ្រួសារដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហម



រូបថតរាប់ពីឆ្វេង៖ ប្អូនស្រីពៅ យ៉ាង ស៊ី ឈីង, បងស្រីធំ យ៉ាង ស៊ី ហ៊ុរី, រូបខ្ញុំ យ៉ាង មួយហេង, បងថ្លៃស្រីធំ លីង មែង ឈីង, បងប្រុសធំ យ៉ាង តា មីង, បងប្រុសទីពីរ យ៉ាង សឺ មីង, ក្មួយប្រុសពៅ យ៉ាង ចឺ ហាវ, ក្មួយប្រុសធំ យ៉ាង ចឺ ហ៊ីង។ (យ៉ាង មួយហេង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

យីង តេរី បានផ្ញើសារអេឡិចត្រូនិចមកកាន់ មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងគោលបំណងស្វែងរកសមាជិកក្រុមគ្រួសារជូនដល់ម្ដាយឈ្មោះ យ៉ាង មួយហេង ដែលបានបែកគ្នាក្នុងរបបខ្មែរក្រហម ដោយបានសរសេររៀបរាប់ថា៖

ខ្ញុំផ្ញើសារអេឡិចត្រូនិចទៅកាន់ មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយសង្ឃឹមថា មជ្ឈមណ្ឌលឯកសារកម្ពុជា អាចជួយដល់ម្ដាយរបស់ខ្ញុំដើម្បីស្វែងរកសមាជិកក្រុមគ្រួសារ ដែលបានបែកគ្នាអស់រយៈពេល៥០ឆ្នាំកន្លងទៅ ឬយ៉ាងហោចណាស់ អាចជួយស្វែងរកដំណឹងថា តើមានរឿងអ្វីបានកើតឡើងចំពោះសមាជិកក្រុមគ្រួសាររបស់ម្ដាយខ្ញុំ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ម្ដាយរបស់ខ្ញុំ បានទទួលដំណឹងថា សមាជិកក្រុមគ្រួសាររបស់គាត់ត្រូវខ្មែរក្រហមសម្លាប់ទាំងអស់។ ក្រោយមក ម្ដាយរបស់ខ្ញុំក៏ទទួលបានដំណឹងផ្សេងទៀតដែរថា មានមនុស្សធ្លាប់ប្រទះឃើញក្រុមគ្រួសារបងស្រីច្បងរបស់ម្ដាយខ្ញុំ ធ្លាប់រស់នៅក្បែរជើងភ្នំខដុង្គ ក្នុងខេត្តកំពង់ស្ពឺ ហើយធ្លាប់ប្រទះឃើញបងប្រុសរបស់ម្ដាយខ្ញុំរស់នៅក្នុងប្រទេសវៀតណាម។ ម្ដាយខ្ញុំ បានព្យាយាមស្វែងរកសមាជិកក្រុមគ្រួសាររបស់គាត់គ្រប់ទីកន្លែង ប៉ុន្តែគាត់នៅតែមិនបានទទួលដំណឹងអ្វីឡើយ។ ម្ដាយខ្ញុំនៅតែសង្ឃឹមក្នុងចិត្តថា យ៉ាងហោចណាស់ នៅមានសមាជិកក្រុមគ្រួសាររបស់គាត់ណាម្នាក់នៅរស់រានមានជីវិតពីរបបខ្មែរក្រហម។

ក្នុងនាមខ្ញុំជាកូនស្រីខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនអាចជួយអ្វីដល់ម្ដាយរបស់ខ្ញុំបានទាល់តែសោះ។ ខ្ញុំនិងបងប្អូនរបស់ខ្ញុំ កើតនៅសហរដ្ឋអាមេរិក ហើយយើងមិនធ្លាប់ស្គាល់សមាជិកក្រុមគ្រួសាររបស់ម្ដាយខ្ញុំណាម្នាក់នោះឡើយ។ អ្វីដែលយើងបានដឹងអំពីសមាជិកក្រុមគ្រួសាររបស់ម្ដាយខ្ញុំនោះ គឺត្រឹមតែជាសាច់រឿងដែលម្ដាយខ្ញុំ បានរៀបរាប់ប្រាប់ទៅតាមការចងចាំរបស់គាត់តែប៉ុណ្ណោះ។ ខ្ញុំចង់ដឹងអំពីសមាជិកក្រុមគ្រួសាររបស់ម្ដាយខ្ញុំឲ្យបានច្រើនជាងនេះ ហើយខ្ញុំក៏ចង់ចូលរួមចំណែកក្នុងការជួយផ្សះផ្សាផ្លូវចិត្តជូនម្ដាយរបស់ខ្ញុំ។ ខាងក្រោមនេះ គឺជាឈ្មោះនិងរូបថតរបស់សមាជិកក្រុមគ្រួសាររបស់ម្ដាយខ្ញុំដែលបាត់ដំណឹង៖

**១) ឪពុកឈ្មោះ យ៉ាង មួយអៀណាំគង**

**២) ម្ដាយឈ្មោះ លី ស៊ីជួង**

**៣) បងស្រីទី ១ ឈ្មោះ យ៉ាង ស៊ី ហ៊ឿ និងប្ដីឈ្មោះ អ៊ូ តាង យាន**

**៤) បងប្រុសទី១ ឈ្មោះ យ៉ាង តាគ័ង និងប្រពន្ធ ឈ្មោះ លីង មែងឈីន**

**៥) បងប្រុសទី ២ ឈ្មោះ យ៉ាង សឺមីង**

**៦) ប្អូនស្រីឈ្មោះ យ៉ាង ស៊ីឈីង**

**៧) កូនរបស់បងស្រីទី១ មានចំនួន៧នាក់ គឺ អ៊ូ ទឹន យាង, អ៊ូ ទឹន ហ័រ, អ៊ូ ទឹន ហ្វួយ, អ៊ូ ទឹន ជា, អ៊ូ ទឹន ហាង, អ៊ូ ទឹន សឹង និង អ៊ូ ទឹនវៃ។**

**៨) កូនរបស់បងប្រុសទី ២ មានចំនួន ៣នាក់ គឺ យ៉ាង ចឹង ហ្វឹង, យ៉ាង ចឹ ហាង និង យ៉ាង ចឹ ធៀង។**

*ប្រសិនបើអ្នកមានព័ត៌មាន ឬស្គាល់ឈ្មោះដូចដែលបានរៀបរាប់ខាងលើ សូមទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈ: អាសយដ្ឋានអ៊ីម៉ែល៖*

truthsodavy.u@dccam.org

*និងលេខទូរសព្ទ ០៧៨ ៩១០ ៧០៧ ឬទំនាក់ទំនងមកកាន់ខ្ញុំផ្ទាល់តាមរយៈ: អាសយដ្ឋានអ៊ីម៉ែល*

terri.s.yeung@gmail.com ។

## ខាងក្រោមគឺជាដំណើរជីវិតរបស់ យ៉ាង មួយហេង ៖

*ខ្ញុំឈ្មោះ យ៉ាង មួយហេង ភេទស្រី អាយុ៧០ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅស្រុកអង្គស្នួល ខេត្តកណ្ដាល ប្រទេសកម្ពុជា។ សព្វថ្ងៃនេះខ្ញុំរស់នៅសហរដ្ឋអាមេរិក។ ម្ដាយរបស់ខ្ញុំឈ្មោះ លី ស៊ីជួង និងឪពុករបស់ខ្ញុំឈ្មោះ យ៉ាង មួយអៀណាំគង។ ឪពុកម្ដាយរបស់ខ្ញុំមានស្រុកកំណើតនៅសានថូវ នៃប្រទេសចិន។ គាត់ គឺជាចិនទាជីវ។ ឪពុកម្ដាយរបស់ខ្ញុំបានរៀបការ និងបង្កើតបានបងស្រីខ្ញុំម្នាក់នៅក្នុងប្រទេសចិន។ ម្ដាយឪពុករបស់ខ្ញុំបានចាកចេញពីប្រទេសចិនមករស់នៅក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ១៩២០ មកម្ល៉េះ ពីព្រោះនាពេលនោះការរស់នៅក្នុងប្រទេសចិនជួបប្រទះបញ្ហាលំបាកខ្លាំង។ ប្រជាជនចិនម្នាក់ៗគិតតែចង់រត់គេចចេញពីប្រទេសរបស់ខ្លួនទៅរស់នៅបរទេសវិញ។ ដំបូងឪពុកម្ដាយរបស់ខ្ញុំមករស់នៅម្ដុំប៉ោយប៉ែតក្បែរព្រំដែនថៃ ហើយបន្ទាប់មក គាត់បានផ្លាស់មករស់នៅក្នុងស្រុកអង្គស្នួល ខេត្តកណ្ដាលវិញ។ បងប្រុសរបស់ខ្ញុំ ប្អូនខ្ញុំ រួមទាំងខ្ញុំ កើតនៅស្រុកអង្គស្នួល ខេត្តកណ្ដាល។ ខ្ញុំរស់នៅអង្គស្នួលរហូតដល់ខ្ញុំមានអាយុ៨ឆ្នាំ។ នៅពេលនោះកងកម្លាំងទ័ពព្រៃ និងកងកម្លាំងរដ្ឋាភិបាល តែងតែប្រយុទ្ធគ្នា។ កងកម្លាំងទ័ពព្រៃ ចេះតែចូលមកអុកឡុករំខានដល់ប្រជាជនរស់នៅក្នុងភូមិ ហើយការប៉ះទង្គិចគ្នារវាងភាគីទាំងពីរនេះ បានប៉ះពាល់ដល់ការប្រកបរបររកស៊ីរបស់គ្រួសារខ្ញុំ និងប្រជាជនដ៏ទៃទៀតយ៉ាងខ្លាំង។ ដូច្នេះហើយក្រុមគ្រួសាររបស់ខ្ញុំ បានសម្រេចចិត្តចាកចេញមករស់នៅម្ដុំផ្សារថ្មី ក្នុងទីក្រុងភ្នំពេញវិញ។*

*មកដល់ភ្នំពេញ ឪពុករបស់ខ្ញុំប្រកបមុខរបររកស៊ីជួសជុលកែលម្អផ្ទះ អាគារ និងគ្រឿងសម្ភារប្រើប្រាស់ក្នុងផ្ទះផ្សេងៗ។ នៅម្ដុំផ្សារថ្មីក្បែរផ្ទះរបស់ខ្ញុំ សម្បូរទៅដោយជនជាតិចិនរស់នៅច្រើនណាស់។ ជនជាតិចិនភាគច្រើននិយាយភាសាទាជីវ និងសរសេរភាសាចិនកុកងឺ។ ខ្ញុំធ្លាប់បានចូលរៀននៅសាលាជាច្រើន ដូចជាសាលា លានហ្វូរ ស៊ុនមីង លីមីង*



*រូបខាងមុខ៖ ប្អូនស្រីពៅ យ៉ាង ស៊ី ឈីង (យ៉ាង មួយហេង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

និងលានយ៉ូវ។ នៅក្នុងថ្នាក់ ខ្ញុំរៀនតែចិនកុកងឺ និងរៀនភាសាខ្មែរបន្តិចបន្តួចប្រហែលជា ២ដងក្នុងមួយសប្តាហ៍។ ខ្ញុំធ្លាប់បានទៅរៀនភាសាខ្មែរនៅសាលាបាក់ទូកពេលល្ងាចដែរ ហើយទោះបីជាខ្ញុំខំប្រឹងប្រែងរៀនសូត្រយ៉ាងណា ខ្ញុំនៅតែរៀនមិនសូវចេះ។ ក្រោយមក ខ្ញុំមិនសូវចាប់អារម្មណ៍នឹងការសិក្សាទៀតទេ ដូច្នេះហើយខ្ញុំសម្រេចចិត្តឈប់រៀន។ ខ្ញុំរៀនបានត្រឹមតែកម្រិតបឋមសិក្សាតែប៉ុណ្ណោះ។ បងប្រុសនិងប្អូនស្រីរបស់ខ្ញុំរៀនសូត្របានច្រើនជាងខ្ញុំ។

នៅក្នុងទីក្រុងភ្នំពេញ ជារឿយៗមានភាពចលាចលបានកើតឡើង។ សាលាចិន និងហាងចិនបានបិទទ្វារ ហើយជនជាតិចិនមិនត្រូវបានអនុញ្ញាតឲ្យប្រើភាសាចិនកុកងឺទៀតទេ។ យើងត្រូវបង្ខំឲ្យរៀនភាសាខ្មែរ។ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ សមាគមចិនទាជីវ បានបន្តប្រកបមុខរបររកស៊ីតាមធម្មតាវិញ ប៉ុន្តែគ្រាន់តែមានការប្រុងប្រយ័ត្នឲ្យបានខ្ពស់ជាងមុននៅពេលចេញទៅខាងក្រៅផ្ទះ។ នៅពេលនោះ ឪពុករបស់ខ្ញុំមានវ័យកាន់តែចំណាស់ ហើយគាត់បានបញ្ឈប់មុខរបររកស៊ីរបស់គាត់។ បងប្រុសរបស់ខ្ញុំ គឺជាអ្នករកស៊ីចិញ្ចឹមគ្រួសារ។ បងប្រុសរបស់ខ្ញុំ បានបម្រើការងារនៅក្នុងក្រុមហ៊ុនទេសចរណ៍មួយនៅទីក្រុងភ្នំពេញ ហើយនៅពេលយប់គាត់ទៅលក់ផ្លែឈើនៅឯរោងកុនអង្គរ។

គ្រួសាររបស់ខ្ញុំបានជួបប្រទះនឹងការលំបាកណាស់។ យើងគ្មានអង្ករហូបគ្រប់គ្រាន់នោះទេ។ យើងធ្លាប់បានទទួលការឧបត្ថម្ភជាអង្ករពីរាជរដ្ឋាភិបាលដែរ។នៅពេលនោះដែរ យើងមិនត្រូវបានអនុញ្ញាតឲ្យចាកចេញទៅខាងក្រៅផ្ទះបន្ទាប់ពីម៉ោង ៩យប់នោះទេ។ ប្រជាជនចិនភាគច្រើនចង់ចាកចេញពីប្រទេសកម្ពុជា ព្រោះដោយសារតែប្រទេសកម្ពុជាមានភាពចលាចលមិនចេះឈប់ឈរ។ ទាំងប្រជាជនខ្មែរ ចិន និងជាតិសាសន៍ដទៃទៀត ជួបការលំបាកយ៉ាងខ្លាំងដោយសារតែភាពចលាចលនេះ។


បងប្រុសទីពីរ យ៉ាង សឺមីង (យ៉ាង មួយហេង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មុនពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាចក្នុងឆ្នាំ១៩៧៥ ខ្ញុំបានចាកចេញពីប្រទេសកម្ពុជាមករស់នៅហុងកុង។ នៅក្នុងក្រុមគ្រួសាររបស់ខ្ញុំ គឺមានតែខ្ញុំទេដែលបានចាកចេញទៅហុងកុង។ ខ្ញុំចាកចេញទៅហុងកុងជាមួយនឹងម្តាយធម៌ រួមទាំងមិត្តភក្តិរបស់ខ្ញុំផ្សេងៗទៀត។ ម្តាយធម៌របស់ខ្ញុំ មានគម្រោងចាកចេញទៅហុងកុង ហើយគាត់បានសួរខ្ញុំថា តើខ្ញុំចង់ទៅជាមួយគាត់ដែរឬទេ ហើយខ្ញុំបានសម្រេចចិត្តចាកចេញទៅហុងកុងជាមួយគាត់។ ដំបូង ម្តាយរបស់ខ្ញុំ មិនចង់ឲ្យខ្ញុំចាកចេញទៅទេ ប៉ុន្តែខ្ញុំទទូចសុំគាត់ទៅ ដោយប្រាប់គាត់ថាមិត្តភក្តិរបស់ខ្ញុំជាច្រើននាក់ក៏ចាកចេញទៅហុងកុងជាមួយខ្ញុំដែរ។ ពេលនោះម្តាយរបស់ខ្ញុំប្រាប់ខ្ញុំថា របបថ្មីកំពុងតែចូលមកកាន់កាប់ប្រទេសកម្ពុជា ដូច្នេះគ្មានអ្វីគួរឲ្យបារម្ភនោះទេ។

ការចាកចេញទៅបរទេសនៅពេលនោះមិនមានលក្ខណៈងាយស្រួលទេ។ រដ្ឋាភិបាលខ្មែរមិនចេញលិខិតឆ្លងដែនឲ្យខ្ញុំឡើយ។ ខ្ញុំបានប្រើប្រាស់លិខិតឆ្លងដែនតៃវ៉ាន់ សម្រាប់ចាកចេញទៅហុងកុង។ ម្តាយធម៌របស់ខ្ញុំគឺជាអ្នករៀបចំធ្វើលិខិតឆ្លងដែនតៃវ៉ាន់ឲ្យខ្ញុំ។ ខ្ញុំគ្រាន់តែឈរចាំតម្រង់ជួរជាមួយម្តាយធម៌របស់ខ្ញុំដើម្បីទទួលបានលិខិតឆ្លងដែន រួចធ្វើដំណើរចាកចេញទៅ។ នៅពេលនោះ គ្មានជើងយន្តហោះដែលហោះហើរត្រង់សំដៅទៅកាន់ហុងកុងឡើយ។ ខ្ញុំត្រូវជិះយន្តហោះពីប្រទេសកម្ពុជាទៅកាន់ប្រទេស ឡាវ រួចបន្តដំណើរទៅហុងកុង។

ខ្ញុំសម្រេចចិត្តចាកចេញទៅហុងកុងព្រោះពូទី ៣ និងសាច់ញាតិរបស់ខ្ញុំស្នាក់នៅទីនោះ។ ខ្ញុំក៏មានពូទី ៤ រស់នៅក្នុងប្រទេសឥណ្ឌូនេស៊ីដែរ ប៉ុន្តែខ្ញុំមិនចង់ទៅទេ ពីព្រោះនៅប្រទេសឥណ្ឌូនេស៊ីជារឿយៗមានភ្នំភ្លើងផ្ទុះ។ ដូច្នេះ ខ្ញុំបានសម្រេចចិត្តទៅហុងកុងដើម្បីរកការងារធ្វើមួយរយៈពេល ហើយបន្ទាប់ពីប្រទេសកម្ពុជាមានសភាពការណ៍ស្ងប់ស្ងាត់ហើយ ខ្ញុំនឹងវិលត្រឡប់មករកគ្រួសាររបស់ខ្ញុំវិញ។

នៅពេលដែលខ្ញុំទៅដល់ហុងកុងដំបូង ខ្ញុំស្នាក់នៅជាមួយម្តាយធម៌របស់ខ្ញុំនៅឯទីក្រុងកៅលូន ព្រោះគាត់

មានសាច់ញាតិស្នាក់នៅទីនោះ។ ខ្ញុំបានស្នាក់នៅជាមួយម្ដាយធម៌របស់ខ្ញុំប្រហែល១ខែ ហើយខ្ញុំបានចាប់ផ្ដើមស្វែងរកការងារធ្វើ។ ខ្ញុំបន្តរស់នៅជាមួយម្ដាយធម៌របស់ខ្ញុំបានប្រហែលជា១ឆ្នាំ រួចខ្ញុំសម្រេចចិត្តចាកចេញទៅរស់នៅស៊ីងធូជាំងម្នាក់ឯង។ ខ្ញុំបានចូលធ្វើការងារ ហើយអាចមានលទ្ធភាពក្នុងការជួលកន្លែងស្នាក់នៅដោយខ្លួនឯងបាន។ ខ្ញុំ ធ្វើការងារជាជាងដេរ និងកាត់សម្លៀកបំពាក់នៅក្នុងរោងចក្រ។ នៅហុងកុង ខ្ញុំធ្លាប់បានឃើញជនជាតិខ្មែរទៅរស់នៅទីនោះមួយចំនួនដែរ។

ខ្ញុំរស់នៅហុងកុងបានប្រហែលជា១ឆ្នាំ ទើបខ្ញុំបានទទួលសំបុត្រពីក្រុមគ្រួសាររបស់ខ្ញុំ។ បងស្រីរបស់ខ្ញុំបានផ្ញើរូបថតមកឲ្យខ្ញុំ ហើយខ្ញុំបានទិញសម្ភារខ្លះផ្ញើទៅឲ្យឪពុកម្ដាយរបស់ខ្ញុំវិញតាមរយៈមិត្តភក្តិរបស់ខ្ញុំដែលរកស៊ីដឹកជញ្ជូនឥវ៉ាន់តាមកប៉ាល់។ ខ្ញុំផ្ញើឥវ៉ាន់ទៅឲ្យក្រុមគ្រួសាររបស់ខ្ញុំបានតែម្ដងនេះតែប៉ុណ្ណោះ ហើយខ្ញុំទទួលបានសំបុត្រពីក្រុមគ្រួសាររបស់ខ្ញុំចំនួន ៣ដង។ នៅក្នុងសំបុត្រទាំងអស់នោះ ម្ដាយខ្ញុំតែងតែសរសេរសួរសុខទុក្ខខ្ញុំថា តើខ្ញុំសុខសប្បាយដែរឬទេ ហើយគាត់បានប្រាប់ខ្ញុំឲ្យបន្តស្នាក់នៅហុងកុងមួយរយៈពេលទៀត រង់ចាំរហូតដល់ប្រទេសកម្ពុជាមានសភាពការស្ងប់ស្ងាត់ចាំវិលត្រឡប់មកវិញ។ ក្រោយមក ខ្ញុំមិនអាចទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់ខ្ញុំបានទៀតទេ។

ខ្ញុំបានដឹងពីរបបខ្មែរក្រហមខ្លះនៅពេលដែលខ្ញុំរស់នៅហុងកុង។ ក្រោយមក សហរដ្ឋអាមេរិកបានប្រកាសទទួលយកជនភៀសខ្លួន ហើយនៅក្នុងឆ្នាំ១៩៧៧ ខ្ញុំនិងប្រជាជនមួយចំនួនទៀតនៅហុងកុង បានស្នើសុំទៅរស់នៅឯសហរដ្ឋអាមេរិក។ ខ្ញុំចង់ចាកចេញទៅរស់នៅសហរដ្ឋអាមេរិក ព្រោះខ្ញុំគិតថាសហរដ្ឋអាមេរិក អាចមានភាពងាយស្រួលជាងការរស់នៅក្នុងប្រទេសកម្ពុជា និងហុងកុង។ នៅក្នុងឆ្នាំ១៩៧៧ ខ្ញុំបានជួបបុរសម្នាក់ឈ្មោះ ឈីង យានចុង នៅហុងកុងខណៈពេលដែលគាត់ធ្វើដំណើរពីប្រទេសថៃទៅកាន់សហរដ្ឋអាមេរិក។ ក្រោយមក ខ្ញុំនិងគាត់បានរៀបការជាមួយគ្នានៅអាមេរិក។ ប្ដីរបស់ខ្ញុំបានចាកចេញពីប្រទេសកម្ពុជាមករស់នៅក្នុងប្រទេសថៃ មុនពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច ហើយក្រោយមកតំបន់ដែលគាត់រស់នៅក្នុងប្រទេសថៃត្រូវបានដាក់ជាជំរំជន



រូបថតក្រុមគ្រួសារ និងសាច់ញាតិរបស់ យ៉ាង មួយហេង ។

(យ៉ាង មួយហេង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមគ្រួសារបងប្រុសធំ៖ បងប្រុសធំ យ៉ាង តាគីង, បងថ្លៃស្រី លីង មែវឈីង, ក្មួយប្រុសធំ យ៉ាង ចី ហ៊ីង, ក្មួយប្រុសតូច យ៉ាង ចី ហាវ (យ៉ាង មួយហេង/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ភៀសខ្លួន។ នៅពេលនោះ ខ្ញុំបានស្នើសុំឲ្យប្តីរបស់ខ្ញុំជួយធានាខ្ញុំទៅរស់នៅសហរដ្ឋអាមេរិក ប៉ុន្តែប្តីរបស់ខ្ញុំមិនអាចធានាខ្ញុំបាននោះទេ ព្រោះគាត់មិនទាន់ទទួលបានសញ្ជាតិអាមេរិកនៅឡើយ។ ប្តីរបស់ខ្ញុំ បានរកអ្នកធានាផ្សេងមកធានារហូតខ្ញុំបានទៅសហរដ្ឋអាមេរិកនៅក្នុងឆ្នាំ១៩៨០។

គ្មាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់ខ្ញុំដឹងថាខ្ញុំមករស់នៅអាមេរិកនោះទេ។ នៅពេលដែលខ្មែរក្រហមគ្រប់គ្រងប្រទេសកម្ពុជា ខ្ញុំមិនដែលទទួលបានដំណឹងអ្វីពីក្រុមគ្រួសាររបស់ខ្ញុំឡើយ។ រហូតដល់របបខ្មែរក្រហមបានដួលរលំ មានជនភៀសខ្លួនជាច្រើននាក់ បានមករស់នៅអាមេរិក។ ពេលនោះ ខ្ញុំបានជួបជាមួយនឹងមិត្តភក្តិរបស់បងស្រីច្បងរបស់ខ្ញុំនៅសហរដ្ឋអាមេរិក។ គាត់គឺជាជនភៀសខ្លួនមកពីប្រទេសកម្ពុជា។ មិត្តភក្តិរបស់បងស្រីខ្ញុំបានប្រាប់ខ្ញុំថា គាត់ធ្លាប់បានឃើញក្រុមគ្រួសារបងស្រីរបស់ខ្ញុំរស់នៅម្តុំជើងភ្នំទង្គុង។ ខ្ញុំបានសួរបញ្ជាក់គាត់ទៀតថា តើគាត់ពិតជាឃើញក្រុមគ្រួសារបងស្រីរបស់ខ្ញុំមែនឬទេ? គាត់បានឆ្លើយតបមកខ្ញុំវិញយ៉ាងច្បាស់ថា គាត់ពិតជាធ្លាប់ឃើញមែន។ ប៉ុន្តែក្រោយមក គាត់មិនដឹងថាក្រុម គ្រួសាររបស់បងស្រីខ្ញុំទៅរស់នៅទីណានោះទេ។ គាត់ក៏មិនច្បាស់ដែរថាម្តាយឪពុក បងប្រុសនិងប្អូនស្រីរបស់ខ្ញុំបានទៅរស់នៅជើងភ្នំទង្គុងជុំគ្នាដែរឬអត់។ ក្រោយមកមានបុគ្គលផ្សេងទៀតបានមកប្រាប់ខ្ញុំថា គាត់ធ្លាប់ឃើញបងប្រុសរបស់ខ្ញុំរស់នៅក្នុងប្រទេសវៀតណាម។ ដំណឹងទាំងអស់នេះ បានផ្តល់ក្តីសង្ឃឹមដល់ខ្ញុំយ៉ាងខ្លាំង។ ខ្ញុំបានខិតខំស្វែងរកដោយបានទំនាក់ទំនងទៅកាន់ជំរំជនភៀសខ្លួននៅប្រទេសថៃ និង ស្វែងរកបងប្រុសរបស់ខ្ញុំនៅក្នុងប្រទេសវៀតណាម។ ខ្ញុំបានចំណាយពេលស្វែងរកក្រុមគ្រួសាររបស់ខ្ញុំជាង ៤០ឆ្នាំកន្លងមកហើយ ប៉ុន្តែខ្ញុំមិនដែលបានទទួលដំណឹងអ្វីទាល់តែសោះ។ ទោះបីជាយ៉ាងនេះក្តី ខ្ញុំមិនអស់សង្ឃឹមក្នុងការបន្តស្វែងរកក្រុមគ្រួសាររបស់ខ្ញុំនោះទេ។ ខ្ញុំនៅតែសង្ឃឹមថា ថ្ងៃណាមួយខ្ញុំទទួលបានដំណឹងពីសមាជិកក្រុមគ្រួសាររបស់ខ្ញុំ។



រូបថតក្រុមគ្រួសារ និងសាច់ញាតិរបស់ យ៉ាង មួយហេង ។
(យ៉ាង មួយហេង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំនឹកស្មានមិនដល់ទេថា ការចាកចេញរបស់ខ្ញុំនឹងមិនអាចវិលត្រឡប់មកវិញបានយ៉ាងដូច្នេះ។

រូបក្របមុខ៖

ស្ត្រីចូលរួមពិធីរំឭកវិញ្ញាណក្ខន្ធដល់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

បុរសកំពុងរៀបចំអដ្ឋិធាតុជនរងគ្រោះ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 257, May 2021 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.